ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-Oct-2015, 09:32
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅជំណាក់កាលពីរ
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី៣៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៊ាង

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms. Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆរ័ន្ត

លោក ស្រ៊ា រតនៈ

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក ត្រាវីស ហ្វារ *(Mr. Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ(*Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោកស្រី ម៉ុច សុវណ្ណារី

លោក ហុង គឹមសួន

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក ត្រាវីស ហ្វារ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ស៊ុត សុផល (2-TCW-845) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការបន្តសួរសំណួរទៅសាក្សី៖ លោក ស៊ុត សុផល** (2-TCW-845)

សួរដោយលោក ត្រាវីស ហ្វារ ផ្ដើមពី ........ទំព័រ ៣
សួរដោយលោក ពេជ អង្គ ផ្ដើមពី ........ទំព័រ ២២
សួរដោយចៅក្រម ក្លូឌា ហ្វេនស៍ ផ្ដើមពី........ទំព័រ ២៩
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី........ទំព័រ ៥៥
សួរដោយលោក គង់ សំអុន ផ្ដើមពី ........ទំព័រ ៦១

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៤៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ស៊ុត សុផល ពាក់ព័ន្ធជាមួយនឹងអង្គហេតុការដ្ឋានទំនប់ត្រពាំងថ្មបញ្ចប់ ហើយនិងបន្ទាប់ពីស្តាប់សក្ខីកម្មសាក្សីរូបនេះចប់ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់នូវសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ភាគីលើបញ្ហាចំនួនពីរ៖ ទី១ សំណើរបស់សហមេធាវីការពារក្តី នួន ជា ក្នុងការស្នើសុំបន្ថែមសាក្សីម្នាក់ទៀត ពាក់ព័ន្ធទៅនឹងអង្គហេតុការដ្ឋានទំនប់ត្រពាំងថ្ម អនុលោមតាមវិធាន ៨៧(៤)នៃវិធានផ្ទៃក្នុងអ.វ.ត.ក ឯកសារ E368 ហើយបញ្ហាទី២ គឺសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងទៅនឹងដំណើរការប្រព្រឹត្តទៅនៃសវនាការស្តាប់សក្ខីកម្មអ្នកជំនាញ អ៊ីសា ឧស្មាន ដោយមានការបារម្ភរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅលើការសម្ងាត់នៃសំណុំរឿង០០៣ និង ០០៤, ឯកសារ E367/1។ សូមភាគីជ្រាប។

ក្រឡាបញ្ជីសវនាការកញ្ញា ជា ស៊ីវហ៊ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន ដោយឡែក លោក នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

នៅថ្ងៃនេះ ដើមបណ្តឹង -- សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោក ស៊ុត សុផល។ លោកមានវត្តមានរួចហើយ នៅក្នុងបន្ទប់សវនាការនេះ។ នៅថ្ងៃនេះ មិនមានសាក្សីបម្រុងទេ។ សូមអរគុណលោកប្រធាន។

[០៩:០៤:១៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ជា ស៊ីវហ៉ង។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥ ដែលបញ្ជាក់ថា គាត់មានបញ្ហាសុខភាពឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធិភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា ថ្ងៃនេះ មានអាការៈឈឺចង្កេះខ្លាំង និងឈឺចាប់កាន់តែខ្លាំងនៅពេលអង្គុយយូរ ហើយនិងបានផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម សហការីទាំងអស់។

[០៩:០៦:១៥]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ពីម្សិលមិញយើងបាននិយាយគ្នាអំពីការកំណត់បរិមាណការងារ ហើយនិងការដករបបអាហារ អ្នកណាដែលមិនបានសម្រេចតាមផែនការដែលដាក់ឲ្យ។ តើខ្លួនលោកផ្ទាល់នេះ ឬក៏ថាសមាជិកក្រុមនេះ ខកខានញឹកញាប់ប៉ុនណាដែរ ដែលមិនបានសម្រេចតាមផែនការ ហើយត្រូវបានគេដករបបអាហារនោះ?

**លោក ស៊ុត សុផល៖**

**ឆ៖** បាទ បងប្រធាន ទោះបីតែថាគ្នាប្រឹងហត់ ប្រឹងហេវយ៉ាងម៉េច ស៊ូហត់នឿយយ៉ាងម៉េចក៏ស៊ូទ្រាំ ឈឺជា យ៉ាងម៉េចក៏ស៊ូទ្រាំទៅ ធ្វើម៉េចកុំឲ្យតែខានឲ្យមានវត្តមាននៅហ្នឹងទីកន្លែងដែលគេធ្វើការហ្នឹង អាហ្នឹងគេអត់ទាន់កាត់បន្ថយទេ។

**ស៖** ហើយនៅពេលដែលលោកមិនអាចសម្រេចការងារតាមផែនការបាន តើលោកទទួលបានរបបអាហារប៉ុន្មានដែរ? ហ្នឹងបើលោកខកខានមិនបានសម្រេចតាមផែនការដាក់ឲ្យនោះ?

**ឆ៖** បាទ គេបន្ថយ ដូចថាគេបើកបីវែកអ៊ីចឹងទៅ បើសិនយើងអាក់ខានធ្វើវាមិនបាន គេដកមួយវែក វានៅពីរវែក។

[០៩:០៧:៥៤]

**ស៖** ហើយតើលោកធ្វើម៉េចដើម្បីឲ្យរស់រានទៅបាន ឬក៏ដើម្បីឲ្យមានអាហារគ្រប់គ្រាន់បាន លោកធ្វើយ៉ាងម៉េចទៅ បើគេដករបបអាហារអ៊ីចឹង?

**ឆ៖** បាទ ធ្វើម៉េចចេះតែស៊ូទៅណា។ ធ្វើចេះតែធ្វើ យើងចេះតែប្រឹងធ្វើការទៅ ធ្វើទាល់តែបានហើយ គោលការណ៍ដែលគេដាក់ឲ្យហ្នឹង បានយើងបានរបបទទួលបានមួយវែកមកវិញ។

**ស៖** ខ្ញុំចង់សួរលោកដែលលោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេតគឺឯកសារ E3/7755 ទំព័រភាសាខ្មែរ 00279115, ERN អង់គ្លេស 00293004 និងបារាំង 00338221។ នេះគឺជាអ្វីដែលលោកបានឆ្លើយ៖ “ប្រជាជននៅក្នុងក្រុមរបស់ខ្ញុំត្រូវបានគេអប់រំ កសាង ហើយដករបបអាហារជាញឹកញាប់។ ពេលខ្លះយើងឃ្លានណាស់ យើងសូមបញ្ជាក់ យើងបានហូបអ្វីៗទាំងអស់។” តើលោកចាំទេលោកហូបតាំងពី លោកមានហូប រើសតាំងពីស៊ីដំឡូង កន្ទុយបារីចោលអី កន្ទុយដំឡូងអីៗ តើលោកធ្វើយ៉ាងម៉េចដែរ?

**ឆ៖** បាទ ដល់ពេលគេដើរមកអ៊ីចឹងទៅ គេហូបអា -- គេមានដំឡូងដុត ឬក៏ដំឡូងស្ងោ គេដើរមកដែលគេដើរមកមើលយើងហ្នឹង ហើយគេបោះចោលអ៊ីចឹងទៅ យើងលួចមើលកន្ទុយភ្នែក។ ចាំមើលឲ្យគេដើរផុតអ៊ីចឹងទៅ យើងនឹងសសៀរៗ មិនអាចយកដៃយកអាដំឡូងដែលគេចោលនោះបានទេ។ យកជើងឆ្កឹះ ហើយមើលលិចមើលកើតៗ ហើយយើងរើសកាន់អ៊ីចឹងមក ចែកគ្នាយើងបីនាក់ហ្នឹងហូប។ បើដំឡូងហ្នឹង បើគេឃើញ គេចាប់យកទៅវ៉ៃ ធ្វើទារុណកម្មអីទៅណា។

**ស៖** ហេតុអ្វីក៏លោកនិយាយថា គេនឹងធ្វើទារុណកម្មលោក ប្រសិនណាលោករើសរបបរបស់ទាំងអស់នេះយកមកស៊ីនោះ?

**ឆ៖** បាទ ព្រោះអីមុនហ្នឹង គេប្រជុំប្រាប់យើង ថាគេឲ្យហូបអីប៉ុនណា គឺយើងហូបប៉ុណ្ណឹង។ បើហូបក្រៅពីហ្នឹង គេនឹងវ៉ៃ គេនឹងដំ គេនឹងធាក់យើងហើយណា បើក្រៅពីគោលរបបដែលគេឲ្យ។

**ស៖** តើលោកបានទឹកមកពីណាហូបដែរ? សូមលោកជម្រាបពីបញ្ហាទឹកហូបនេះ បន្តិចមើល។

**ឆ៖** បាទ បើយើងធ្វើការហ្នឹង វាក្បែរបឹង គឺយើងហូបទឹកបឹង។ បើទៅធ្វើការ ដូចថាយើងជីកវាទៅឆ្ងាយប្រហែលកន្លះគីឡូ ឬ១គីឡូអីទៅ គេមានឡាន ឬក៏មានគេអូសទឹកហ្នឹងតាម។ ប៉ុន្តែទឹកហ្នឹងគេទៅយកពីណា កន្លែងណា គឺខ្ញុំអត់ដឹងទេ។

**ស៖** ហើយនៅពេលដែលគេដឹកទឹកតាមឡានយកទៅឲ្យលោកហូបហ្នឹង តើលោកទទួលបានទឹកហូបហ្នឹងគ្រប់គ្រាន់ទេ? ឬថាទឹកដែលគេចែកជូនហ្នឹងមានរបបកំណត់?

**ឆ៖** បាទ ទឹកដែលគេឲ្យហ្នឹង គេឲ្យហូបគ្រប់គ្រាន់ គេដាក់ដប គេដាក់ប៊ីដុង គេបើកឲ្យយើងហ្នឹង ដែលចំនួនមួយថ្ងៃអ៊ីចឹងទៅ។

[០៩:១២:០៦]

**ស៖** ឥឡូវនេះខ្ញុំសូមសួរលោកនូវមនុស្សដែលលោកបានរៀបរាប់ពីម្សិលមិញ។ លោកថាមានមនុស្សក្មេងៗ មានប្រដាប់ទៅដោយអាវុធ ឬក៏ដាវ នៅកន្លែងការដ្ឋានការងារនោះ។ តើលោកអាចផ្តល់តួលេខបានទេពីចំនួនបានទេ មនុស្សក្មេងៗដែលមានអាវុធ និងមានដាវនៅនឹងខ្លួនហ្នឹង មានប្រហែលប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ មនុស្សដែលដើរធ្វើការមើលយើងធ្វើការហ្នឹង មិនមានច្រើនទេ បីនាក់អ៊ីចឹងទៅ មានក្មេងប្រុសហ្នឹងពីរនាក់អ៊ីចឹងទៅ មានមនុស្សចាស់ដូចថានារីហ្នឹងម្នាក់ហ្នឹងទៅ។ បីនាក់ហ្នឹងគេដើរទៅ នារីហ្នឹងគេស្ពាយកាំភ្លើងទៅ ក្មេងៗហ្នឹងកាន់ដាវហ្នឹងទៅ។

**ស៖** តើអាវុធប្រភេទណាដែលអ្នកទាំងនោះគេប្រើប្រាស់ហ្នឹង?

**ឆ៖** អាវុធ ខ្ញុំមិនស្គាល់ហ្នឹងអាវុធស្អីទេ។ អាវុធហ្នឹងវាតូចដែរ វាខ្លី ហើយគេមានបិត មានបើក មានបក ម៉េចអីទេ ព្រោះសម័យយើងនេះ អត់មានប្រើ កាំភ្លើងអត់ឃើញមាន។

**ស៖** អ៊ីចឹងខ្ញុំសូមបញ្ជាក់បន្តិចថា តើកាំភ្លើងនេះវាជាកាំភ្លើងប្រភេទអ្វីដែរ ជាកាំភ្លើងខ្លី ឬក៏ជាកាំភ្លើងវែង?

**ឆ៖** បាទ កាំភ្លើងហ្នឹង គឺកាំភ្លើងវែង ប៉ុនវាមានស្នាយវាបត់។

**ស៖** តាមដែលខ្ញុំចាំហ្នឹង គឺថាលោកបាននិយាយថា អ្នកទាំងអស់នេះគឺថាគឺជាឈ្លប។ តើអ្នកទាំងអស់នេះគឺជាអ្វី គឺជាឈ្លប ជាកងទ័ព ឬក៏ជាអ្វីដែរ?

**ឆ៖** បាទ ព្រោះបើខ្ញុំឮគេហៅថា ឈ្លបៗហ្នឹង មិនដឹងជាកងទ័ពអីទេ។ គេថាឈ្លប ក៏ឈ្លបនឹងគេទៅ ខ្ញុំអត់ដឹងដែរ។

**ស៖** តើលោកដឹងថាអ្នកទាំងនោះមានទំនាក់ទំនងជាមួយថ្នាក់ឃុំ ថ្នាក់ស្រុក ឬក៏ថ្នាក់តំបន់ដែរឬទេ? ហើយតើលោកដឹងថាអ្នកទាំងអស់នោះគេរាយការណ៍ទៅណាដែរ?

**ឆ៖** បាទ មិនដឹងទេ ព្រោះខ្ញុំប្រឹងតែធ្វើការហ្នឹង។ មិនដឹងចេញពីណា គេធ្វើពីណា ខ្ញុំអត់ដឹង។ ដឹងតែ ដូចថា ដឹងថាគេមកប្រើយើង។ គេប្រើម៉េច គឺយើងធ្វើអ៊ីចឹងទៅ។ បើត្រង់គេនៅកន្លែងណា បញ្ជាចេញពីកន្លែងណា ខ្ញុំអត់ដឹងដែរ។

**ស៖** ពីម្សិលមិញលោកបានជម្រាបជូនតុលាការថា មានពេលមួយនោះ លោកបានឃើញមនុស្សម្នាក់គេចងជាមួយនឹងឈើ ហើយត្រូវបានគេវាយដំជា ចងឆ្កាង ចងដោតព្យួរនឹងឈើឆ្កាង ដោយសារតែមិនបានសម្រេចការងារបាន ហើយបើគាត់ធ្វើការមិនបានសម្រេចទៀតទេគឺថា នឹងត្រូវសម្លាប់ចោល។ តើលោកបានជួបរឿងបែបនេះតែម្តងនេះទេ ឬក៏ថាលោកជួបការដាក់ទណ្ឌកម្មបែបនេះច្រើនដងដែរតាមដែលលោកដឹងនោះ?

**ឆ៖** អត់ទេ ព្រោះក្នុងអង្គភាពខ្ញុំ ខ្ញុំឃើញតែម្តង។ ខ្ញុំមិនបាន គេមិនបានដាក់ខ្លួនខ្ញុំផ្ទាល់ទេ ប៉ុន្តែដាក់មិត្តដែលធ្វើការជាមួយគ្នាចំនួនបីនាក់ហ្នឹង។ ដល់ពេលគេហៅទៅ ដល់ពេលវាមក ខ្ញុំមិនបានមើលឃើញច្បាស់ទេ ក៏ប៉ុន្តែខ្ញុំសួរវា វាថា៖ “ហ៊ឺអ្នក! ទៅដល់គេធ្វើបាបអញដល់ហើយ គេចងអញហើយយោងអួសជើងឡើងលើ គេទាញទម្លាក់ៗ” ខ្ញុំថា៖ “ចុះមិនងាប់ឲ្យហើយទៅ?” ហើយវាថា៖ “បើវាមិនងាប់”។ ហើយក៏គេលែងមកឲ្យធ្វើការវិញមក។ មុននឹងលែងមក គេថាថ្ងៃក្រោយបើធ្វើអ៊ីចេះទៀត

គេនឹងយកទៅសម្លាប់ចោល។

**ស៖** បាទ សូមអរគុណដែលបានបំភ្លឺចំណុចនេះ។ ឥឡូវនេះ ខ្ញុំចង់សួរលោកអំពីការហូបចុកវិញ -- អំពីការវាយដំ។ តើលោកធ្លាប់ដែលឃើញឈ្លបវាយដំអ្នកណាម្នាក់ទេ?

**ឆ៖** បាទ ដែលកំពុងធ្វើការហ្នឹងមានឃើញដែរ ប៉ុន្តែវ៉ៃវាមិនដែលបានដល់សន្លប់ ដល់ប្រកាច់ប្រកិនទេ គ្រាន់តែថា ដូចថាគេយកដាវអីហ្នឹងទៅរុញៗហើយ ដូចថាយើងធ្វើរាងយឺតអ៊ីចឹង គេរុញ យកដាវចុងស្រួចៗហ្នឹង គេថា៖ "ធ្វើអ៊ីចឹង? ធ្វើឲ្យលឿនបន្តិចទៅ?"។

**ស៖** តើហេតុអ្វីបានជាគេធ្វើបែបនេះចំពោះអ្នកធ្វើការងារសមាជិកក្នុងកងហ្នឹង? លោកដឹងពីមូលហេតុទេ?

**ឆ៖** ខ្ញុំមិនដឹងទេហ្នឹង ប្រហែលជាអផ្សុកគេទេដឹង វាអត់ការងារធ្វើ។

**ស៖** តើលោកមានបានស្តាប់ឮគេនិយាយអ្វីទៅកាន់ពលករទាំងអស់នោះដែរ នៅពេលដែលគេយកដាវទៅភ្ជង់ពលករនោះ?

**ឆ៖** បាទ គេថាគេណែនាំយើង គេថាឲ្យយើងប្រឹងធ្វើការ ដូចថាអ្នកណាដែលធ្វើហើយ គេអត់យកដាវរុញទេ។ អ្នកណាដែលគ្នាដូចថា ចង់គ្រុន ចង់រងាអ៊ីចឹងទៅ គ្នាដូចថាវារាងឱបដៃឱបជើងអ៊ីចឹងទៅ ក៏យកដាវហ្នឹងទៅវិញ។ ដល់រុញទៅគ្នាក៏ភ័យក៏ធ្វើទៀតទៅ។

[០៩:១៨:៣៤]

**ស៖** តើការដែលយកដើរទៅភ្ជង់នេះ គេភ្ជង់នៅចំពោះមុខអ្នកដទៃ គេភ្ជង់នៅចំពោះមុខពលករហ្នឹង ឬក៏យ៉ាងណា?

**ឆ៖** បាទ ដែលគេភ្ជង់ គឺភ្ជង់នៅកន្លែងដែលធ្វើការ។ យើងកំពុងធ្វើការហ្នឹង គេយកដាវទៅភ្ជង់កន្លែងធ្វើការហ្នឹង។

**ស៖** នៅក្នុងពេលដែលលោកធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម តើលោកដែលឮសួរកងពិសេសណាមួយនោះ? កងណាមួយនោះដែលគេហៅថា កងករណីៗ គឺសំដៅទៅលើ កងខ្ជិលៗហ្នឹង។ លោកធ្លាប់ដែលឮទេ?

**ឆ៖** បាទ សុំម្តងទៀតបងប្រធាន។

**ស៖** តើលោកធ្លាប់ឮថាមានកងដែលអ្នកធ្វើការនៅក្នុងកងនេះ គេចាត់ទុកថាជាអ្នកខ្ជិល ជាកងដាច់ដោយឡែកមួយ។ លោកធ្លាប់ឮទេ? ឬជួនកាលគេហៅថាកងករណី។ កងសម្រាប់អ្នកខ្ជិល។

**ឆ៖** អត់ទេ កន្លែងដែលខ្ញុំធ្វើការហ្នឹង ដូចអត់មានដែលមានរៀបកងខ្ចិលហ្នឹងទេ បើរៀបតែកងឧស្សាហ៍។ អាខ្ចិលដូចអត់មាន។

**ស៖** ឥឡូវខ្ញុំសូមសួរលោកអំពីការចាប់ខ្លួនវិញម្តង។ តើលោកធ្លាប់ដែលបានឃើញ ឬក៏បានដឹងស្ថានភាពដែលថាមានគេចងពលករដោយៗក្រុមឈ្លប ឬក៏ដោយក្រុមណាមួយផ្សេង លោកដែលឃើញទេ?

**ឆ៖** អត់ ឃើញខ្លះដែរ។ ជួនកាលមួយថ្ងៃហ្នឹងក៏ឃើញទៅ ជួនកាលពីរបីថ្ងៃហ្នឹង បើចាប់មិនមែនចាប់តែមួយទេ បើចាប់ឃើញចាប់ពីរ ចាប់បីដែលគេយកទៅ មិនដឹងថាគេយកទៅធ្វើម៉េចអ្នកដែលគេយកទៅហ្នឹងអត់ដែលឃើញមកធ្វើការអីវិញទេ តែយកទៅដឹងតែសូន្យ យកទៅសូន្យ ប៉ុន្តែមិនដឹងគេយកទៅទុកកន្លែងណា កន្លែងខ្ចិលមិនខ្ចិល ខ្ញុំមិនដឹងទេ ប៉ុន្តែយកទៅដឹងតែសូន្យហើយ។

**ស៖** ខ្ញុំគិតថា -- លោកគិតថាការចាប់ចងនេះកើតមានឡើងពីរបីថ្ងៃម្តង ហើយពេលមួយនោះលោកបានឃើញគេបណ្តើរពលករចេញទៅពីការដ្ឋានការងារ។ តើលោកបាននិយាយថាដូច្នេះមែនទេ?

**ឆ៖** បាទ គេថាយកទៅណែនាំ តែដល់ទៅរៀនសូត្រនៅកន្លែងប្រធានហ្នឹងណា ប្រធានគេមិនដឹងនៅឯណាយើងអត់ដឹងពីសម័យនោះ ព្រោះខ្ញុំភ័យខ្លួនដែរ ខ្លាចខ្លួនឯងដែរ ខំប្រឹងតែពីធ្វើការ។

**ស៖** តើអ្នកណាជាអ្នកចងពលករទាំងហ្នឹង ហើយបណ្តើរចេញទៅបាត់នោះ?

**ឆ៖** បាទ ពួកអាឈ្លបតូចៗនោះឯង កូនកុមារតូចៗហ្នឹងឯង វាមកចងយកទៅហ្នឹង។ ពួកឈ្លបដែលដើរមើលយើងរាល់ថ្ងៃហ្នឹងឯង។

[០៩:២២:២៩]

**ស៖** តើពលករដែលគេចងហ្នឹងគឺជាសមាជិកកងរបស់លោក ឬក៏ជាសមាជិកកងផ្សេង?

**ឆ៖** បាទ ដែលមិនមែននៅកងអីខ្ញុំទេ ប៉ុន្តែធ្វើការជាប់ៗជាមួយគ្នាហ្នឹង មើលគ្នាឃើញទៅវិញទៅមកហ្នឹង។ យើងលួចមើលគេៗលួចមើលយើង។ ដល់ពេលគេឃើញមកអីចឹងទៅ ជួនកាលយកដីដុំបានចោលសញ្ញាគ្នាទៅ "នោះគេមកទៀតហើយ" ក៏យើងនាំគ្នាប្រឹងធ្វើប្រឹងអីទៅ។ ហើយដល់ពេលឃើញមកពីខាងខ្ញុំៗយកដីដុំហ្នឹងបាន ក៏ចោលជាសញ្ញាថា "នោះគេមកទៀតហើយវើយ!"។

**ស៖** ហើយហេតុអ្វីបានជាលោកព្យាយាមយកដុំដីចោលជាសញ្ញាទៅដល់ពលករដទៃទៀត?

**ឆ៖** បាទ ហ្នឹងចោលឲ្យដឹង ៗថាគេដើរមកទៀតហើយ យើងប្រឹងធ្វើការ បើសិនណាគេទៅឆ្ងាយបន្តិចទៅ ដូចថាយើងគ្នាយើងនោះវាអត់អីទេ យើងធ្វើបន្តិចបន្តួចៗអីចឹងទៅណា វាអត់ វាហត់

វាហេវ ដល់បើសិនបើគេដើរមកពីលិចអ៊ីចឹងទៅ អាពួកខាងលិចឃើញ គេចោលដីដុំសញ្ញាឲ្យយើងទៅ "នោះគេមកទៀតហើយ" យើងក៏ខំប្រឹងខំប្រែង ដល់ពេលគេហួសឆ្ងាយអ៊ីចឹងទៅ ក៏យើងធ្វើធម្មតាវិញទៅ។

**ស៖** លោក តើលោកដឹងទេ ហេតុអ្វីបានជាគេចាប់ចងប្រជាជនដូចជាលោកបានឃើញគេចាប់ចងពលករហ្នឹង ហើយបណ្ដើរចេញទៅបាត់ហ្នឹង?

**ឆ៖** វាមិនដឹងថាយ៉ាងម៉េច បើគេត្រូវចាប់។ បើគ្នាធ្វើការៗអ៊ីចឹងទៅ គេចាប់យកទៅបាត់ទៅ។

**ស៖** ក្នុងពេលលោកធ្វើការនៅការដ្ឋានការងារនោះ តើគេមានឲ្យលោកធ្វើប្រវត្តិរូប ឬក៏លោកមានបានសរសេរប្រវត្តិរូប ជីវប្រវត្តិអីរបស់លោកឲ្យទៅឲ្យគេទេ?

**ឆ៖** តែពីសម័យនោះបង ដូចមិនដែលមានអ្នកណាគេចេះធ្វើប្រវត្តិរូបអីទេ គេឲ្យធ្វើតែការហ្នឹង ប្រវត្តិរូបអីមិនដែលធ្វើ។

**ស៖** ខ្ញុំគិតថាពីខាងដើមលោកថា ប្រជាជនដែលគេចាប់ចងហ្នឹង គឺគេបណ្ដើរយកទៅផ្ទះប្រធាន តើផ្ទះប្រធានហ្នឹងនៅឯណាហើយ ប្រធានហ្នឹងឈ្មោះអ្វី ហើយប្រធានធ្វើអ្វីដែរ?

**ឆ៖** បាទ គេយកទៅផ្ទះប្រធាន មិនដឹងផ្ទះគេនៅកន្លែងណា បើខ្ញុំអត់ដែលដឹងពីកន្លែងហ្នឹងណា ក៏ប៉ុន្តែប្រធានដែលនៅក្ដាប់ខ្ញុំហ្នឹង ដូចខ្ញុំប្រាប់ថាឈ្មោះតាវ៉ាល់ៗហ្នឹង ប្រធាន។ ហើយដល់គេយកទៅ ប៉ុនមិនដឹងផ្ទះ មិនដឹងជាកន្លែងទីតាំងគេហ្នឹង មិនដឹងគេនៅទីកន្លែងណា ព្រោះខ្ញុំអត់ដឹង។

[០៩:២៥:៥០]

**ស៖** ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ម្ដងទៀត អ៊ីចឹង តើលោកនិយាយថា អ្នកដែលគេចាប់ចងហ្នឹង គេយកទៅផ្ទះ តាវ៉ាល់ អ៊ីចឹងឬ?

**ឆ៖** គេថាយកទៅផ្ទះប្រធាន ប៉ុន្តែបើប្រធានខ្ញុំគឺឈ្មោះ តាវ៉ាល់។

**ស៖** លោកបានឆ្លើយថាពលករដែលគេយកទៅបាត់ហ្នឹង គឺថាមិនដែលត្រឡប់ ឃើញត្រឡប់មកវិញទេ។ ធ្វើម៉េចបានជាលោកប៊ានអះអាងថា អ្នកដែលគេយកទៅបាត់ហ្នឹងមិនដែលបានឃើញត្រឡប់មកវិញ?

**ឆ៖** បាទ ពួកទាំងហ្នឹងគឺធ្វើការជាប់ៗគ្នា ដូចគេមានពួក មួយក្រុមហ្នឹងគេមានបីពួកហ្នឹង គេរៀបជាពួកៗហ្នឹងយើងធ្វើការជាប់គ្នា។ ហើយដល់តែគេដកមួយទៅ យើងដឹង យើងមើលឃើញ បើធ្វើការនៅជុំគ្នាបីក្រុមហ្នឹង វានៅជាប់គ្នាហ្នឹងណា។ ហើយតែដល់ពេលហ្នឹងយើងបាត់សមាជិករបស់

យើងហើយ ហើយដល់ពេលនៅក្បែរគ្នាយើងមើលលួចមើលគ្នាដឹងថា "អូ! អញមុនប្រាំមួយ ឬប្រាំបួននាក់ ឥឡូវអាមួយនោះយកទៅម្សិលមិញ"។ ហើយដល់គេដូរមនុស្សមក គេយកមនុស្សថ្មីមក អត់មានយកអាហ្នឹងមកវិញទេ បាត់អាហ្នឹងតែបាត់ មិនដឹងគេយកទៅដាក់កន្លែងណា ឬក៏គេធ្វើឯណាទៀត យើងអត់ដឹង ព្រោះគេបញ្ចូលមក គេបញ្ចូលថ្មីមក មនុស្សមុខផ្សេង។

[០៩:២៧:១៩]

**ស៖** តើអ្នកដែលគេចាប់ខ្លួនហ្នឹង ជាកុមារ ឬក៏ជាមនុស្សពេញវ័យ?

**ឆ៖** បាទ អ្នកដែលគេចាប់ខ្លួនហ្នឹង ក៏កុមារ ក៏ធ្វើការហ្នឹង វាមានមួយកង គេចែកមួយខណ្ឌៗហ្នឹង អាហ្នឹងកុមារហើយ មួយខណ្ឌទៅនោះទៅមនុស្សចាស់ បើកន្លែងពួកខ្ញុំហ្នឹងកុមារទេ។

**ស៖** តើលោកអាចផ្តល់តួលេខ ថាតើមានកុមារប៉ុន្មាននាក់ដែរ ដែលត្រូវបានគេចាប់ខ្លួនក្នុងពេលដែលលោកធ្វើការនៅការដ្ឋានលើកទំនប់ហ្នឹង ពេញមួយអំឡុងពេលហ្នឹងតែម្តង?

**ឆ៖** បាទ សុំសាថ្មីបន្តិចបងប្រធាន មិនច្បាស់។

**ស៖** ខ្ញុំយល់ថា នេះប្រហែលជាសំណួរដែលពិបាក ប៉ុន្តែតើលោកអាចប៉ាន់ប្រមាណចំនួនសរុបនៃកុមារៗដែលលោកបានឃើញគេចាប់ចងនៅការដ្ឋានទំនប់ត្រពាំងថ្ម ពេញអំឡុងពេលដែលលោកធ្វើការនៅទីនោះ តើលោកឃើញគេចាប់ចងកុមារហ្នឹងប្រហែលប៉ុន្មាននាក់ដែរ?

**ឆ៖** អ៊ូ! បងប្រធានខ្ញុំវាពិបាកនឹងឆ្លើយដែរ ជួនកាលទៅ ចុះបើគេចាប់ជួនថ្ងៃខ្លះមួយ ជួនកាលទៅពីរ ហើយខ្ញុំធ្វើម៉េចបានសរុប បើខ្ញុំអាល័យតែភ័យខ្លួនឯងដែរ មិនដឹងក្នុងរយៈពេលហ្នឹងវាមិនប៉ុន្មាន។ មួយចប់អាងត្រពាំងថ្មហ្នឹងមិនដឹងប៉ុន្មាន ព្រោះខ្ញុំវាមិនយកចិត្តទុកដាក់ ខ្ញុំអាល័យតែភ័យអរៗថ្ងៃនេះមិនដឹងអញ ថ្ងៃណាមិនដឹងជាគេ ថ្ងៃណា មានបានយកចិត្តទុកដាក់ ត្រង់សរុបអ៊ីចឹងទៅ ថ្ងៃនេះប៉ុណ្ណេះនេះប៉ុណ្ណោះ ខ្ញុំម៉េចបានចាំ ភ័យតែខ្លួនឯង។

[០៩:២៩:២៧]

**ស៖** លោកបាននិយាយថា ពលករដែលត្រូវបានគេចាប់ខ្លួនហ្នឹង គឺថាមិនៗដែលឃើញគេត្រឡប់មកវិញទេ។ លោកដឹងថាមានអ្វីកើតឡើងចំពោះអ្នកទាំងអស់នោះទេ?

**ឆ៖** បាទ មិនដឹងទេ ពីព្រោះគេយកទៅបាត់ហើយ មិនដឹងធ្វើម៉េចថាមានកើតឡើង មិនកើតឡើងយើងម៉េចដឹង បើគេយកទៅបាត់ហើយ។

**ស៖** តើលោកដឹងថាមានគុកឬក៏មានមន្ទីរអប់រំកែប្រែណានៅជិតការដ្ឋានទំនប់ត្រពាំងថ្មដែរទេ?

**ឆ៖** មិនដឹងមាននៅកន្លែងណាទេបង បើខ្ញុំវាមិនដឹងដែរកន្លែងគុក កន្លែងច្រវាក់ហ្នឹង វាដឹងតែកន្លែងធ្វើការហ្នឹងឯង។ កន្លែងគុកច្រវាក់ដែលគេចាប់យកដាក់ហ្នឹង មិនដឹងជាគេដាក់នៅកន្លែងណា។ ពួកយើងអ្នកធ្វើការ ធ្វើម៉េចបានដឹង កន្លែងគុកច្រវាក់ហ្នឹង គេលាក់ការណ៍ មិនដែលអ្នកណាដឹងផង ព្រោះមានអាកន្លែងហ្នឹង វាមានតែពួកទាហាន ពួកឈ្លបអីគេនៅហ្នឹង ពួកយើងតែចូលទៅដឹងតែចប់ហើយ ដល់កន្លែងហ្នឹង។

**ស៖** ឥឡូវនេះខ្ញុំសូមចង់សួរលោកអំពីការសម្លាប់នៅការដ្ឋានការងារ តើលោកធ្លាប់ដែលឃើញពលករណាម្នាក់ត្រូវបានឈ្លប ឬក៏កងទ័ព ឬក៏អ្នកណាផ្សេងសម្លាប់នៅការដ្ឋានការងារហ្នឹងតែម្តងដែរទេ?

[០៩:៣១:០៨]

**ឆ៖** បាទ មានខ្លះៗដែរ កន្លែងដែលគេសម្លាប់ ប៉ុន្តែវាមិនញឹកញាប់ ដូចថា១០ថ្ងៃ ឬក៏៥ថ្ងៃអ៊ីចឹងទៅ ឃើញគេវាយមួយ វាយពីរអ៊ីចឹងទេ។ អាហ្នឹងមិនមែនបាញ់ទេ វាយបណ្តោយ។ វាយហើយគេដាក់ហ្នឹងបាតទំនប់ ហើយយើងរែកដីចាក់ពីលើ។

**ស៖** នៅពេលលោកនិយាយ លោកនិយាយជាពហុវចនៈ មានន័យថាសម្លាប់បួនដប់ថ្ងៃម្តង។ សំណួរខ្ញុំសួរថា តើលោកបានឃើញគេសម្លាប់មនុស្សនៅការដ្ឋានហ្នឹងផ្ទាល់តែម្តងទេ ឬក៏ច្រើនដង?

**ឆ៖** ព្រោះដែលខ្ញុំឃើញហ្នឹង តាំងពីខ្ញុំធ្វើការនៅការដ្ឋានហ្នឹង គឺខ្ញុំឃើញពីរដង។

**ស៖** ហើយនៅក្នុងឱកាសដែលលោកបានឃើញនោះ តើលោកឃើញថាមានមនុស្សប៉ុន្មាននាក់ត្រូវបានគេអប់រំកែប្រែអីសិនដែរ ឬក៏យ៉ាងណា លោកបានឃើញអ៊ីចឹងទេ?

**ឆ៖** បាទ មិនដែលឃើញគេណែនាំកែប្រែ ព្រោះមនុស្សហ្នឹងមិនដឹងគេយកពីណាមក ឬក៏គេចាប់ពីកន្លែងណាមក ព្រោះស្រាប់ឃើញមកវាយហ្នឹងតែម្តង។ យកមកសម្លាប់នៅហ្នឹងទំនប់ហ្នឹងតែម្តង ហើយគេឱ្យយើងរែកដីចាក់ពីលើអ៊ីចឹងទៅ។

**ស៖** សំណួររបស់ខ្ញុំ នៅក្នុងពេលដែលលោកបានឃើញគេសម្លាប់មនុស្សហ្នឹង តើលោកបានឃើញគេសម្លាប់ម្នាក់ ឬក៏ពីរនាក់ ឬក៏ប្រាំនាក់ ឬក៏១០នាក់? តើពេលគេសម្លាប់មនុស្សម្តងៗ លោកឃើញគេសម្លាប់មនុស្សប្រហែលប៉ុន្មាននាក់?

**ឆ៖** ពេលដែលគេយកមកសម្លាប់ហ្នឹង គេយកតែម្តងមួយអ៊ីចឹងទៅ។ មិនដែលឃើញយកមកបួន ដប់នាក់ទេ គេយកតែម្តងមួយអ៊ីចឹងទៅ ធ្វើឱ្យយើងខ្លាចហ្នឹងណា។ សម្លាប់តែមួយអ៊ីចឹងទៅ ក៏បួន

ដប់ថ្ងៃអ៊ីចឹងទៅ ឬក៏កន្លះខែអ៊ីចឹងទៅ ឃើញមួយមកទៀតមក។

**ស៖** ធ្វើម៉េចបានជាលោកគិតថា ការសម្លាប់ហ្នឹងគឺជាការសម្លាប់ដើម្បីធ្វើឲ្យលោកខ្លាច?

**ឆ៖** បាទ ពេលដែលគេសម្លាប់ហើយ គេប្រាប់យើង។ គេថា "មិត្តឯងថ្ងៃក្រោយ បើសិនថាមិត្តឯងមិនធ្វើតាមគេ គេនឹងសម្លាប់ដូចដែរ ដែលគេសម្លាប់ហ្នឹងឯង"។ គេឲ្យយើងធ្វើអី ជីកទំនប់ ជីកប្រឡាយ យើងជីកទៅ បើយើងមិនជីក គេហៅយើងទៅសម្លាប់ទៅ ដូចគេសម្លាប់ឲ្យយើងឃើញហ្នឹងឯង។

[០៩:៣៤:៣៦]

**ស៖** អ្នកណាជាអ្នកប្រាប់លោកថា អ៊ីចឹង ថាបើសិនណាជាលោកមិនធ្វើតាមការណែនាំទេ លោកក៏ត្រូវ -- អ្នកឯងក៏នឹងត្រូវគេសម្លាប់ចោលដែរ អ្នកណាអ្នកប្រាប់លោក?

**ឆ៖** គិត បើសម័យហ្នឹងគេហៅថា សេនាជនៗ នារី។ ប៉ុន្តែមិនដឹងឈ្មោះអីទេ ពេលដែលគេយកមកហ្នឹង គឺយើងមិនដឹង អ្នកដែលនៅ អ្នកដែលមកហ្នឹង មិនដឹងជានៅកន្លែងណា ស្រាប់តែគេយកមកសម្លាប់នៅមុខយើងធ្វើការហ្នឹងឯង។ កន្លែងដែលទីតាំងរបស់គេដែលនៅឈរជើងហ្នឹង មិនដឹងជានៅកន្លែងណា ហើយអ្នកដែលស្លាប់ហ្នឹងក៏មិនដឹងគេយកពីកន្លែងណា អ្នកដែលគេយកមកសម្លាប់ហ្នឹង។ ហើយសម្លាប់រួច គេប្រាប់យើងថា ពួកមិត្តឯងខំធ្វើការ បើអ្នកណាមួយមិនធ្វើការ គេនឹងសម្លាប់ដូចដែលគេសម្លាប់ឲ្យយើងឃើញហ្នឹងឯង។

**ស៖** លោកបាននិយាយថា អ្នក -- មានមនុស្សដែលគេសម្លាប់នៅនឹងមុខលោកតែម្តង។ លោកអាចជម្រាបជូនតុលាការបានទេ នៅពេលគេសម្លាប់មនុស្សនឹងមុខអ៊ីចឹង តើមានមនុស្សប៉ុន្មាននាក់ដែរ ពលករប៉ុន្មាននាក់ដែរ បានឃើញរឿងហ្នឹង?

**ឆ៖** បាទ មនុស្សដែលឃើញ ឃើញមួយចង្កោមហ្នឹង បើៗយើងសរុបទៅ ប្រហែលជាខ្ទង់ ១០០នាក់ ឬក៏ទៅ៥០នាក់។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេការសម្លាប់ហ្នឹង សម្លាប់នៅត្រង់កន្លែងណាដែរ?

[០៩:៣៦:២៩]

**ឆ៖** បាទ ដែលសម្លាប់ហ្នឹង គឺសម្លាប់នៅៗនឹងទំនប់ហ្នឹង នឹងបាតទំនប់ហ្នឹងតែម្តង។ វាចម្ងាយពីកែងហ្នឹងមក ប្រហែលជា បើតាមដែលខ្ញុំស្មានមិនភ្លេច ប្រហែលជា១០០ម៉ែត្រ ឬ២០០ម៉ែត្រ ពីកែងខាង ពីជើងមកកើតហ្នឹង អ៎! ពីជើងមកលិចហ្នឹង។

**សះ** ខ្ញុំយល់ថា លោកបានឆ្លើយ លោកៗប្រើពាក្យថា "យើង យើងជាពលករ គឺថាជាអ្នកកប់មនុស្សដែលគេបានសម្លាប់ហ្នឹង"។ លោកឆ្លើយថាអ៊ីចឹងមែនទេ?

**ឆះ** បាទ ចុះៗបើគេ ខ្ញុំឆ្លើយអ៊ីចឹងមែន ក៏ប៉ុន្តែបើយើងអ្នក -- គេយកមកវាយហើយ គេបញ្ជាឱ្យយើងរែកដីចាក់ពីលើទំនប់គេត្រូវលើកហ្នឹងឯង។

**សះ** តើខ្លួនលោកផ្ទាល់ធ្លាប់បានកប់ខ្មោចអ្នកដែលគេសម្លាប់នៅទំនុងដែរទេ ដោយផ្ទាល់ដៃលោកដែរទេ?

**ឆះ** បាទ អ្នកដែលកប់ គឺកប់គ្នាច្រើន ដូចខ្ញុំថា រែកដីចាក់ទៅ គេយកមកវាយដាក់នឹងទំនប់អ៊ីចឹងរួច គេឱ្យយើងរែកដីចាក់ៗគ្របពីលើឱ្យជិត ឡើង ទំនប់ឡើងកម្ពស់ណា កម្ពស់ណី។ មិនរែកកប់តែឯង ហើយយើងលុបចិត្តឯងណា ទំនប់ហ្នឹងគេធ្វើឡើងហើយទំនប់ ហ្នឹងគេដាក់ជាប់នៅបាតទំនប់ហ្នឹងឯង។

[០៩:៣៨:៣២]

**សះ** ហើយតើសូមលោកជួយជម្រាបជូនតុលាការឱ្យច្បាស់លាស់មើល៍ អ្នកដែលសម្លាប់ពលករហ្នឹង ជាអ្នកណា ជាឈ្លប ជាកងទ័ព ឬក៏ជាអ្នកណា?

**ឆះ** បាទ ជាឈ្លប ឈ្លបទៅដើរមើលដូចថា មិនដឹងគេយកពីទីណា មកពីទីណី យើងវាអត់ដឹងព្រោះអ្នកដែលធ្វើការហ្នឹង មិនដែលមានទាហាន មិនដែលមានយោធាទេ តែឈ្លបគ្នាប្អូន ប្រហែលជាប្អូន ដប់នាក់ហ្នឹងឯង ដើរទៅ ដើរមក ជួនកាលដើរពីកន្លែងយើងទៅកន្លែងគេ ជួនកាលដើរពីកន្លែងគេមកកន្លែងយើង។ មកដូចថា គេចែកកន្លែងគ្នាដើរនុំងណ៎ា ជួនកាល អាហ្នឹងដើរទៅនោះទៅ ជួនកាលអានោះដើរមកនេះទៅ។ មុខ យើងចំណាំវាមិនបានអស់ ចំណាំម៉េចបានអស់ បើអាល័យតែភ័យស្លន់ស្លោខ្លួនឯងផង ទៅយកចិត្តទុកដាក់អីមើលមុខ តែឃើញគេដើរមក ឱនស្រ៊ុប មិនហ៊ានមើលមុខគេផង។

**សះ** តើលោកអាចជម្រាបជូនតុលាការបានទេ តើអ្នកទាំងនោះ គេប្រើប្រាស់ឧបករណ៍ ឬក៏អាវុធអ្វីដែរ ដើម្បីសម្លាប់មនុស្ស?

**ឆះ** បាទ អាហ្នឹងគេប្រើដំបង ខ្ញុំឃើញដែលគេវាយ វាយនឹងដំបង។

**សះ** ឥឡូវនេះ ខ្ញុំសុំសួរលោកសង្ខេបទេអំពីស្ថានភាពសុខភាពរបស់ពលករនៅឯការដ្ឋានលើកទំនប់ តើកម្លាំងដែលលើកទំនប់ហ្នឹងធ្លាក់ខ្លួនឈឺញឹកញាប់ដែរទេ បើឈឺហ្នឹង ឈឺដោយសារអ្វីដែរ?

**ឆ៖** បាទ និយាយពីឈឺហ្នឹង វាឈឺទាំងគេ ឈឺទាំងខ្ញុំហ្នឹងឯង ប៉ុន្តែមិនដែលហ៊ានសម្រាកទេ។ ឈឺយ៉ាងម៉េចធ្វើការទាំងឈឺ លុះត្រាតែដួលងាប់តែម្តង អាហ្នឹងបានឈប់ធ្វើ។ ឱ្យតែនៅឈឺយ៉ាងម៉េច នៅតែធ្វើ បើយើងគេប្រើយើងមិនធ្វើ គេថាយើងវាឈឺសតិអារម្មណ៍ ក៏គេយកទៅវាយចោលដែរ។ អាហ្នឹងតាមដែលគេធ្វើការប្រាប់យើង។ ដល់ហើយ អត់យ៉ាងម៉េច ហេវយ៉ាងម៉េច ថាទាល់តែងាប់ទៅណា បានឈប់ធ្វើ អាឈឺក៏វាប្រើឱ្យធ្វើការដែរ។ ហើយបើយើងប្រាប់គេថា "បងអើយ ខ្ញុំឈឺ" គេយកថ្នាំមកឱ្យលេប។ ប៉ុន្តែថ្នាំនេះ មិនដឹងគេពូតអីទេ មូលៗប៉ុនគ្នាហ្នឹង ដូចថាចុងចង្កឹះ ឬក៏ប៉ុនចង្កឹះទៅចុះ មកឱ្យយើងលេប ជាក៏ដោយ មិនជាក៏ដោយ យើងលេបទៅ ធ្វើការបណ្តើរលេបបណ្តើរ។

**ស៖** ខ្ញុំសូមសួរលោកអំពីអនាម័យផងដែរ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ នៅការដ្ឋានការងារហ្នឹងមានបង្គន់ ឬក៏មានកន្លែងបត់ជើង ហើយតើចំណីអាហារហ្នឹង ជាចំណីអាហារប្រកបដោយអនាម័យដែរទេ?

**ឆ៖** បាទ បើអនាម័យដូចគ្មានទេ ព្រោះបត់ជើង ព្រោះគេបើកអី -- បើអាបត់ជើងធំ អាហ្នឹងអត់មានស្អីដាក់ទេ។ យើងដាក់ចោលពាសវាល ពាសកាល បើទឹកនោមយើងហ្នឹងគឺមាន គេបើកប៊ីដុងឱ្យ។ ពេលដែលយើងនោម គេឱ្យយើងនោមដាក់ប៊ីដុង។ ដាក់ប៊ីដុងរួច គេមានកម្លាំងរបស់គេហ្នឹង គេយកទឹកនោម គេមានពាងគេមួយធំប៉ុណ្ណឹងទៅ ពេលយើងសម្រាកធ្វើការហ្នឹង យើងយកទៅចាក់ចូលក្នុងហ្នឹង។ ដើម្បីគេយកអាទឹកនោមហ្នឹង សួរ គេថាយកទៅដាក់ជី ធ្វើជី ធ្វើអីណានោះ។

[០៩:៤២:៣៨]

**ស៖** នៅក្នុងចម្លើយរបស់លោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺថា លោកឆ្លើយថា លោកធ្លាប់បានរត់គេច លោកបានសម្រេចខ្លួនរត់គេចចេញពីការដ្ឋានទំនប់ត្រពាំងថ្ម។ សូមលោកជម្រាបជូនតុលាការផងទៅមើល ហេតុអ្វីបានជាលោកសម្រេចរត់ចេញពីការដ្ឋានទំនប់ត្រពាំងថ្ម?

**ឆ៖** បាទ ព្រោះការងារហ្នឹង ខ្ញុំមើលទៅវាឃើញវាធ្ងន់ធ្ងរពេក នៅធ្វើក៏ស្លាប់ ម្ល៉ោះហើយ រត់ក៏ស្លាប់ ខ្ញុំសុខចិត្តប្រថុយរត់។ ហើយដល់ពេលខ្ញុំរត់ទៅហ្នឹង ខ្ញុំរត់ចូលទៅព្រៃ ដល់ចូលទៅព្រៃ រត់ប្រហែលជាកន្លះខែបានដល់អាកន្លែងស្រួលគ្រាន់ ទៅព្រៃគេមានចម្ការដំឡូងគេធំ។ ទៅដកហូបនៅហូបអីហ្នឹង។ ដល់ឮសន្ធឹកអាត្រាក់ង៉ោងៗអ៊ីចឹងទៅ ខ្ញុំដើរទៅមើល។ ដល់ដើរទៅ អាខ្លះឮស្រែកអីយ៉ូយអីយ៉ាៗ ដែលអាត្រាក់វារុញលុប។

**ស៖** បាទ ខ្ញុំនឹងត្រឡប់មកនិយាយចំណុចបន្តិចទៀតនេះ។ លោកគិតមើលតើមានរយៈពេល

ប៉ុន្មានខែដែរ គិតពីលោករត់គេចចេញពីទំនប់ការដ្ឋានត្រពាំងថ្ម រហូតដល់ដាច់របបខ្មែរក្រហម?

**ឆ៖** បាទ ខ្ញុំរត់ចេញពីការដ្ឋានហ្នឹង ប៉ុនមិនដឹងជាឆ្នាំប៉ុន្មានផង កាលហ្នឹង ខ្ញុំវាអត់ចាំដែរ ព្រោះវា ខ្ញុំវានៅវាងស្មើរដែរទៅ វាអត់ចាំពីឆ្នាំ ឬខែ ក៏ប៉ុន្តែខ្ញុំ ការស្មានរបស់ខ្ញុំដែលខ្ញុំទៅនៅក្នុងព្រៃហ្នឹង ប្រហែល ជាពីរខែ ឬពីរខែកន្លះ បានយើងមករំដោះឆ្នាំ៧៩ ព្រោះហូបតែដំឡូងឆៅ មិនដែលមានភ្លើងអីដុតទេ ហូបដូចប្រមាហើយ។ ហើយជួនកាលគេដើររើសទុំខ្នុរដែលជ្រុះមក ទុំៗហ្នឹងលួច។ យប់ឡើងគេដើរចូលព្រៃជ្រលងវិញទៅ នឹងចម្ការដំឡូងគេហ្នឹង។

**ស៖** មុននេះបន្តិច លោកបានទៅដល់កន្លែងមួយឃើញ ឮសូរសម្រែកស្រែក ហើយគេលុបរណ្តៅ។ តើលោកអាចជម្រាបជូនតុលាការបានថា ពីការដ្ឋានទំនប់ត្រពាំងថ្ម ទៅដល់រណ្តៅនេះ ដែលគេលុបមនុស្សនេះ ចម្ងាយប៉ុន្មានដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ឆ្លើយតប! អញ្ជើញសហមេធាវីអន្តរជាតិលោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេ៖**

ជម្រាបសួលោកប្រធាន។ សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់នឹងសំណួរទាំងអស់នេះ ពីព្រោះថា បើយើងស្តាប់អ្វីដែលសាក្សីបាននិយាយនេះ គឺថាដូចគាត់ថាគាត់បានចំណាយពេលកន្លះខែ ដើម្បីទៅដល់។

**ប្រធានអង្គជំនុំ៖**

មានបញ្ហាបកប្រែ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអ្នកបច្ចេកទេស។ បញ្ហាបកប្រែភាសា។

បាទ អញ្ជើញតទៅទៀត អង់តា ហ្គីសសេ!

និយាយសាថ្មីៗ មិញអត់មានការបកប្រែ។

[០៩:៤៧:១០]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំនិយាយឡើងវិញ។ ខ្ញុំជំទាស់នឹងសំណួរមួយចំនួនកន្លងមកនេះ ដែលព្រះរាជអាជ្ញាកំពុងតែសួរនេះ។ បើយោងតាមចម្លើយពីមុនរបស់សាក្សីហ្នឹង គាត់ថាគាត់បានដើរជាច្រើន ដើម្បីចេញពីទំនប់ត្រពាំងថ្មនេះ ដោយគាត់និយាយថាគាត់មិនបានឃើញមន្ទីរសន្តិសុខនោះទេ ហើយគាត់ក៏មិនបានឃើញ

ការសម្លាប់មនុស្សនៅទំនប់ត្រពាំងថ្មនោះផងដែរនោះ។ អ៊ីចឹងបើសិនជាសហព្រះរាជអាជ្ញាគាត់ចងបន្តដែលទៅនិយាយអំពីមន្ទីរសន្តិសុខនោះទេនោះ វាអត់មាននៅក្នុងដីកាបំបែកដំណើរការនីតិវិធីនោះទេ។ អ៊ីចឹងព្រះរាជអាជ្ញាមិនអាចនិយាយអំពីមន្ទីរសន្តិសុខនៅចំការគរនេះបានទេលោកប្រធាន។ អ៊ីចឹងខ្ញុំជំទាស់នឹងសំណួរទាំងអស់នេះ។

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន អនុញ្ញាតឱ្យខ្ញុំឆ្លើយតបដោយសង្ខេបទេ។ សំណួររបស់ខ្ញុំៗសួរថា ចម្ងាយពីត្រពាំងថ្ម ទៅរណ្ដៅហ្នឹងចម្ងាយប៉ុន្មាន។ ដើម្បីចង់ដឹងថាតើរណ្ដៅដែលពួសម្រែក គេកប់មនុស្សហ្នឹងវាជាផ្នែកមួយនៃកន្លែងដែលគេយកមនុស្សពីការដ្ឋានទៅសម្លាប់ ឬក៏យ៉ាងណា។ ហើយក្រោយមកទៀតខ្ញុំក៏បានសួរថាតើគេប្រើប្រាស់ឧបករណ៍ខ្លះអ្វីដែរ? ហើយខ្ញុំចង់សួរទៅសាក្សី ថាតើមានប្រើឧបករណ៍អីដែរទេ? មានបានឃើញឧបករណ៍ដែលគេប្រើប្រាស់នៅត្រពាំងថ្មហ្នឹង យកមកប្រើប្រាស់នៅកន្លែងដែលគេកប់ហ្នឹង ឬក៏យ៉ាងណា?

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥០:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដី ខៀវ សំផន លើបញ្ហាការតាំងសំណួរនេះ ពីព្រោះបញ្ហានេះវាក៏មិនទាន់ប្រាកដទេ ប៉ុន្តែវាអាចពាក់ព័ន្ធទៅនឹងការដ្ឋានទំនប់ត្រពាំងថ្មដែរ ហើយដើម្បីច្បាស់លាស់ហ្នឹង គឺអាចឱ្យសាក្សីស្ដាប់ -- សាក្សីផ្ដល់សក្ខីកម្មឆ្លើយតបទៅនឹងសំណួរនេះ។ សាក្សីអាចឆ្លើយតបនឹងសំណួរនឹងសំណួរដែលសួរអម្បាញ់មិញនេះ ប្រសិនបើលោកនៅចងចាំ ហើយបើលោកអត់ចាំទេ សូមឱ្យសហព្រះរាជអាជ្ញារងអន្តរជាតិហ្នឹងតាំងសំណួរនោះសាជាថ្មីម្ដងទៀត។ ទំនងជាមិនចាំទេ សូមតាំងសំណួរអម្បាញ់នេះសាជាថ្មីម្ដងទៀត។

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកសាក្សី តើលោកអាចជម្រាបជូនតុលាការថា ចម្ងាយពីកន្លែងដែលលោកទើបរៀបរាប់ថាមានរណ្ដៅ ពីកន្លែងរណ្ដៅដែលលោកបានឃើញហ្នឹង ទៅការដ្ឋានទំនប់ត្រពាំងថ្ម តើមានចម្ងាយ

ប៉ុន្មានដែរ?

**លោក ស៊ុត សុផល៖**

**ឆ៖** បាទ បើតាមដែលការដែលស្មាន បើខ្ញុំស្មានមិនខុសទេ ដីប្រហែលជា៧០គីឡូ ឬក៏៦០គីឡូ ពីតំបន់អាងត្រពាំងថ្មទៅចំការខ្នុរ ចំការគរ។

**ស៖** ក្នុងករណីនេះ ខ្ញុំសុំសួរលោកឲ្យជាក់លាក់បន្តិច។ លោកបានរៀបរាប់ថាលោកបានឃើញត្រាក់ទ័រ ឬក៏ឡានមួយគ្រឿងពីរគ្រឿងទៀតដែលគេបានប្រើប្រាស់នៅពេលនោះ។ ដោយសារលោកធ្លាប់ធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម តើត្រាក់ទ័រ និងឡានធំៗទាំងនេះ អាចជាត្រាក់ទ័រ និងឡាន ដែលគេយកប្រើប្រាស់ដើម្បីជីកដី និងដឹកដីនៅឯការដ្ឋានទំនប់ត្រពាំងថ្មនោះដែរទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[០៩:៥៣:០០]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់ទៅនឹងសំណួរនេះ។ សំណួរនេះសួរឲ្យសាក្សីឆ្លើយស្មានៗទេ។ នៅពេលធ្វើនៅការដ្ឋានទំនប់ត្រពាំងថ្ម សាក្សីអាចមានអាយុតែ១២, ១៣ឆ្នាំ។ នៅពេលធ្វើការហ្នឹង គឺថាគាត់បានឃើញឡាននៅឆ្ងាយពីកន្លែងដែលគាត់ធ្វើការ។ ដូច្នេះសួរបែបនេះគឺថាឲ្យគាត់ឆ្លើយស្មានៗហើយ។

**លោក ត្រាវីស ហ្វារ៖**

ប្រហែលជាសំណួរខ្ញុំមិនច្បាស់ហើយមើលទៅ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំមិនដឹងថាសហព្រះរាជអាជ្ញាមានចេតនាសួរអ្វីនោះទេ ព្រោះថាមានការបង្ហាញច្បាស់ហើយថាសាក្សី គាត់ហ្នឹងគាត់ទើបនឹងឆ្លើយថា គាត់នៅចម្ងាយប្រហែលជា ៦០-៧០គីឡូម៉ែត្រពីទំនប់ត្រពាំងថ្ម ដូចដែលលោកមេធាវី កូប៉េ បាននិយាយអំមិញហើយ គឺថាសុំឲ្យសាក្សីឆ្លើយព្រាវហើយ គឺសុំឲ្យគាត់និយាយអំពី គឺថាព្រះរាជអាជ្ញាសុំឲ្យសាក្សីហ្នឹងនិយាយអំពីកន្លែងមួយដែលនៅចម្ងាយដល់ទៅ ៧០គីឡូម៉ែត្រឯណោះ។ អ៊ីចឹង សុំឲ្យគាត់ឆ្លើយនេះ គឺថាបានត្រឹមតែឆ្លើយដោយស្មានៗនោះទេ ហើយមួយទៀត

នោះ គឺថាវាមិននៅក្នុងវិសាលភាពនៃវគ្គជំនុំជម្រះនេះផងលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចទទួលយកនូវក្តី -- មានអីបញ្ជាក់តនេះទេ? តបទេ?

**លោក ត្រាវីស ហ្វារ៖**

សំណួរខ្ញុំអាចមិនច្បាស់។ សំណួរខ្ញុំសួរថា ឧបករណ៍ប្រភេទ -- សម្ភារៈប្រភេទនេះអាចជាឧបករណ៍មធ្យោបាយដែលគេប្រើប្រាស់នៅការដ្ឋានទំនប់ត្រពាំងថ្មដែរឬអត់? ខ្ញុំយល់ហើយថាគាត់មិនមែនជាអ្នកជំនាញទេ ប៉ុន្តែគាត់ធ្លាប់ធ្វើការនៅទំនប់ត្រពាំងថ្ម ហើយធ្លាប់ឃើញរថយន្ត ឬត្រាក់ទ័របែបនេះ គេប្រើប្រាស់នៅការដ្ឋាននោះ អ៊ីចឹងហើយបានជាខ្ញុំសួរថាតើប្រភេទរថយន្តទាំងអស់នេះ អាចជាប្រភេទរថយន្តដែលគេប្រើប្រាស់នៅឯការដ្ឋានទំនប់ត្រពាំងថ្មដែរឬក៏អត់?

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំឮសួរសាក្សីនិយាយថាគាត់មិនដែលធ្លាប់បានឃើញគេប្រើប្រាស់រថយន្ត ឬក៏គ្រឿងយន្តអីនៅការដ្ឋាននោះទេ។ អ៊ីចឹងធ្វើម៉េចបានគាត់ឆ្លើយបានបើគាត់មិនដែលឃើញរថយន្ត ឬក៏យានយន្តទាំងអស់នេះផង។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥៩:៥០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចថាសេចក្តីជំទាស់របស់មេធាវីការពារក្តីទាំងពីរក្រុមចំពោះសំណួរចុងក្រោយនេះ គឺមានមូលដ្ឋានត្រឹមត្រូវសមស្រប ដែលវាមិនមានមូលដ្ឋានពីដើមទី នាំឲ្យតាំងសំណួរបែបនេះទេ។ អ៊ីចឹងសាក្សីមិនបាច់ឆ្លើយតបនឹងសំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញារងអន្តរជាតិដែលសួរលោកអម្បាញ់មិញហ្នឹងទេ។

បញ្ហាចុងក្រោយ សូមជម្រាបរំឭកទៅសហព្រះរាជអាជ្ញារងទាំងពីរ ហើយរួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីផងដែរថា អង្គជំនុំជម្រះនឹងផ្តល់ពេលវេលានៅពេលចូលមកវិញតែ១៥នាទីបន្ថែមទៀតទេ ជំនួសឲ្យកាលពីការអាក់ខានកាលពីម្សិលមិញរយៈពេល១៥នាទី។ បាទ សូមជ្រាប។

**លោក ត្រាវីស ហ្វារៈ**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ត្រាវីស ហ្វារៈ**

**សៈ** លោកសាក្សីត្រឡប់ទៅនិយាយអំពីបទពិសោធន៍របស់លោកនៅការដ្ឋានទំនប់ត្រពាំងថ្ម។ ខ្ញុំសួរមួយ លោកនិយាយយល់យ៉ាងម៉េចចម្លើយ សេចក្ដីថ្លែងការណ៍របស់ ខៀវ សំផន ដែលគាត់បានធ្វើឡើងនៅខែមេសា ១៩៧៧ គឺឯកសារ E3/201, ERN ជាភាសាខ្មែរ 00292810 ដល់ 11, អង់គ្លេស 00419516 និងបារាំង 00612170។

**កញ្ញា អង់តា ហ្គីសសេៈ**

លោកប្រធានខ្ញុំសូមជំទាស់នឹងសំណួររបស់សហព្រះរាជអាជ្ញា ពីព្រោះគាត់សុំយោបល់ពីសាក្សី គាត់ៗមិនបាននិយាយថា គាត់ស្គាល់ ឬក៏ជួបលោក ខៀវ សំផន នៅពេលណាមួយនោះទេ ប្រសិនបើសុំយោបល់ពីសាក្សីបែបនេះ គាត់មិនមែនជាអ្នកជំនាញទេ។ ដូច្នេះ សំណួរនេះគឺមិនមានមូលដ្ឋានទេ គួរតែត្រូវច្រានចោល ហើយសួរអំពីការនិយាយរបស់លោក ខៀវ សំផន មុន ឬក្រោយពេលអង្គហេតុក្រៅពីបរិបទដែលសាក្សីគាត់មិនដឹងបែបនេះ គឺមិនអាចឲ្យអង្គជំនុំជម្រះ វាយតម្លៃទៅលើភាពអាចជឿជាក់បាននៃសាក្សីរូបនេះ ឬក៏មានព័ត៌មានជាក់លាក់អំពីហេតុការណ៍នៅត្រពាំងថ្មនោះទេ។ ដូច្នេះ អ្វីដែលធ្វើបែបនេះហ្នឹង ដូចជាការសន្និដ្ឋានបញ្ចប់អ៊ីចឹង ប្រសិនបើសហព្រះរាជអាជ្ញាចង់ប្រើចម្លើយរបស់លោក ខៀវ សំផន គាត់អាចធ្វើបាននៅពេលដែលគាត់ធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ចុងក្រោយ។ សាក្សីនេះគាត់មិនដឹងឮអ្វីអំពីលោក ខៀវ សំផន នោះទេ។ ដូច្នេះ សូមយោបល់របស់សាក្សីពាក់ព័ន្ធទៅនឹងសម្ដីរបស់លោក ខៀវ សំផន គឺវាមិនសមស្របទេ។ ដូច្នេះ អង្គជំនុំជម្រះគួរតែច្រានចោលនូវសំណួររបស់សហព្រះរាជអាជ្ញា។

[១០:០២:៤៦]

**លោក ត្រាវីស ហ្វារៈ**

លោកប្រធាន គឺថាខ្ញុំមិនទាន់បានសួរនៅឡើយ។ គឺថាខ្ញុំគ្រាន់តែបង្ហាញឯកសារ និង ERN ហើយខ្ញុំចង់ដកស្រង់ដើម្បីសួរទៅសាក្សី។ មេធាវីការពារក្ដី គឺថាមិនអាចនិយាយថា សាក្សីអាចមានការយល់ឃើញយ៉ាងណាទៅលើ សុន្ទរកថានេះ នៅមុន ៧៧ ក្រោយនោះទេ។ ខ្ញុំសួរបទពិសោធន៍របស់គាត់ ហើយសុន្ទរកថារបស់ ខៀវ សំផន និយាយអំពីកុមារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយសាក្សី

រូបនេះគាត់ក៏ជាកុមារម្នាក់ដែលធ្វើការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះដែរ។ ដូច្នេះ ខ្ញុំគិតថាជាការត្រឹមត្រូវអនុញ្ញាតឲ្យខ្ញុំសួរ ដើម្បីសួរទៅសាក្សីមើល៍ ពីព្រោះសុន្ទរកថារបស់ ខៀវ សំផន នេះគឺនិយាយអំពីស្ថានភាពការងារ ដែលពាក់ព័ន្ធទៅនឹងកុមារផងដែរ។ ដូច្នេះ បើអង្គជំនុំជម្រះអនុញ្ញាតគឺថាខ្ញុំសូមដកស្រង់សម្រង់ខ្លីទេ មុននឹងដល់ពេលឈប់សម្រាក។

**ប្រធានអង្គជំនុំ៖**

ការលោកតាំងសំណួរ ដូចជាយើងមិនច្រឡំទេ ដូចជាយើងអត់ទាន់បានស្តាប់នូវសំណួររបស់លោកសួរថានៅក្នុងអំឡុងពេលគាត់ លោកគាត់ធ្វើការដ្ឋានការងារទំនប់ត្រពាំងថ្មនោះ ធ្លាប់បានស្តាប់នូវសុន្ទរកថារបស់ ខៀវ សំផន ដែរឬទេ។ ដូចមានទេ? ដូចយើងស្តាប់តាំងតែពីម្សិលមិញ រហូតដល់ម៉ោងនេះមិនមានទេ។ ហើយបើគាត់អត់ដឹងផង តើគាត់មានអ្វីមកវាយតម្លៃលើបញ្ហានេះ ចុងក្រោយនេះបានបើគាត់អត់បានស្តាប់ផង។ បង្ហាញមើលថាតើវាសាក្សីហ្នឹង គាត់ដឹង គាត់ស្តាប់សេចក្តីថ្លែងការណ៍របស់ ខៀវ សំផន ហ្នឹងពីពេលណា? ហើយថ្លែងការណ៍នេះវា គាត់បានទទួលដឹងស្តាប់ហ្នឹង តាមមធ្យោបាយអី?

**លោក គ្រាវីស ហ្វារ៖**

លោកប្រធាន លោក លោកស្រីចៅក្រម អនុញ្ញាតឲ្យខ្ញុំអានសម្រង់សិន បើដូច្នេះ ហើយដើម្បីសួរមើល៍ថា តើគាត់ធ្លាប់ដែលបានឮ ឬក៏អត់?

**កញ្ញា អង់តា ហ្គីសសេះ៖**

ខ្ញុំគិតថាសំណួររបស់សហព្រះរាជអាជ្ញា ប្រហែលជាគាត់សួរថា តើលោកសាក្សីលោកធ្លាប់ស្តាប់ឮសេចក្តីថ្លែងការណ៍របស់លោក ខៀវ សំផន ឬក៏អត់? គាត់ប្រហែលជាសួរបែបហ្នឹងហើយសហព្រះរាជអាជ្ញានោះ។

[១០:០៥:៤៣]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ខ្ញុំគិតថាបញ្ហានឹងអាចទៀងួច ប្រសិនបើលោកប្រធានអនុញ្ញាតឲ្យតំណាងសហព្រះរាជអាជ្ញាអានឃ្លាដែលលោកចង់អាន ហើយសួរទៅសាក្សី ដើម្បីឲ្យឆ្លើយថា តើស្ថានភាពរបស់សាក្សីដែលរស់នៅនាពេលនោះមានលក្ខណៈដូចជាអ្វីដែលលោក ខៀវ សំផន បានលើកឡើងនៅក្នុងសុន្ទរកថាគាត់ដែរឬទេ។ ខ្ញុំគិតថាការសួរបែបនេះ គឺបញ្ជាក់ពីស្ថានភាពជាក់ស្តែងរបស់

សាក្សី ហើយផ្ទុះបញ្ចាំងទៅនឹងសុន្ទរកថារបស់លោក ខៀវ សំផន។ បាទ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងបង្ហាញនូវ ដកស្រង់នូវខ្លឹមសារនៃសេចក្ដីសុន្ទរកថានោះសិន មើល វាយ៉ាងម៉េចទៅ?

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកសាក្សី ខ្ញុំសូមរំឭកលោកបន្តិច គឺថាខ្ញុំនឹងអានសុន្ទរកថាដែល ខៀវ សំផន បានថ្លែង នៅក្នុងខែមេសា ឆ្នាំ១៩៧៧ គាត់បានថ្លែងដូច្នេះ សូមដកស្រង់៖ "កុមារៗរបស់យើង កូនក្មេងរបស់យើងមិនលេងប្រដាប់ប្រដាក្មេងលេង ដូចជាឡាន ទូក និងកាំភ្លើង ដែលពីមុនអស់តម្លៃយ៉ាងច្រើននោះទេ។ ក្មេងៗរបស់យើងសប្បាយនឹងការដេញចាប ឃ្វាលគោក្របី រកជីធម្មជាតិ ជួយកសាងទំនប់ និងខឿនទំនប់ ការពារទឹក ជីកអាងស្តុកទឹក និងប្រឡាយ។" បញ្ចប់ការដកស្រង់។

សំណួររបស់ខ្ញុំ អង្គជំនុំជម្រះអនុញ្ញាត ថាតើសុន្ទរកថារបស់ ខៀវ សំផន នេះជាសុន្ទរកថាមួយបញ្ជាក់អំពីស្ថានភាពការងាររបស់កុមារ ដែលធ្វើនៅការដ្ឋានទំនប់ត្រពាំងថ្ម ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះដែរឬទេ?

[១០:០៧:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធសេចក្ដីជំទាស់ ហើយនិងអនុញ្ញាតឲ្យសាក្សីឆ្លើយតបបានណាសាក្សី! អង្គជំនុំជម្រះក៏ត្រូវការស្ដាប់នូវចម្លើយតបរបស់សាក្សីចំពោះសំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញារងអន្តរជាតិដែរ។

**លោក ស៊ុត សុផល៖**

**ឆ៖** ខ្ញុំដល់ច្រើនអ៊ីចឹង ខ្ញុំស្ដាប់មិនទាន់ ខ្ញុំមិនដឹងដោះសាយ៉ាងម៉េចទេ។ ស្ដាប់មិនទាន់ វែងៗណាស់ពេក។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារងដកស្រង់សាជាថ្មីម្ដងទៀត ហើយឲ្យទំនងខ្លី ហើយច្បាស់បានហើយ

មិនបាច់រៀបរាប់វែងឆ្ងាយទេ ហើយដើម្បីឲ្យគាត់ស្ដាប់យល់ ហើយនិងសួរឲ្យគាត់ឆ្លើយតបអំពីប្រតិកម្មតបរបស់គាត់ ហើយទំនងជាមិនគប្បីប្រើប្រាស់នូវពាក្យថា តើអ្នកឯងយល់យ៉ាងម៉េចនោះទេ? ពាក្យថានេះ គឺវាមានអត្ថន័យលើកកម្ពស់គាត់ទៅជាអ្នកជំនាញ។ បញ្ហាវាអាចខុសក្នុងការប្រើប្រាស់ពាក្យពេចន៍នេះ ក៏ជាអាចជាមូលហេតុមួយដែរ នាំឲ្យមានបញ្ហាចម្រូងចម្រាស។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** ឥឡូវនេះ លោកសាក្សី ខ្ញុំអានសម្រង់សាជាថ្មី ដោយស្រង់តែកន្លែងចំណុចសំខាន់ៗ។ គាត់បានថ្លែងថា សូមដកស្រង់៖ “កូនក្មេងរបស់យើងមិនលេងប្រដាប់ប្រដារក្មេងលេង ដូចជា ឡាន ទូក និងកាំភ្លើង ដែលពីមុននោះនាំឲ្យអស់តម្លៃយ៉ាងច្រើននោះទេ។ ក្មេងៗរបស់យើងសប្បាយនឹងការដេញចាប ឃ្វាលគោក្របី រើសជីធម្មជាតិ ជួយកសាងទំនប់ និងលើកខឿនទំនប់ ការពារ និងជីកប្រឡាយ។” បញ្ចប់ការដកស្រង់។ លោកសាក្សី តើលោកមានប្រតិកម្មយ៉ាងម៉េចដែរ? តើលោកសប្បាយចិត្តទេនៅពេលគេឲ្យលោកទៅធ្វើការលើកទំនប់នៅការដ្ឋានទំនប់ត្រពាំងថ្មនោះ?

**លោក ស៊ុត សុផល៖**

**ឆ៖** មិនដឹងឆ្លើយយ៉ាងម៉េច ឆ្លើយមិនរួច។

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន ខ្ញុំសូមបញ្ចប់ត្រឹមនេះចុះ ដោយសារថាដល់ពេលឈប់សម្រាកហើយ ហើយខ្ញុំក៏បញ្ចប់សំណួររបស់ខ្ញុំត្រឹមនេះផងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះ តទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១១ នាទី ដល់ម៉ោង ១០:៣០ នាទី)*

[១០:៣០:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ ផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ ហើយមានពេល១៥នាទី។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន ដែលផ្ដល់ឱកាសឲ្យខ្ញុំសួរសំណួរទៅសាក្សី។ បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី និងសាធារណជន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** សូមជម្រាបសួលោកសាក្សី ខ្ញុំបាទឈ្មោះ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំចង់ -- ខ្ញុំមានសំណួរមួយចំនួនសម្រាប់រយៈពេល១៥នាទី ដែលនៅសេសសល់នេះ។ ខ្ញុំសូមបន្តពីតំណាងសហព្រះរាជអាជ្ញា ពាក់ព័ន្ធទៅនឹងកាលដែលលោកធ្វើការនៅទំនប់ត្រពាំងថ្ម។ លោកនៅ ពេលធ្វើការនៅត្រពាំងថ្ម លោកជាកុមារ។ តើលោកអាចនិយាយបានទេថា ពេលដែលលោកធ្វើការនៅទំនប់ត្រពាំងថ្ម កាប់ដី ធ្វើទំនប់នៅត្រពាំងថ្មហ្នឹង លោកមានការសប្បាយរីករាយទេ នៅពេលដែលគេឲ្យលោកធ្វើការងារហ្នឹង?

**លោក ស៊ុត សុផល៖**

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ គឺដែលធ្វើការនៅអាងត្រពាំងថ្មហ្នឹងសប្បាយចិត្តម៉េចកើត ឲ្យទៅលូន ឲ្យទៅរែក ឲ្យទៅលី ទៅសែងអីចឹង ធ្វើម៉េចបានសប្បាយចិត្ត? ហូបក៏មិនគ្រប់ អីក៏មិនគ្រប់ម៉េចសប្បាយចិត្តម៉េចកើត?

**ស៖** ឃ្លាដែលជាសុន្ទរកថារបស់លោក ខៀវ សំផន ដែលអានដែលតំណាងសហព្រះរាជអាជ្ញាមុននេះ ដែលនិយាយថា "ក្មេងៗរបស់យើងសប្បាយចិត្តនឹងការដេញចាប ឃ្វាលគោក្របី រើសជីធម្មជាតិ ជួយកសាងទំនប់ និងខឿនទំនប់ការពារ ជីកអាងស្តុកទឹក និងជីកប្រឡាយ"។ ថាតើឃ្លាដែល

និយាយថាលោក -- ដែលក្មេងៗដែលលោកជាកុមារម្នាក់ដែរនោះ សប្បាយរីករាយ និងធ្វើការទាំងអស់នោះ ថាតើគាត់និយាយហ្នឹងត្រឹមត្រូវដែរឬទេ សម្រាប់ស្ថានភាពរបស់លោកហ្នឹង?

[១០:៣៣:១៩]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប! អញ្ជើញមេធាវីការពារក្ដីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះទៅលើពីរចំណុច។ ទី១ ជាប្រភេទសំណួរនាំមុខ, ទី២ សាក្សីរូបនេះក៏មិនអាចនិយាយជំនួសឲ្យក្មេងដទៃទៀតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូលបានទេ។ បាទ សូមអរគុណ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ វាមិនមែនជាអ្វីដែលមិនធ្លាប់ធ្វើទេ ដែលយើងអាន -- ដែលមានការអានឃ្លា ហើយឲ្យសាក្សីនិយាយអំពីស្ថានភាពជាក់ស្ដែងរបស់គាត់។ សាក្សី -- សំណួររបស់ខ្ញុំគឺសួរឲ្យសាក្សីនិយាយអំពីស្ថានភាពជាក់ស្ដែងរបស់គាត់ ហើយនិងកុមារដទៃទៀតដែលគាត់បានឃើញថាតើស្ថានភាពរបស់គាត់ហ្នឹង វាដូចនឹងអ្វីដែលសុន្ទរកថារបស់លោក ខៀវ សំផន បាននិយាយដែរឬទេ។ ខ្ញុំគិតថាវាមិនមែនជាសំណួរដែលមិនអាចធ្វើបានទេ។

**ប្រធានអង្គជំនុំ៖**

លោកតាំងសំណួរម្ដងទៀតមើល៍ វាយ៉ាងម៉េចទៅ? ហើយអ្នក -- សាក្សីពិបាកហ្នឹងឆ្លើយតបណាស់ ព្រោះអំមិញសំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ ឆ្លើយមិនរួចទៅហើយណ៎ះ! អ៊ីចឹងគឺអាចរៀបចំសំណួរថ្មី ធ្វើម៉េចឲ្យគាត់អាចយល់បាន ងាយយល់។ សួរម្ដងទៀត!

**លោក ពេជ អង្គ៖**

**ស៖** ខ្ញុំសូមដកស្រង់ខ្លឹមសារខ្លីតែប៉ុណ្ណោះ។ សុន្ទរកថារបស់លោក ខៀវ សំផន គាត់និយាយថាខ្ញុំសូមលើកតែខ្លឹមសារទេ គាត់ថា៖ "ក្មេងៗរបស់យើងសប្បាយនឹងកិច្ចការងារនានា ដូចជាលើកទំនប់ហើយនិងជីកអាងស្ដុកទឹក"។ បាទ អ៊ីចឹង ឃ្លាដែលគាត់និយាយថា ក្មេងៗហ្នឹងសប្បាយរីករាយនឹងធ្វើការងារអស់ហ្នឹង។ តើស្ថានភាពរបស់លោក ហើយនិងក្មេងៗដែលធ្វើការជាមួយលោកហ្នឹង សប្បាយរីករាយ ដូចដែលលោក ខៀវ សំផន និយាយដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតបនឹងសំណួរនេះ អង្គជំនុំជម្រះក៏ត្រូវការស្ដាប់ចម្លើយតបដែរ។ តាមបទពិសោធន៍របស់លោកបានជួបប្រទះ។

[១០:៣៥:៥៨]

**លោក ស៊ុត សុផល៖**

**ឆ៖** នេះ ខ្ញុំសូមឆ្លើយថា រាល់ដែលគាត់និយាយហ្នឹង គឺខ្ញុំដែលធ្វើហ្នឹង ខ្ញុំមិនសប្បាយចិត្តទេ។ ព្រោះសប្បាយចិត្តម៉េចកើត បើរៀនសូត្រក៏មិនរៀនសូត្រ ទៅឲ្យសប្បាយចិត្តនឹងដេញចាប រែកដី កាប់ដី ទូលដី ហើយទៅសប្បាយចិត្តម៉េចកើត បើសប្បាយចិត្តឲ្យបានរៀនសូត្រហ្នឹងបានសប្បាយចិត្ត បើរវល់តែឲ្យកាប់ដី ជីកប្រឡាយ លើកទំនប់ ទូលដី សក់មិនដុះផង ទៅសប្បាយចិត្តម៉េចកើត។

**ស៖** បាទ សូមអរគុណលោកសាក្សី។ លោកអាចបញ្ជាក់បានទេ ថាតើពេលដែលលោកធ្វើការនៅទំនប់ត្រពាំងថ្ម ខេត្តបាត់ដំបង ឥឡូវបន្ទាយមានជ័យនេះ។ តើពេលនោះ គេមានឲ្យលោករៀនសូត្រអក្សរ ឬក៏លេខអីទេ ក្នុងនាមលោកជាកុមារ ពេលនោះ លោកមានបានរៀនសូត្រអ៊ីចឹងទេ?

**ឆ៖** បាទ ខ្ញុំមិនបានរៀនទេ បើសិនណាបានរៀន បានចេះ។ បើបានរៀន គឺបានរៀនតែកាប់ទន្ទ្រានខែត្រ ដើររើសអាចម៍គោ រៀនរើស រៀនតែលើកដី រៀនតែកាប់ដី អាហ្នឹង រៀន។ បើថារឿងរៀនអក្សរ អត់ដែលមានឲ្យរៀន ឲ្យសូត្រអីទេ។

**ស៖** តើពេលនោះ លោកមានដែលគិតថា លោកចង់រៀនអក្សរ រៀនលេខដែរឬទេ? ចូលសាលារៀន លោកមានដែរ គិតអំពីបញ្ហាហ្នឹងដែរឬទេ?

**ឆ៖** បាទ ពីសម័យហ្នឹង វាបាត់ការចងចាំអស់ហើយ អារឿងរៀន រឿងសូត្រ ព្រោះវាមិនដែលឃើញមានសាលារៀន មិនដែលមានសិស្សរៀន។ សិស្ស មានតែសិស្សទូលអាចម៍គោ សិស្សកាប់ទន្ទ្រានខែត្រ សិស្សលើកទំនប់ អាហ្នឹង មាន បើសាលារៀន អត់មាន។

**ស៖** បាទ សូមអរគុណ។ លោក ខ្ញុំចង់សួរបញ្ជាក់អំពីក្រុមដែលលោកធ្វើការ ឬក៏កងរបស់លោកធ្វើការ។ តើជាក្រុមកុមារ ឬក៏គេហៅថាជាកងកុមារ? ហើយលោកអាចបញ្ជាក់បានទេ កងរបស់លោក ឬក៏ក្រុមរបស់លោកហ្នឹងមានគ្នាប៉ុន្មាននាក់ដែរ កុមារហ្នឹង?

**ឆ៖** បាទ អាហ្នឹងតាមតែការស្មានរបស់ខ្ញុំហ្នឹង វាមានច្រើន កុមារហ្នឹងវាមានប្រហែលជាការស្មានហ្នឹង ប្រហែលជាខ្ទង់ ប្រហែលជា១០០០ ឬទៅ ២០០០នាក់ ប៉ុន្តែមិនដឹងគេយកពីណាមកខ្លះៗ

មិនដឹងទេ ប៉ុន្តែបើយើង វាដកចេញពីភូមិមក ដូចថា វារើសយកអ្នកធំៗ អ្នកដែលល្មមធ្វើការកើត រែក កើត អីកើត ដែលយកមកកន្លែងអាងត្រពាំងថ្មហ្នឹង។

[១០:៣៨:៥៧]

**ស៖** កុមារដែលលោកនិយាយថា ១០០០ ទៅ២០០០នាក់ហ្នឹង លោកអាចបញ្ជាក់បានទេ លោកសំដៅទៅលើកុមារដែលមានអាយុពីប៉ុន្មានឆ្នាំ ទៅប៉ុន្មានឆ្នាំ? ទាបប៉ុន្មានឆ្នាំ? ខ្ពស់ប៉ុន្មានឆ្នាំ?

**ឆ៖** បាទ អង្កាល់ហ្នឹង គេជ្រើសរើសចាប់ពីអាយុ១៤ឡើងទៅ ហើយមិនដឹងទៅទល់គ្នានឹងប៉ុន្មាន ខ្ញុំមិនដឹងទេ ព្រោះខ្ញុំអង្កាល់ហ្នឹង ខ្ញុំប្រាប់គេទៅ ខ្ញុំថាអាយុ១៤ឆ្នាំ។ ទៅក៏គេសួរយើងថាអាយុប៉ុន្មានប្អូនឯង? ខ្ញុំថា១៤ឆ្នាំ។ អើ ១៤ឆ្នាំ ល្មមទៅធ្វើការ ឆ្ងាយពីឪពុកម្ដាយបានហើយ។ ហើយក៏គេបញ្ជូនខ្ញុំទៅអាងត្រពាំងថ្មហ្នឹងទៅ។

**ស៖** ខ្ញុំសូមបញ្ជាក់អំពីបញ្ហាហ្នឹងបន្តិច ដែលលោកនិយាយថា រហូតដល់១០០០, ២០០០នាក់ហ្នឹង អ្នកសុទ្ធតែជាកុមារ។ អ៊ីចឹង លោកអាចនិយាយបញ្ជាក់បានទេ កុមារដែលលោកនិយាយក្នុងចំណោម១០០០, ២០០០នាក់ហ្នឹង អ្នកដែលមានអាយុច្រើនជាងគេបំផុត អាយុប៉ុន្មាន?

**ឆ៖** ដែលគេយកទៅ ដូចខ្ញុំប្រាប់ថា គេចាប់យកពីអាយុ១៤ឆ្នាំទៅ រហូតទៅទល់គ្នានឹងអាយុ ១៥, ១៦, ១៧ អ៊ីចឹងទៅ អាហ្នឹងចាប់ពី១៧, ១៨អ៊ីចឹងទៅ អាហ្នឹងគេចូលទៅពួក គេហៅកុមារពិសេសស្អីគេនោះ។ អាពួកកុមារពិសេសហ្នឹង អាហ្នឹងគេសម្រាប់កាប់ដី គេតម្រង់ជួរគ្នា គេលើកពីមួយបោះពីមួយបោះ លើកដីដុំយើងកាប់ប៉ុណ្ណឹង គេបោះដាក់បាតទំនប់ដែលវានៅទាប គេមិនទាន់រែកឡើងទេ។ អាហ្នឹងគេមានកម្លាំងកាប់ គេមានកម្លាំងទប់ សម្រាប់គេបោះដីទៅឲ្យនោះ។ គេតម្រង់ជួរ ពីរជួរ មួយបោះទៅមួយៗអ៊ីចឹងទៅ។

**ស៖** លោកបានឆ្លើយជាមួយនឹងតំណាងសហព្រះរាជអាជ្ញាអំពីការប្រវត្តិរូបដែលលោកនិយាយថា មិនដឹងអំពី -- មិនមានការធ្វើប្រវត្តិអីទេ។ តើលោកនិយាយថាការមិនមានធ្វើប្រវត្តិរូប លោកនិយាយសំដៅទៅលើអ្នកដែលលោកអាចបានដឹងនៅក្នុងកងរបស់លោក ឬក៏លោកសំដៅទៅលើទាំងអស់គ្នាតែម្ដងនៅទំនប់ត្រពាំងថ្មហ្នឹង? សូមបញ្ជាក់រឿងហ្នឹងតិច?

[១០:៤១:៣៩]

**ឆ៖** បាទ អាហ្នឹងគេអត់មានធ្វើប្រវត្តិរូបទេ គេសួរយើងផ្ទាល់តែម្ដង។ សួររួចគេថាយើងអាយុប៉ុន្មាន? ខ្ញុំប្រាប់គេថាអាយុ១៤។ ១៤ហ្នឹងគេទាញយើងទៅដាក់កន្លែង១៤ អត់ដែលមានក្រដាស មាន

សៀវភៅអីគេយកមកកត់ មកសរសេរអីហ្នឹងអត់ដែលមានទេ។ គេសួរយើងអ៊ីចឹង តែសួរនោះមួយទៀតទៅ ថាអាយុប៉ុន្មានអ្វែង? ថាខ្ញុំ១៤ឆ្នាំ ឬក៏១៥ឆ្នាំហ្នឹងទៅ។ ចាប់ពី១៤, ១៥ ហ្នឹងទៅអាហ្នឹងគេយកទៅមួយកន្លែងអ៊ីចឹងទៅ ប៉ុន្តែមិនដឹងគេយកពីណាពីណីមក យើងអត់ដឹង ព្រោះខ្ញុំដឹងៗតែខ្លួនឯងហ្នឹង។ ព្រោះមនុស្សវាច្រើន ដល់ច្រើនដឹងស្គាល់គ្នាម៉េចអស់ អានេះខ្លះ អានោះខ្លះ ដល់យើងនៅបានយូរតិចទៅបានស្គាល់គ្នា។

**ស៖** បាទ សូមអរគុណ។ លោកបាននិយាយអំពីការប្រជុំដែលមានជាមួយនឹង តាវ៉ាល់។ តើលោកអាចបញ្ជាក់បានទេ តើលោកមានធ្លាប់ប្រជុំជាប្រចាំ ជាសប្តាហ៍ រាល់អាទិត្យ ឬក៏ថារាល់ខែអីជាមួយអ្នកផ្សេងទៀត ផ្សេងពី តាវ៉ាល់ ដែរឬទេ?

**ឆ៖** បាទ ពេលប្រជុំហ្នឹងគឺមានមេហ្នឹង មិនដែលឮមានពីណាផង ឮតែឈ្មោះថា តាវ៉ាល់ៗ ប៉ុនមិនដឹងមុខគាត់ម៉េច។ ពេលប្រជុំក៏គេនិយាយ ប៉ុន្តែយើងមិនដែលសួរយកចិត្តទុកដាក់ថាស្តាប់ផងបន់ឲ្យតែគេសម្រាកផង--

**ស៖** បាទ ខ្ញុំសូមកាត់លោកដោយសារខ្ញុំមានពេលតិចតួចណាស់។ លោកមានធ្លាប់ប្រជុំជាក្រុម ជាកងទេ? មានគេហៅលោកទៅប្រជុំជាក្រុម ជាកងទេ?

[១០:៤៣:១៩]

**ឆ៖** ដល់ប្រជុំជាក្រុម ជាកងហ្នឹងគេមិនដែលហៅយើងទៅទេ យើងប្រជុំនៅកន្លែងធ្វើការ អត់ដែលហៅទៅឆ្ងាយពីកន្លែងធ្វើការអត់ដែលមានទេ គេប្រជុំប្រហែលជាកន្លះម៉ោង ឬក៏មួយម៉ោងអ៊ីចឹងទៅ ពេលដែលមុនបាយ ឬក៏បាយហើយអ៊ីចឹងទៅ។ ពេលដែលគេសម្រាក គេប្រជុំក្រុម។

**ស៖** បាទ ប្រជុំក្រុមហ្នឹង តើគេនិយាយអំពីអ្វីខ្លះ? លោកអាចមាននៅចាំអ្វីដែលគេបាននិយាយឲ្យលោកស្តាប់ទេ? ហើយប្រជុំហ្នឹងញឹកញាប់ដែរឬទេ?

**ឆ៖** បាទ ប្រជុំហ្នឹងជួនកាលនៅពីរថ្ងៃគេប្រជុំម្តងទៅ គ្មានអីនិយាយអី និយាយឲ្យយើងប្តេជ្ញាៗធ្វើម៉េចសម្រេចផែនការរបស់អង្គការហ្នឹង។ មាននិយាយអីច្រើន និយាយតែប៉ុណ្ណឹងឯង។

**ស៖** បាទអរគុណ។ ខ្ញុំសូមសួរបន្ថែមបន្តិច រឿងលោកស្នាក់នៅៗត្រពាំងថ្មពេលដែលលោកធ្វើការហ្នឹង ថាតើលោកស្នាក់នៅយ៉ាងម៉េច មានគ្រែ មានមុង ភួយអី ត្រឹមត្រូវសម្រាប់លោកសម្រាកដែរឬទេ? លោកដេកពេលយប់មានទេ មានគ្រប់គ្រាន់ទេ?

**ឆ៖** អត់ កន្លែងដេកហ្នឹងវា គេធ្វើផ្ទះឲ្យដេក ប៉ុន្តែវាមិនដែលមានមុង មានភួយ មានខ្នើយ អត់

ដែលមានទេ។ គ្រាន់តែដេកមាន គេធ្វើប្រក់ជាស្បូវ អាខ្លះប្រក់ជាស័ង្កសី គេធ្វើជារោងវែងៗ មួយកន្លែងហ្នឹង គេសម្រាកបានរាប់រយ រាប់ បីបួនរយនាក់ គេធ្វើពីរជាន់ គេធ្វើដូចជាកន្លែងដាក់ហាលត្រឡាច។ ពេលយើងដេកទៅ ស្រីដេកមួយចំហៀងអីចឹងទៅ ប្រុសដេកមួយចំហៀងអីចឹងទៅ ប៉ុន្តែពេលដេកហ្នឹងខ្លី។ ដេកពីម៉ោងមួយដណ្តប់មកទាល់គ្នាម៉ោងបីព្រឹក មានដេកអី ជួនកាល បើអ្នកមិនដេកដូចសព្វថ្ងៃដេកមិនបានលក់ផង ដល់ម៉ោងធ្វើការទៀតហើយ។

**ស៖** តើការសម្រាករបស់លោកដេក ដែលដេកហ្នឹង គ្រប់គ្រាន់សម្រាប់ឲ្យលោកមានកម្លាំងធ្វើការដែរឬទេ?

**ឆ៖** បាទ មិនគ្រប់គ្រាន់ទេ។

**ស៖** លោកបាននិយាយអំពីលោកកាប់ដី ហើយលោកដេកនៅលើជាមួយចបកាប់តែម្តង។ តើញឹកញាប់ទេដែលលោកលង់លក់នៅកន្លែងកាប់ដីតែម្តង?

**ឆ៖** បាទ អាហ្នឹងប្រចាំថ្ងៃ រឿងដេកនឹងដងចបហ្នឹងគឺដេករាល់ថ្ងៃតែម្តង ឲ្យតែពេលធ្វើការ។

**ស៖** ពេលដែលលោកដេកនៅដងចបហ្នឹង អាច លោកអាចនិយាយបានទេ ដេកមួយថ្ងៃ លោកដេកប្រហែលជារយៈពេលប៉ុន្មានម៉ោង? ហើយមួយពេលដែលដេកហ្នឹងគឺបានប៉ុន្មាននាទី? លោកអាចនិយាយបានទេ?

**ឆ៖** បាទ ហ្នឹងស៊ីសងទៅលើអ្នករែកដីឡើងទៅលើទំនប់។ បើគេឆាប់បានមកវិញ គេដាស់យើង យើងងើបកាប់ទៅ។ ហើយបើគេទៅយូរ ក៏យើងលួចដេកបានយូរបន្តិចដែរទៅ។

**ស៖** ខ្ញុំនៅសល់បីសំណួរទៀតសម្រាប់សួរទៅលោក។ លោកអាចបញ្ជាក់បានទេ ថាតើលោកមួយរយៈពេលដែលលោកធ្វើការនៅត្រពាំងថ្មហ្នឹង លោកកាប់ដីរហូត ឬក៏ថាមានពេលខ្លះលោករែកដីដែរ?

**ឆ៖** បាទ ហ្នឹងគឺវិលជុំ។ ថ្ងៃនេះខ្ញុំកាប់ទៅ ស្អែកឡើងខ្ញុំទៅរែកទៅ ខាងស្អែកឡើងក៏គេកាប់ម្តងទៅ កាប់ហ្នឹងវិលជុំ។

[១០:៤៧:៤៥]

**ស៖** បាទ អរគុណ។ លោកអាចបញ្ជាក់ថែមទៀតបានទេ លោកដែលបានឃើញដែលអ្នកដែលគេសម្លាប់កប់នៅបាតទំនប់ហ្នឹង លោកឃើញពីចម្ងាយប៉ុន្មានពីកន្លែងដែលគេសម្លាប់កប់ដាក់នៅបាតទំនប់ហ្នឹង?

**ឆ៖** ហ្នឹងដែលខ្ញុំឃើញ ប៉ះថ្ងៃវេនដែលត្រូវថ្ងៃខ្ញុំរែកហ្នឹងគឺចម្ងាយវា យើងរែកពីជើងទំនប់ទៅប្រហែលជា ៥០ម៉ែត្រ ឬក៏៤០ម៉ែត្រ។

**ស៖** លោកឃើញនឹងផ្ទាល់ភ្នែកលោកតែម្តង ឬក៏យ៉ាងម៉េច? ឃើញការសម្លាប់ហ្នឹងផ្ទាល់ភ្នែកលោកតែម្តង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ឃើញផ្ទាល់នឹងភ្នែកហើយ ចង់គាំងបេះដូងរែកដីឡើងមិនរួចទៀត វាភ័យ។

**ស៖** តើអ្នកដែលគេសម្លាប់ហ្នឹង គាត់ជាមនុស្សស្រី ឬក៏ប្រុស? លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ មនុស្សស្រីគេមិនដែលសម្លាប់ទេ ព្រោះមនុស្សស្រីគេអ្នកបញ្ជា។ ប្រធានគេបីនាក់ហ្នឹង គឺមានមនុស្សស្រីហ្នឹងជាប្រធាន។

[១០:៤៩:១៩]

**ស៖** បាទ សុំៗកាត់បន្តិច។ អ្នកដែលត្រូវគេសម្លាប់ ជនរងគ្រោះដែលគេសម្លាប់គាត់នោះ គាត់ជាមនុស្សស្រី ឬជាមនុស្សប្រុស?

**ឆ៖** បាទ មនុស្សប្រុស។

**ស៖** បាទ អរគុណ។ សំណួរចុងក្រោយរបស់ខ្ញុំ។ នៅពេលដែលលោកបរិភោគមិនឆ្អែត ឬក៏ត្រូវគេកាត់បន្ថយចំណីអាហារ ថាតើលោកមានបានរកអ្វីផ្សេងដើម្បីមកបំពេញក្រពះកុំឲ្យ បាត់ហេវឃ្លានហ្នឹងដែរឬទេ? ហើយលោកបរិភោគអ្វីប្រសិនបើលោករកស្អីផ្សេងមកបំពេញហ្នឹង ស្អីគេរបស់ហ្នឹង?

**ឆ៖** អត់មានទេអារឿងរកបំពេញអត់មានទេ មានតែគោលរបបគេឲ្យប៉ុនណា គឺប៉ុណ្ណឹងឯងហើយកន្ទុយភ្នែកយើងរកមើលតែអាក្បែរៗខ្លួនក្រែងមានស្អីដែលវាត្រូវហូបកើត ដូចជា សម្បកដំឡូងចុងដំឡូងដុតដែលគេយកមកបោះក្បែរៗហ្នឹង រើសអាហ្នឹងស៊ី បើគេឃើញគេវាយចោលទៀត បើយើងរើសហើយលួចលាក់ យកជើងឆ្កឹះៗមកជាន់ទុកសិនទៅ មើលនាយមើលអាយ កន្ទុយភ្នែកលិច កើតទៅមើលតែគេទៅផុត រើសរឹប ដាក់ក្ដាប់ទុកស្រេច--

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកសាក្សី លោកបាននិយាយអំពីបញ្ហានេះហើយ ខ្ញុំមិនសួរលម្អិតរឿងបញ្ហាដំឡូងហ្នឹងទៀតទេ។ សូមអរគុណលោកសាក្សី សូមអរគុណលោកប្រធាន ចំពោះការផ្ដល់ឱកាសនេះឲ្យខ្ញុំសួរនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ ទំនងជាចៅក្រមមានសំណួរសួរសាក្សីរូបនេះ។ សូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

[១០:៥១:២១]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** លោកសាក្សីសំណួរដំបូងរបស់ខ្ញុំគឺ ខ្ញុំចង់ឲ្យជួយខ្ញុំដើម្បីស្វែងយល់អំពីចំនួន ខ្ញុំដឹងថាលោកមិនចេះសរសេរ មិនចេះអានទេ ប៉ុន្តែសព្វថ្ងៃនេះលោកអាចរាប់លេខបាន។ តើត្រឹមត្រូវដែរទេ?

**លោក ស៊ុត សុផល៖**

**ឆ៖** បាទ រាប់បានហ្នឹងលេខ ចំនួន មួយ ពីរ បី បួន ប្រាំ រាប់បានតើ។

**ស៖** អ៊ីចឹងរាប់ពីក្រោមទៅលើនេះ ពីមួយទៅហ្នឹង គឺថាលោករាប់ដល់ប៉ុន្មាន ដល់ប្រាំ ដល់១០ ដល់១០០ ដល់២០០ អ៊ីចឹងឬយ៉ាងណា?

**ឆ៖** ច្រើនណាស់ពេក ខ្ញុំរាប់មិនត្រូវទេ។ រាប់បានត្រឹម២០ ឬ៣០អី ច្រើនមិនចេះរាប់ទេ។

**ស៖** ដូច្នេះ ខ្ញុំគិតថាលោកមិនអាចបូក -- មិនអាចគណនាលេខបានទេ គឺថាលោកមិនអាចបូក ដក គុណ បានទេ។ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ។

**ស៖** ឥឡូវខ្ញុំបានកត់សម្គាល់ឃើញថាការរាប់លេខខ្ពស់ទៅៗ គឺថាៗលោកអាចរាប់បានត្រួសៗទេ ឧទាហរណ៍ថានៅពេលដែលគេសួរថា តើមានកុមារប៉ុន្មាននាក់ដែរនៅការដ្ឋានលើកទំនប់ លោកអាចឆ្លើយ១០០០, ២០០០ ឬក៏៣០០០នាក់។ ដូច្នេះ សំណួររបស់ខ្ញុំ តើចំនួនដែលលោកបានឆ្លើយនេះ ថាលោកជា លោកគណនា ឬក៏លោកប្រើប្រាស់មធ្យោបាយណាផ្សេងដើម្បីបញ្ជាក់ពីចំនួនថា១០០០, ២០០០, ៣០០០ នេះ?

[១០:៥៣:៥៦]

**ឆ៖** បាទ អាហ្នឹងជាក់ស្តែង ដែលខ្ញុំមើលទៅឃើញមនុស្សវាច្រើនៗ វាខាប់ អ៊ូ! ចៀស បុកគ្នា

វាច្រើនៗពេក ហើយដល់ច្រើនពេកទៅ វាមិនអាចរាប់អស់ទេ។ ការដែលស្មានរបស់ខ្ញុំ គឺថា គ្មានស្អី ច្រើនជាងពាន់ ជាងម៉ឺនទេ មានតែវាមនុស្សហ្នឹងវាច្រើនស្មើនឹងហ្នឹងឯង។ វាច្រើនណាស់មនុស្សលើក ទំនប់។

**ស៖** ខ្ញុំយល់ហើយ ក៏ប៉ុន្តែសំណួររបស់ខ្ញុំសួរថា ពេលដែលសួរអំពីកុមារៗ នៅពេលមួយនោះ លោកឆ្លើយថា មានដល់ពាន់នាក់ មានពេលមួយនោះលោកឆ្លើយថា ២០០០នាក់ ហើយពេលមួយនោះ ឆ្លើយថា ៣០០០នាក់។ តើលោករាប់ចំនួននេះតាមលំដាប់លំដោយអ៊ីចឹង ឬក៏លោកគិតថាចំនួនហ្នឹង គឺវា មានចំនួនប៉ុណ្ណឹងនៅការដ្ឋាននោះ?

[១០:៥៥:០០]

**ឆ៖** បាទ អាហ្នឹងតាមខ្ញុំស្មានមើលទៅ ថាមនុស្សហ្នឹងវាច្រើន។ ដល់តែច្រើនមានពេលឯណា បានដើររាប់ បានខ្ញុំថាវាច្រើនហ្នឹងវាច្រើនពេក មិនមែនមានមនុស្សតែប្អូន ១០ ឬ២០នាក់ឯណា មនុស្ស ហ្នឹងមើលទៅត្រង់ណាក៏មនុស្ស ត្រង់ណាក៏មនុស្ស។ ដល់វាច្រើនអ៊ីចឹងទៅខ្ញុំស្មានថាអ៊ីចឹងទៅ។

**ស៖** ខ្ញុំយល់ហើយ ឥឡូវហ្នឹងខ្ញុំសូមចូលទៅប្រធានបទមួយផ្សេងទៀត ប៉ុន្តែខ្ញុំសូមរំឭកថា បើសិនជាលោកមិនចាំ លោកឆ្លើយថាមិនចាំ។ តើលោកនៅឯការដ្ឋានលើកទំនប់ហ្នឹង អស់រយៈពេល ប៉ុន្មាន?

**ឆ៖** បាទ ពីសម័យហ្នឹងវាយូរហើយ មិនដឹងថាវាប៉ុន្មាន ប៉ុន្តែនៅហ្នឹងរៀងយូរដែរ។ នៅយូរ លើកទំនប់ឡើងឆ្ងាយដែរហ្នឹងណា ប៉ុន្តែវាមិនដឹងប៉ុន្មានខែ មិនដឹងប៉ុន្មានឆ្នាំទៅទំនប់ហ្នឹង ខ្ញុំមិនដឹងដែរ ប៉ុន្តែធ្វើហ្នឹងវាយូរដែរ រយៈពេលយូរ។

**ស៖** បើខ្ញុំស្តាប់លោកមិនច្រឡំទេ លោកថាលោកធ្វើ បានធ្វើការនៅទីនោះអាចដល់រាប់ឆ្នាំឯ ណោះ។ តើត្រឹមត្រូវដែរទេ?

**ឆ៖** បាទ អាហ្នឹង ស្មានរបស់ខ្ញុំអ៊ីចឹងហើយ ព្រោះវាធ្វើហ្នឹងវាយូរៗៗដែរ។ មិនដឹងជាប៉ុន្មានខែ មិនដឹងជាប៉ុន្មានឆ្នាំ រហូតថ្នាក់ដល់លួចរត់ហើយ វាស៊ូមិនបាន។

**ស៖** ខ្ញុំយល់ហើយ ឥឡូវទុកចំនួនតួលេខមួយអន្លើសិនចុះ។ លោកចាំទេ លោកធ្វើការនៅទីនោះ បានឆ្លងកាត់រដូវវស្សានោះណ៎ា រដូវភ្លៀងបានប៉ុន្មានដង ឆ្លងកាត់រដូវវស្សាបានតែម្តង ឬក៏ធ្វើការនៅ ទីនោះឆ្លងកាត់រដូវភ្លៀង ឬក៏រដូវវស្សាហ្នឹងបានពីរដង លោកចាំសូមលោកឆ្លើយ?

[១០:៥៧:១៥]

**ឆ៖** បាទ ដែលខ្ញុំគេកុមារយកទៅហ្នឹង គេយកទៅធ្វើតែខែ១ដែលអត់មានភ្លៀង បាទ ខែអត់ភ្លៀង។ ដល់ខែដែលភ្លៀងហ្នឹង គេយកមកឲ្យយើងអូសសំណាប ដែលឲ្យគេស្ទូង គេអីហ្នឹង។ ខែភ្លៀង គេអត់ឲ្យធ្វើទេ កុមារ គេយកមកអូសសំណាប អូសអី ពេលគេដក គេអីបានហើយហ្នឹង។

[១០:៥៧:៣៩]

**ស៖** តើអ៊ីចឹងលោកចាំទេ លោកធ្វើការនៅទីនោះឆ្លងកាត់រដូវប្រាំងហ្នឹង បានប៉ុន្មានរដូវដែរ?

**ឆ៖** បាទ កម្លាំងដែលពួកខ្ញុំទៅហ្នឹង បានតែមួយរដូវទេ។

**ស៖** ឥឡូវនេះខ្ញុំប្តូរចូលទៅប្រធានបទថ្មីមួយទៀត ខ្ញុំនឹងសួរលោកអំពីការសម្លាប់ដែលតំណាងសហព្រះរាជអាជ្ញាបានសួរទៅលោក លោកថា មានការសម្លាប់មនុស្សនៅការដ្ឋានលើកទំនប់ ហើយការសម្លាប់នៅកន្លែងការដ្ឋានលើកទំនប់នេះ គឺដើម្បីឲ្យអ្នកដទៃបាក់ស្បាតរៀងខ្លាច ហើយលោកថាការសម្លាប់នេះ គឺថាប្រហែលជា ១០ថ្ងៃម្តង។ ប៉ុន្តែ លោកបានឃើញថាការសម្លាប់នៅការដ្ឋាននោះ តែពីរដងទេ។ ដូច្នេះ សំណួររបស់ខ្ញុំថាបើ គឺបើលោកបានឃើញតែពីរដងអ៊ីចឹង ធ្វើម៉េចបានលោកឆ្លើយថាការសម្លាប់ហ្នឹង គឺគេសម្លាប់រៀងរាល់ ១០ថ្ងៃម្តង?

**ឆ៖** បាទ ហ្នឹង គឺដែលខ្ញុំឃើញហ្នឹង គឺឃើញដូចថា អាហ្នឹងស្មានរបស់ខ្ញុំ ខ្ញុំថា មុនដំបូងអ៊ីចឹងគេយកមកវាយមួយអ៊ីចឹងទៅ យើងរែកដីចាក់អ៊ីចឹងទៅ ហើយយូរបន្តិចទៅ ឃើញគេយកមួយទៀតយកមកដាក់ហ្នឹងទៀតហើយ។ ពេលដែលខ្ញុំឃើញ១ ពីរដងហ្នឹងឯង។ ប៉ុន្តែអាហ្នឹងវាទៀងទាត់ ព្រោះខ្ញុំស្មានហ្នឹងថាប្រហែលជា ១០ថ្ងៃ ឬ ៥ថ្ងៃ ដឹងតែឃើញមួយហើយ– ១០ថ្ងៃ ឬ ៥ថ្ងៃ ឃើញមួយហើយ។ ដល់ពេលខ្ញុំដកទៅបានអាហ្នឹងមិនដឹងជាយ៉ាងម៉េចទៅទៀតក៏ខ្ញុំអត់ដឹងដែរ ខ្ញុំយក ខ្ញុំចេញទៅហើយហ្នឹង។

**ស៖** ឥឡូវខ្ញុំសូមសួរបញ្ជាក់ដើម្បីយល់ឲ្យបានច្បាស់។ ចន្លោះពេលដែលគេសម្លាប់មនុស្សពីរនាក់នេះ គឺលោកឃើញសម្លាប់ពីមនុស្សទី១ មកសម្លាប់លើកទី២ គឺ១០ថ្ងៃ ដែលនាំឲ្យលោកសន្និដ្ឋានថាគេសម្លាប់មនុស្សរៀងរាល់១០ថ្ងៃម្តង។ តើនេះ គឺជាមូលដ្ឋាននៃការសន្និដ្ឋានរបស់លោកមែនទេ?

**ឆ៖** បាទ ហ្នឹងជាការពិតហើយបង។

[១១:០០:៣៥]

**ស៖** ឥឡូវនេះខ្ញុំដូរប្រធានបទថ្មីទៀត។ ឥឡូវនេះចូលសួរហេតុការណ៍ដែលលោកបានរៀបរាប់ពីម្សិលមិញថា ប្រជាជនបានដួលសន្លប់នៅឯការដ្ឋានការងារ ហើយមានគេជួយធ្វើចលនាឲ្យដឹងខ្លួនឡើងវិញដែរ ប៉ុន្តែគាត់ស្លាប់ទៅ។ នេះគឺជាអ្វីដែលលោកបានឆ្លើយទៅតំណាងសហព្រះរាជអាជ្ញាកាល

ពីម្សិលមិញ។ ខ្ញុំចង់ដឹង សួរថាតើសាកសពហ្នឹងៗ គេចាត់ចែងរបៀបម៉េចទៅ?

**ឆ៖** បាទ សាកសពហ្នឹង មិនដឹងគេយកទៅណាទេ អ្នកដែលឈឺហ្នឹងគេអត់មានដាក់ទុកហ្នឹងទេ គេយកទៅ អ្នកដែលស្លាប់ហ្នឹង។ ឲ្យតែនៅស្លាប់នៅកន្លែងធ្វើការហ្នឹង គេអត់ដែលយកមកដាក់ទ្រាប់ ឬក៏ដាក់ទប់នឹងទំនប់ អត់មានទេ អាហ្នឹងគេយកទៅ មិនដឹងគេយកទៅដាក់នៅកន្លែង គេទៅកប់ឯណា ក៏យើងអត់ដឹង។

[១១:០១:៤៥]

**ស៖** តើគេយកចេញទៅហ្នឹងតាមរបៀបណាដែរ គេសែងយកទៅ ឬគេដឹករទេះ ឬក៏ប្រើមធ្យោបាយណាដែរ?

**ឆ៖** បាទ អាហ្នឹងគេសែង គេដាក់រែងអាឈើយើង មិនដឹងគេហៅស្អីគេអាហ្នឹង។ សែងឈើគេដាក់កាន់សងខាង មនុស្ស ប្រើមនុស្សពីរនាក់ទេ ដែលគេដាក់លើកសពឡើងទៅ ដែលយកទៅ លើកយកទៅហ្នឹង គេដាក់ឈើ គេរែងឈើប៉ុនៗនេះ ហើយគេដាក់សែងយកទៅៗ មិនដឹងគេយកទៅដាក់ឯណា គេយកទៅទុកឯណា ខ្ញុំម៉េចដឹង ព្រោះសម័យនោះ អត់មានឃើញមានអង្រឹង មានអីផងដាក់សែងនឹងឈើហ្នឹងតែម្តង។

**ស៖** ហើយធ្វើម៉េចបានជាលោកដឹងថាមនុស្សហ្នឹងស្លាប់ ឬក៏អ្នកដែលជួយធ្វើចលនាបេះដូងឲ្យគាត់ហ្នឹង គេសន្និដ្ឋានថា គេសន្មតថាមនុស្សហ្នឹងស្លាប់ហើយ ឬក៏លោកសន្មតដោយខ្លួនឯង? ធ្វើម៉េចបានជាលោកដឹងថាអ្នកនោះស្លាប់?

**ឆ៖** បាទ ចុះអ្នកដែលដួលហ្នឹង អ្នកដែលស្លាប់ហ្នឹង គឺស្លាប់ក្បែរនឹងផ្លូវដែលខ្ញុំរែកដីឡើងទៅលើទំនប់។ ដល់ដួលទៅ មនុស្សដូចថាវាផ្អើលឈូឡូទៅ ខ្ញុំនាំគ្នាមើលទៅ អាខ្លះជួយរឹត អាខ្លះជួយច្របាច់ទៅ ក៏ប៉ុន្តែគ្នាវាមិនរស់ ហើយក៏ស្លាប់ ក៏យើងឃើញដឹងថាស្លាប់ហើយ ក៏ប៉ុន្តែមិនដឹងថាជួយធ្វើម៉េច ហើយមិនបានដែលបានឈរមើលឯណា ឲ្យហួសពីប្រាំនាទី ឬ១០នាទី អត់មានទេ។ គ្រាន់តែយើងអើតមើល ដឹងថាគាត់ឈឺ គាត់ប្រកាច់ គ្រាន់តែជួយបានតែមួយភ្លែត បើថា អ៊ូ! ស្លាប់ហើយៗ យើងទាញបង្កី ទាញអីហ្នឹង ទៅរែកដីធម្មតាវិញទៅ រែកទៅ រែកមកអ៊ីចឹងទៅ ឃើញគេយកស្អីហ្នឹងឯងយកមកដាក់សែងយកទៅបាត់ទៅ។

[១១:០៣:៤៣]

**ស៖** ខ្ញុំមិនបានស្តីបន្ទោសអីលោកនោះទេ គ្រាន់តែថាខ្ញុំសួរលោកដើម្បីព្យាយាមឲ្យយល់ឲ្យបាន

ច្បាស់។ តើអ្នកណាដែលជាអ្នកព្យាយាមជួយគក់ ជួយច្របាច់ ធ្វើចលនាឲ្យដឹងខ្លួនឡើងវិញនេះ?

**ឆ៖** បាទ អ្នកនៅក្នុងកន្លែងធ្វើការហ្នឹងឯង ដែលឃើញដួល មិនប្រកាន់ថាពួកគេ ពួកយើងហ្នឹង អត់មានចេះប្រកាន់ ដល់តែឃើញដួលអ៊ីចឹងទៅ យើងជួយគ្នា មិនមែនពួកគេមកជួយទេ ជួយអាពួកយើងរែកដីហ្នឹងដែលជួយ។ ប៉ុន្តែដល់ជួយច្របាច់ ជួយគក់ ជួយរឹតទៅ ក៏វាមិនជា ហើយដល់ពេលស្លាប់ទៅ យើងទុកហ្នឹងទៅ យើងម៉េចបានទៅមើល។ ដល់តែស្លាប់អ៊ីចឹង វាមានក្រុម មានពួកគេ អាហ្នឹងគេរាយការណ៍ទៅណាតាមពួក តាមក្រុមគេហ្នឹង យើងមិនដឹង ព្រោះវាមិនមែននៅក្នុងក្រុមរបស់ខ្ញុំ ហើយខ្ញុំមិនមែនពួករបស់ខ្ញុំណា។

**ស៖** តើគ្រោះថ្នាក់បែបនេះ ឬក៏ថាដួលសន្លប់ ហើយស្លាប់ហ្នឹងកន្លែងបែបនេះ លោកធ្លាប់បានឃើញប៉ុន្មានដងដែរ?

**ឆ៖** បាទ ឃើញហ្នឹងវាញឹកញាប់ដែរ ក៏ប៉ុន្តែមិនបានជាថារាប់ប៉ុន្មានដងៗ មិនដែលបានរាប់ ប៉ុន្តែដែលតែងឃើញហ្នឹង ជួនកាលមួយថ្ងៃមួយ ជួនកាលមួយថ្ងៃពីរ ជួនកាលក៏សង្គ្រោះបាន ជួនកាលក៏អត់ទៅ។

[១១:០៥:៣៥]

**ស៖** ខ្ញុំដឹងថាលោកមានការលំបាកក្នុងការប្រាប់អំពីតួលេខ គឺចំនួនដងយ៉ាងដូច្នេះ។ លោកបានឃើញមនុស្សដួលសន្លប់ហ្នឹងរាល់ថ្ងៃ ប៉ុន្តែមិនមែនស្លាប់រាល់ថ្ងៃទេ នៅពេលដែលខ្ញុំសួរថា តើលោក បានឃើញហេតុការណ៍បែបនេះប៉ុន្មានដង ហើយលោកថាបានឃើញច្រើនដងដែរ។ ដូច្នេះ សំណួររបស់ខ្ញុំគឺ តើលោកបានឃើញច្រើនជាង១០ដង ឬក៏តិចជាង១០ដង? តើលោកបានជួបប្រទះគ្រោះថ្នាក់ការងារបែបនេះ ច្រើនជាង១០ដង ឬក៏តិចជាង១០ដង។

**ឆ៖** បាទ អានេះប្រហែលជាវា លើសៗពី១០ដង ព្រោះវាសឹងតែរាល់ថ្ងៃទៅហើយ។ មួយថ្ងៃ ជួនកាលពីរនាក់ បីនាក់ ក៏ប៉ុន្តែ ខ្លះស្លាប់ ខ្លះរស់ – ស្លាប់ខ្លះ រស់ខ្លះ។ មនុស្សពីសម័យនោះ បើថានិយាយយូរទៅ ខ្ញុំនឹកឃើញកំសត់ទៀតហើយ។

**ស៖** ខ្ញុំមានចំណាប់អារម្មណ៍តែរឿងពលករដែលដួលសន្លប់ ហើយស្លាប់ទេ។ ចំនួនពលករដែលដួលសន្លប់ និងស្លាប់ គឺថាច្រើនជាង១០ដង។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ដោយសារតែលោកដឹងពីចំនួនតួលេខមិនច្បាស់ ខ្ញុំសូមបញ្ជាក់ម្តងទៀត។ លោកបានឃើញ

ហេតុការណ៍បែបនេះ ច្រើនជាង ១០ដង ឬក៏យ៉ាងណា ចំពោះពលករដែលដួលសន្លប់ ហើយស្លាប់?

**ឆ៖** មើល៍បង សុំសំណួរម្តងទៀតមើល។

**ស៖** ខ្ញុំកំពុងតែព្យាយាមចង់ដឹងថា តើលោកបានឃើញពលករ កម្លាំងការងារដែលធ្វើហ្នឹងដួលសន្លប់ ហើយនិងស្លាប់ ប៉ុន្មានដង។ លោកបានឆ្លើយនឹងសំណួរខ្ញុំមុននេះថា ជាង១០ដង លោកបានឆ្លើយថាអ៊ីចឹង ថាលោកបានឃើញកម្លាំងពលកម្មហ្នឹងគឺថា ដួលសន្លប់ និងស្លាប់ជាង១០ដង។ សំណួររបស់ខ្ញុំ តើលោកពិតជាបានឃើញមនុស្សដួលសន្លប់ និងស្លាប់នៅកន្លែងការដ្ឋានការងារនោះ ច្រើនជាង១០ដងដែរ ឬក៏យ៉ាងណា?

**ឆ៖** ចុះបើស្លាប់ ហើយនិងដួលមែន មិនដឹងឲ្យខ្ញុំឆ្លើយថាម៉េច បើខ្ញុំប្រាប់បីដងទាំងលើកនេះហើយថា ជាការពិតដែលខ្ញុំឃើញ គឺឃើញមែន។ ខ្ញុំមិនដឹងឆ្លើយថាម៉េចទៀតទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណ។ ខ្ញុំអស់សំណួរហើយលោកប្រធាន។

[១១:០៨:៥១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាតទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី។ ដំបូងនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការសួរដេញដោលសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**លោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អរុណសួស្តីលោកសាក្សី។ ខ្ញុំនឹងសួរសំណួរលោកមួយចំនួន ហើយចាប់ផ្តើមសួរលោកទាក់ទងទៅនឹងប្រធានបទចុងក្រោយនិយាយអំពីមនុស្សដួលសន្លប់ ពលករដែលដួលសន្លប់។ លោកបានរៀបរាប់នូវឧទាហរណ៍មួយទាក់ទងទៅនឹងដែលលោកបានក្រឡេកទៅឃើញនោះ តើអ្នកដួលសន្លប់នេះជាអ្នកណា? តើអ្នកដួលសន្លប់នេះ ជាសមាជិកនៅក្នុងកងរបស់លោក ឬក៏ជាសមាជិកនៅក្នុងផ្សេង?

**ឆ៖** បាទ ហ្នឹងនៅកង វាកងធំហ្នឹងជាមួយគ្នា ក៏ប៉ុន្តែគេកងតូចក្រុមហ្នឹង វាបំបែក១ ផ្សេង១

ពីគ្នា មិនមែនសមាជិកនឹងក្រុមជាមួយខ្ញុំដែលធ្វើនោះទេ។

**ស៖** ដូច្នេះបើខ្ញុំនិយាយថាលោកគឺថាមិនស្គាល់មនុស្សនេះដោយផ្ទាល់ទេ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ធ្វើម៉េចបានស្គាល់ បើមនុស្សវាច្រើននៅក្នុងក្រុមហ្នឹង។ មិនដឹងអ្នកណា ពីណើ មួយថ្ងៃៗមិនដែលបានសួរពីឈ្មោះគ្នាឯណា។ គិតតែពីការ គិតតែពីងារហ្នឹង។ ប៉ុនគ្រាន់ថា មុខនេះនៅក្រុមជាមួយខ្ញុំ នៅកងជាមួយខ្ញុំ ប៉ុន្តែមិនដឹងថាឈ្មោះស្អី យើងគ្រាន់តែឃើញមុខ។ ប៉ុន្តែជួនកាលឃើញថ្ងៃនេះទៅ ចំណាំបានតែថ្ងៃនេះ ស្អែកឡើងលែងចំណាំគ្នាបានទៀតហើយ។ ជួនកាលទៅ ប៉ែរទៅជាហើម ប៉ែរទៅជាស្វិត។

**ស៖** បើលោកមិនស្គាល់អ្នកដែលដួលសន្លប់នេះទេ គឺថាលោកគ្រាន់តែបានក្រឡេកទៅឃើញនូវអ្វីដែលបានកើតឡើង។ អ៊ីចឹងធ្វើម៉េចបានលោកដឹងថា មនុស្សហ្នឹងនោះសន្លប់ដោយសារតែការអស់កម្លាំងមែនទែននោះ? ធ្វើម៉េចបានលោកដឹង?

**ឆ៖** បាទ អាហ្នឹងជាការស្មានរបស់ខ្ញុំទេ។ ខ្ញុំថាវាហត់ វាហេវទៅ វាអត់មានកម្លាំងអីធ្វើការ។ គ្នាឈឺហើយ ក៏នៅតែប្រើគ្នាទាំងឈឺនេះទៅៗ ថាទៅៗដល់ថ្នាក់ទន់ជើង ហើយដួល។

[១១:១២:២៧]

**ស៖** តើត្រឹមត្រូវដែរទេ គឺថាលោកមិនបាននិយាយទៅកាន់ពេទ្យ ឬក៏អ្នកសែងមនុស្សនោះទេ។ អ៊ីចឹងការដែលថាមនុស្សនេះដួលសន្លប់ដោយសារអស់កម្លាំងខ្លាំង នេះគឺជាការសន្និដ្ឋានរបស់លោកទេ។ ត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ គ្មានពេទ្យ គ្មានស្អីឯណាគេមកមើលទេ ប៉ុនអាហ្នឹងជាការស្មានរបស់ខ្ញុំមកពីគ្នាហត់ហេវ បានវាដួល។ សម័យហ្នឹងដែលមានពេទ្យណាបានទៅពិនិត្យ ទៅមើលហ្នឹង។

**ស៖** តើលោកកំពុងតែឆ្លើយបញ្ជាក់ថានៅឯការដ្ឋានលើកទំនប់នោះគឺថាមិនមានពេទ្យទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** អ៊ីចឹងបើអ្នកណាម្នាក់ធ្លាក់ខ្លួនឈឺនៅក្នុងកងរបស់លោក ឧទាហរណ៍ថា ធ្លាក់ខ្លួនឈឺនៅពេលព្រឹក ហើយគាត់ប្រាប់ទៅមេកងរបស់លោកថា "ខ្ញុំឈឺហើយ ទៅធ្វើការមិនកើតទេ។" តើមានអ្វីកើតឡើងចំពោះមនុស្សនោះដែរ?

**ឆ៖** បើសិនជាយើងឈឺ យើងមិនដែលមានសិទ្ធិអី បានទៅសុំដល់មេកងធំទេ។ យើងសុំត្រឹម

តែមេពួកទៅ "មេពួកអើយ ថ្ងៃនេះខ្ញុំដូចជាមិនស្រួល"។ ដល់អ៊ីចឹងទៅ ប្រហែលរយៈពេល -- ប៉ុន្តែការងារគេនៅតែឲ្យយើងធ្វើ។ ក្នុងរយៈពេលមួយម៉ោង ឬកន្លះម៉ោងចុងក្រោយមក គេយកថ្នាំមកឲ្យលេបហើយ។ ថ្នាំហ្នឹង ថ្នាំមូលៗ មានថ្នាំសៗ មូលៗខ្មៅៗ វាមិនដឹងជាថ្នាំស្អី។ គេយកមកឲ្យយើងលេបទៅ ជាមិនជាទៅ អាហ្នឹងជារឿងរបស់យើង ការធ្វើការចេះតែធ្វើ លេបចេះតែលេបទៅ។ ជាមិនជាអាហ្នឹងធ្វើម៉េច។

[១១:១៤:៣៦]

**ស៖** តើលោក ឬក៏សមាជិកនៅក្នុងកងរបស់លោក ធ្លាប់បានទៅមន្ទីរពេទ្យនៅជិតៗនោះដែរទេ នៅពេលណាដែលមានអ្នកឈឺ?

**ឆ៖** បាទ កន្លែងមន្ទីរពេទ្យ គឺខ្ញុំមិនដែលឃើញទេ មិនដែលស្គាល់ផង។ មិនដែលមានអ្នកណាបានទៅពេទ្យ ឃើញតែឈឺប្រាប់មេក្រុមនេះ ប្រាប់ពួកគេទៅ គេយកថ្នាំកន្លែងដែលឈឺ -- អ៎! កន្លែងដែលធ្វើការហ្នឹងឯង។ មិនដែលឃើញយកទៅពេទ្យទៅអី អត់ដែលមាន មិនដឹងពេទ្យនៅឯណា។

**ស៖** មនុស្សដែលដួលសន្លប់ដែលលោករៀបរាប់នេះ តើពលករផ្សេងទៀត ពលករជាច្រើននាក់ទៀត បានឃើញដែរទេនៅឯការដ្ឋាននោះ?

**ឆ៖** អាហ្នឹងបើឃើញ ឃើញចង់គ្រប់តែគ្នានោះ ប៉ុន្តែមិនដឹងថាអ្នកណាខ្លះ គេឃើញ ឈ្មោះអីខ្លះគេឃើញ ដូចខ្ញុំប្រាប់ថា ពីសម័យហ្នឹងមិនដែលស្គាល់គ្នា ហើយក៏មិនដែលស្គាល់មុខគ្នាច្បាស់ទេ។ ថ្ងៃនេះស្គាល់ ស្រាប់តែស្អែកឡើងហើមស្លឹង ហើមមនុស្សរស់ មិនមែនហើមមនុស្សស្លាប់ទេ។ ហើមមនុស្សរស់ យើងមិនស្គាល់អី អានេះដូចមិនមែនធ្វើការជាមួយអញម្សិលមិញទេ។ ចុះថ្ងៃនេះក៏ហើមជួនកាល ឃើញថ្ងៃនេះហើម ស្អែកឡើងស្វិត។ អាហ្នឹងវាពិបាក មិនដែលស្គាល់គ្នាឲ្យបានពីរថ្ងៃ បីថ្ងៃឲ្យច្បាស់ ឲ្យដូចយើងសព្វថ្ងៃ "អ្ហូ! អានេះស្អាត អានោះអាក្រក់ មិនដែលមានទេ" អ្នកណាក៏អាក្រក់ដែរសម័យនោះ រកតែចំណាំគ្នាមិនបាន។

[១១:១៦:៣១]

**ស៖** ប្រសិនបើជាលោកឆ្លើយថា ប្រជាជនជាច្រើននៅឯការដ្ឋានទំនប់ត្រពាំងថ្ម ហេតុអ្វីក៏មានតែលោកទេ ដែលឆ្លើយថាបានឃើញការដួលសន្លប់នៅការដ្ឋានទំនប់ត្រពាំងថ្ម។

**លោក ត្រាវីស ហ្វារ៖**

ខ្ញុំសូមជំទាស់លោកប្រធាន។ មេធាវីការពារក្តីសួរទៅសាក្សីឲ្យពន្យល់អំពីភស្តុតាងរបស់សាក្សី

ដទៃទៀត ប៉ុន្តែដោយមិនបានបញ្ជាក់ថា សាក្សីទាំងនោះ -- សាក្សីដែលមិនបានឆ្លើយអ៊ីចឹងជាសាក្សីណា ហើយសាក្សីហ្នឹងធ្វើការនៅត្រង់កន្លែងណាដែរ នៃការដ្ឋានលើកទំនប់នោះ។ ដូច្នេះ សំណួរបែបនេះ គឺថាសំណួរមិនត្រឹមត្រូវទេក្នុងការសួរឲ្យសាក្សីរូបនេះពន្យល់ចំពោះភស្តុតាងរបស់សាក្សីដទៃទៀតនោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន គឺថាយើងបានស្តាប់សាក្សីរូបនេះគ្រប់គ្នាហើយ ប៉ុន្តែមិនមានអ្នកណាសួរ។ ប្រហែលជាកងរបស់គាត់ធ្វើការនៅកន្លែងណាមួយជាក់លាក់ ឬក៏ថារបបការងារសម្រាប់កងគាត់នេះ គឺថាវាធូន់ធូរពេក។ ដូច្នេះ សាក្សីរូបនេះអាចពន្យល់ចំពោះភាពខុសគ្នានេះបាន។

[១១:១៧:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីកត់សម្គាល់របស់សហព្រះរាជអាជ្ញារងអន្តរជាតិត្រឹមត្រូវ។ លោកបង្ហាញហេតុមកបង្ហាញភស្តុតាងនៃសាក្សីដែលបានផ្តល់សក្ខីកម្មពីមុនមក ដើម្បីបញ្ជាក់បញ្ហានេះ។ ទី២ អង្គហេតុដែលពាក់ព័ន្ធជាមួយការដ្ឋានការងារ អំពីផ្នែកដែលកុមារហ្នឹង ដូចជាយើងមិនទាន់ស្តាប់សាក្សី សក្ខីកម្មសាក្សីណាមួយ ដែលជាកុមារពាក់ព័ន្ធនឹងបញ្ហានេះទេ។ ហើយលោកបង្ហាញគេទៅ ជាក់លាក់មួយណាដែលឆ្លើយថាមិនមាន។ បាទ សួរទូលាយពេក គឺអាចពិបាកឆ្លើយ ហើយឆ្លើយក៏អត់មានបានផលប្រយោជន៍អ្វីដែលស្វែងរកការពិតដែរ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ទោះបីថា វាពិបាកក្នុងការបង្ហាញភស្តុតាងដែលមានស្រាប់ដែលបានឆ្លើយជូនតុលាការហើយនោះក៏ដោយ ខ្ញុំសូមបន្តទៅមុខទៀត ទៅចុះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សំណួរលម្អិតតូចទេលោកសាក្សី បើខ្ញុំយល់មិនច្រឡំទេ លោកបានឆ្លើយថានៅពេលដេកនៅពេលយប់នោះ គឺថាលោកអត់មានមុងទេ អ៊ីចឹង ឬក៏យ៉ាងណា?

**លោក ស៊ុត សុផល៖**

**ឆ៖** បាទ ពីសម័យហ្នឹង មិនដែលមានមុងមែន។ បើមិនមានទៅឲ្យខ្ញុំឆ្លើយថា មានម៉េចកើត។

**ស៖** ឥឡូវនេះ ខ្ញុំដកស្រង់ចម្លើយរបស់លោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/7555, ខ្មែរ 00279113, អង់គ្លេស 00293003 និងបារាំង 00338220។ នេះគឺជាអ្វីដែលលោក

បានឆ្លើយ៖ “នៅពេលខ្ញុំរស់នៅទីនោះ គឺថាគេធ្វើរោងវែងឲ្យដេក មានមុង មានភួយ តែគ្មានខ្នើយទេ។” បញ្ចប់ការដកស្រង់។ ដូច្នេះ លោកសាក្សី លោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតប៉ុន្មានឆ្នាំមុននេះថា លោកមានមុង មានភួយ។ អ៊ីចឹងសូមលោកបញ្ជាក់មើល៍ មួយណា លោកមានមុង មានភួយ ឬក៏មិនមានទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប! សូមអញ្ជើញលោក ពេជ អង្គ!

**លោក ពេជ អង្គ៖**

បាទ ខ្ញុំសូមបញ្ជាក់រឿងអ្វីដែលលោក កូប៉េ បានលើកអម្បាញ់អំមិញ ឃ្លាជាភាសាខ្មែរ ចម្លើយរបស់លោកសាក្សីមិនមាននិយាយអំពីមុង ភួយទេ ហើយខ្ញុំសូមអាន៖ “គេធ្វើរោងវែងនៅក្បែរទំនប់ឲ្យដេក ក្នុងមួយរោងដេកគ្នា១០០នាក់ ដោយធ្វើផ្នើរពីរជាន់ ក្នុងមួយជាន់ដេក៥០នាក់។ គេបើកកន្ទេលឲ្យដែរ ពេលទៅណាមកណា យើងស្ពាយតាមខ្លួន។” ដូច្នេះ ខ្ញុំគិតថាមានការនិយាយថាមានមុង គឺមិនមានទេក្នុងអត្ថបទជាភាសាខ្មែរ។ សូមអរគុណលោកប្រធាន។

[១១:២១:២៩]

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រហែលជាខ្ញុំប្រាប់លេខទំព័រទៅ ខ្មែរគឺ 00279114។ បាទ នេះទើបត្រឹមត្រូវ សូមកែតម្រូវ។ ខ្ញុំអានខ្មែរមិនបានទេ ប៉ុន្តែជាភាសាអង់គ្លេសគាត់ឆ្លើយថាអ៊ីចឹងថា “ខ្ញុំដេកនៅទីនោះ គេធ្វើរោងវែងឲ្យដេកមានមុង មានភួយ តែគ្មានខ្នើយទេ”។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតប!

**លោក ស៊ុត សុផល៖**

**ឆ៖** បាទ ខ្ញុំថាភ្លេចអស់ហើយដល់អ៊ីចឹង បាត់ការចងចាំអស់។ វាយូរដែរហើយ។

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅលោក ពេជ អង្គ?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន អ្វីដែល ទំព័រដែលលោក កូប៉េ បានលើកអម្បាញ់មិញ គឺដូចនៅ

ក្នុង -- ដូចដែលក្នុង ERN ដែលលោក កូប៉េ បានលើក គឺមិនពាក់ព័ន្ធទៅនឹងទីកន្លែងត្រពាំងថ្មទេ។ ហើយនៅក្នុងឃ្លានោះ គឺគេនិយាយថា មានមុងមែន ប៉ុន្តែវាមិនពាក់ព័ន្ធទៅនឹងការដ្ឋានត្រពាំងថ្មទេ។ ដូច្នេះ ខ្ញុំគិតថាសំណួរនេះគឺជាសំណួរដែលចាកប្រធាន -- មិនស្ថិតនៅក្នុងផ្នែកនៃសវនាការយើងនេះទេ។ សូមអរគុណលោកប្រធាន។

[១១:២៣:២៨]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ឥឡូវនេះ ខ្ញុំរៀបសំណួរឡើងវិញ។ លោកសាក្សី លោកឆ្លើយថាមិនមានមុងដេកទេ នៅពេញមួយរបបនោះតែម្តង។ ប៉ុន្តែនៅត្រង់ចម្លើយនេះ ប្រហែលជាអាចនៅការដ្ឋានការងារមួយផ្សេង ប៉ុន្តែតែលោកឆ្លើយថា មានមុង មានភួយ។ តើត្រឹមត្រូវដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតប!

**លោក ស៊ុត សុផល៖**

**ឆ៖** មិនដឹងឆ្លើយយ៉ាងម៉េចទៀត រកកន្លែងឆ្លើយមិនឃើញ។

**ស៖** បាទ បើដូច្នេះខ្ញុំបន្តទៅមុខទៀតចុះលោកសាក្សី។ ឥឡូវ ខ្ញុំសួរសំណួរមួយផ្សេងទៀត។ កាលពីម្សិលមិញនិងព្រឹកមិញនេះ លោកបាននិយាយអំពីអ្នកដែលទទួលគ្រប់គ្រងនៅការដ្ឋានទំនប់ត្រពាំងថ្មទាំងមូលតែម្តង គឺ តាវ៉ាល់។ ហើយតំណាងសហព្រះរាជអាជ្ញា កាលពីម្សិលមិញសួរទៅលោកថា តើលោកបានស្គាល់ តើលោកបានដឹងថា តាវ៉ាល់ កាន់មុខតំណែងនេះរហូតឬក៏អត់ ឬក៏ត្រូវមានគេជំនួសគាត់? ហើយលោកឆ្លើយថា៖ “ខ្ញុំមិនដឹងទេ គ្រាន់តែដឹងថាគាត់នៅកាន់ការងារទីនោះរហូតដល់ចុងបញ្ចប់នៃរបបនោះ”។ តើធ្វើដូចម្តេចដែលលោកដឹងថា តាវ៉ាល់ នៅគ្រប់គ្រងនៅទីនោះរហូតដល់ដាច់របបនោះតែម្តង?

[១១:២៥:៣៩]

**ឆ៖** បាទ ចាប់ពីដែលខ្ញុំ មិនដឹងពីឆ្នាំណាទេ គេដកខ្ញុំឲ្យទៅនៅសាលាក្រហម។ ទៅឲ្យជីកស្រះ ដល់តែជីកស្រះទៅ ទៅហ្នឹងក៏ឃើញតាវ៉ាល់។ គឺថា តាវ៉ាល់ ស្រះ – ស្រះតាវ៉ាល់។ ស្រះនៅជាប់ស្រះតាវ៉ាល់ ស្រះតាវ៉ាល់ តែរហូត។ គេថាម្ចាស់ស្រះហ្នឹងឈ្មោះស្រះតាវ៉ាល់ ប៉ុន្តែពួកខ្ញុំអ្នកជីក។ ឮតែឈ្មោះតាវ៉ាល់ៗ តែរហូត ប៉ុន្តែមិនដឹងថារូបរាងគាត់យ៉ាងម៉េច បើគេអ្នកមកប្រាប់ខ្ញុំថា តាវ៉ាល់ឲ្យធ្វើៗ។ ខ្ញុំ

មិនដឹងតាវ៉ាល់ហ្នឹងយ៉ាងម៉េច ខ្ញុំអត់ស្គាល់ដែរ។ ហើយរហូតមកដល់ថ្ងៃ ថ្ងៃដែលយួនចូលមកវ៉ៃហ្នឹង ខ្ញុំក៏រត់បែបបាក់គ្នានៅកន្លែងស្រះ ជីកស្រះហ្នឹងឯង ជីកស្រះមិនទាន់នឹងបានហើយផង ទទួលគេវ៉ៃ យួនវ៉ៃជាមួយ ប៉ុល ពត ហ្នឹងទៅ ក៏បែកបាក់ គេទៅផ្ទះគេ ខ្ញុំទៅរត់ទៅផ្ទះខ្ញុំអ៊ីចឹងទៅ។ បានខ្ញុំសន្និដ្ឋានថា តាវ៉ាល់ ហ្នឹងនៅគ្រប់គ្រងរហូតដល់ថ្ងៃរំដោះហ្នឹងឯង ព្រោះស្រះក៏ស្រះតាវ៉ាល់ ទំនប់ក៏ទំនប់តាវ៉ាល់ ទីណាក៏វ៉ាល់។

[១១:២៧:១១]

**ស៖** តាមការចងចាំរបស់លោក នៅពេលធ្វើការនៅការដ្ឋានលើកទំនប់នោះជាមួយនឹងកងរបស់លោកនោះ។ តើ តាវ៉ាល់ គឺជាមនុស្សម្នាក់ដែលគ្រប់គ្រងនៅការដ្ឋានការងារនោះទាំងមូលតែម្តងឬ?

**ឆ៖** ថាមុខមាត់ តាវ៉ាល់ ខ្ញុំមិនដែលឃើញទេ ប៉ុន្តែដូចថាមេខ្ញុំគាត់ប្រើថា មេយើង មេៗឈ្មោះ តាវ៉ាល់។ អង្កាល់ដែលខ្ញុំទៅជីកស្រះ ក៏ឈ្មោះ វ៉ាល់។ ដល់ខ្ញុំទៅបិទទំនប់ហ្នឹង ពេលគេថាសន្និបាតហ្នឹង គេថា “ថ្ងៃនេះ តាវ៉ាល់មកហើយថ្ងៃនេះ”។ ដល់ទៅបើកជីកស្រះហ្នឹងក៏គេថា ដែលគេធ្វើមុននឹងជីកហ្នឹង គេបើកអីគេថា អង្គមីទ្ទិង អង្គស្អីគេទេ។ ថាថ្ងៃនេះ តាវ៉ាល់មក។ គេបើកអង្គមីទ្ទិងដើម្បីជីកស្រះ។ អ៊ីចឹងបានខ្ញុំសន្និដ្ឋានថាមានតែ តាវ៉ាល់ ហ្នឹងទៀត។

**ស៖** សំណួរនេះប្រហែលជាពិបាកបន្តិចហើយ ប៉ុន្តែតើមានពេលណាមួយនោះ លោកមានចាំដែរទេថានៅពេលធ្វើការនៅការដ្ឋានលើកទំនប់នោះ មេកងដែលធ្លាប់ដែលនិយាយថា ការបញ្ជានេះគឺមិនមែនមកពី តាវ៉ាល់ទេ គឺបញ្ជាពីអ្នកផ្សេង? ឬក៏មេកងរបស់លោកតែងតែប្រាប់ថា រាល់ការបញ្ជាហ្នឹងគឺចេញមកពី តាវ៉ាល់ គ្រប់ពេល?

[១១:២៨:៥៨]

**ឆ៖** បាទ ហ្នឹងពេលអង្គមីទ្ទិង អង្គស្អីហ្នឹង ឮតែឈ្មោះ តាវ៉ាល់ ហ្នឹងឯង មិនដែលឮឈ្មោះពីណាទេ។ ដល់យើងទៅស្តាប់អង្គមីទ្ទិងហ្នឹងទៅ គេថា៖ “អង្គមីទ្ទិងថ្ងៃនេះ តាវ៉ាល់ មកបើកការដ្ឋានជីកស្រះ”។ ហ្នឹងបានខ្ញុំថា អាងត្រពាំងថ្មក៏ តាវ៉ាល់ទៅបើកការដ្ឋាន, ជីកស្រះមួយភូមិមួយហ្នឹងក៏ តាវ៉ាល់។ ហើយស្រះដែលខ្ញុំជីកហ្នឹង ជីកមិនទាន់ហើយទេ គេវ៉ៃគ្នាជាមួយយួនអ៊ីចឹងទៅរត់បែកបាក់គ្នា គេទៅផ្ទះ ខ្ញុំៗក៏ទៅផ្ទះទៅ។ ហើយគាត់ហ្នឹងក៏មិនដឹងជាទៅឯណាទៅឯណី ហើយខ្ញុំមុខមាត់ហ្នឹងក៏មិនដែលឃើញ មិនដឹងមុខមាត់ តាវ៉ាល់ ហ្នឹងយ៉ាងម៉េច ឮតែមេកងប្រាប់ ដែលសន្និបាតហ្នឹងក៏មានមនុស្សច្រើន ក៏យើងមើលម៉េចបានឃើញគេធ្វើជារោងធ្វើជាអី ហើយសន្និបាតគេមិនដែលធ្វើថ្ងៃទេ គេច្រើនធ្វើតែល្ងាចៗ

ព្រលប់ៗ។ គេសន្និបាតចប់អីអ៊ីចឹងទៅ គេមានសិល្បៈឲ្យយើងមើល។ ប៉ុន្តែសិល្បៈគេសម្ដែងមានអី? មានតែរែកដី កាប់ដី។ អត់ដែលមានថា អ៊ូ! វាំរែកអី អត់មានទេ មានតែពីកាប់ដី ជីកប្រឡាយធ្វើស្រែ។

**ស៖** អាចជាសំណួរពិបាកទៀតហើយ ក៏ប៉ុន្តែខ្ញុំត្រូវតែសួរ។ នៅក្នុងបន្ទប់សវនាការនេះ យើងទាំងអស់គ្នាបានដឹងថាការចាប់ផ្ដើមលើកទំនប់ការដ្ឋានទំនប់ត្រពាំងថ្ម គឺនៅក្នុងអំឡុង ខែកុម្ភៈ ១៩៧៧ ហើយយើងក៏បានដឹងផងដែរៗថា មកដល់ខែមិថុនា ឆ្នាំ៧៧ ប្រាំមួយខែក្រោយមកគឺថា បួនប្រាំខែក្រោយមក គឺ តាវ៉ាល់ គឺឈប់នៅទីនោះហើយ។ អ៊ីចឹងសូមលោកបញ្ជាក់មើល លោកធ្វើការនៅឯការដ្ឋាននោះចាប់ពីពេលណាដល់ពេលណា?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! អញ្ជើញលោកមេធាវីពេជ អង្គ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ សំណួរដែលបានលើកនេះមិនត្រឹមត្រូវទេ អ្វីដែល -- ឃ្លាដំបូងគឺជាការសន្និដ្ឋានថាទាំងអស់គ្នានៅទីនេះបានដឹងអំពីពេលវេលានៃការចាប់ផ្ដើមសាងសង់ទំនប់នេះ ខ្ញុំគិតថានេះជាការសន្និដ្ឋានមួយដែលមិនត្រឹមត្រូវ ហើយលោកមេធាវី លោក កូប៉េ គួរតែលើកជាសំអាងឯកសារណាមួយឲ្យច្បាស់លាស់ បញ្ជាក់អំពីពេលវេលានៃការចាប់ផ្ដើមជាជាងការសន្និដ្ឋានថាទាំងអស់គ្នាដឹងអំពីបញ្ហាទាំងអស់នេះ។ សូមអរគុណលោកប្រធាន។

[១១:៣២:០៨]

**លោក វ៉ិចទ័រ កូប៉េ៖**

ការជំទាស់គឺថា ខ្ញុំសន្មតថាទាំងអស់គ្នានៅក្នុងបន្ទប់សវនាការដឹងអំពីការចាប់ផ្ដើមលើកទំនប់នោះ។ ខ្ញុំយល់ឃើញថា មិនមានអ្នកណាអាចជំទាស់បានទេថា ការចាប់ផ្ដើមលើកទំនប់នេះគឺចាប់ផ្ដើមនៅខែកុម្ភៈ ១៩៧៧ ដោយសារដើម្បីនិយាយឲ្យវាត្រឹមត្រូវនេះ អ៊ីចឹងមើលទៅហាក់បីដូចជាសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអត់ដឹងកាលបរិច្ឆេទចាប់ផ្ដើមលើកទំនប់នេះទេ តែយ៉ាងណាក៏ដោយខ្ញុំចាប់រៀបសំណួរខ្ញុំឡើងវិញទៅចុះ ប៉ុន្តែអង្គជំនុំជម្រះគួរអនុញ្ញាតកំណត់កាលបរិច្ឆេទនេះថាគឺការលើកទំនប់នេះចាប់ផ្ដើមនៅខែកុម្ភៈ ដល់ខែមិថុនា ១៩៧៧។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះដូចមិនអនុញ្ញាតឲ្យភាគីតវ៉ា ជំទាស់លើកទី២ ឬក៏បង្ហាញពីគំនិតជំទាស់លើសេចក្ដី

បញ្ចោក់ចុងក្រោយរបស់ភាគីម្ខាងទៀតទេ។ យើងមិនអនុញ្ញាតទេ! ច្បាស់លាស់ហើយ!

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣៤:៥៤]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី វ៉ិចទ័រ កូប៉េ គប្បីកែសម្រួលសំណួររបស់លោកឡើងវិញ។ ហើយសំណួរដែលលោកសួរថាអ្នកទាំងអស់គ្នានៅក្នុងសាលសវនាការនេះ សុទ្ធតែដឹងថាកាលបរិច្ឆេទនៃការលើកទំនប់ត្រពាំងថ្មនោះ ពីពេលណាអីពេលណានោះ វាដូចជាមិនទំនងទេ ហើយមិនត្រឹមត្រូវទេ។ នោះជាការសន្និដ្ឋានរបស់លោកទេ ការដេញដោល គឺមានកាលបរិច្ឆេទហ្នឹងខុសៗគ្នាច្រើន អង្គជំនុំជម្រះមិនទាន់កំណត់ច្បាស់លាស់ថា យកពេលវេលាណាមួយសមស្របនៅឡើយទេ ហើយសំណួរលោក គឺអាចសួរសាក្សីនេះបានផ្ទាល់តែម្តង អំពីការដឹងរបស់គាត់ អំពីការដែលចាប់ផ្តើមកសាងនៅការដ្ឋានទំនប់ត្រពាំងថ្ម ហើយនិងកាលវេលាដែលគាត់ពាក់ព័ន្ធទៅនឹង ចូលរួមទៅលើកទំនប់ត្រពាំងថ្ម អាហ្នឹងគឺជាការសមស្រប ហើយច្បាស់លាស់ហើយ។ លោកបានបង្ហាញខ្លួនឯងហើយថា ជាសំណួរលំបាក ប៉ុន្តែជាសំណួរមួយដែលវាមិនត្រូវសួរដូច្នេះទេ ពីព្រោះសំណួរនេះ គឺលើកទី១ហើយដែលយើងឮថា ប្រើប្រាស់អ្នកទាំងអស់គ្នានៅទីនេះសុទ្ធតែដឹងនោះ គឺវាអត្តនោម័តិខ្លួនឯង ហើយសន្និដ្ឋានខ្លួនឯងទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកចាំទេ លោកចាប់ផ្តើមទៅធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្មហ្នឹង នៅពេលណាដែរ? តើនៅក្នុងឆ្នាំ១៩៧៧ ឬក៏អត់ទេ?

**លោក ស៊ុត សុផល៖**

**ឆ៖** បាទត្រង់ឆ្នាំ ត្រង់ខែ ត្រង់ថ្ងៃហ្នឹង គឺខ្ញុំមិនបានចាំទេ ព្រោះខ្ញុំចាំតែខ្ញុំធ្វើហ្នឹងឯង។ ថ្ងៃខែឆ្នាំហ្នឹង អត់មានចាំមិនដឹងធ្វើឆ្នាំណា ចាប់ផ្តើមធ្វើថ្ងៃណា ឬខែណាហ្នឹងអត់ចាំ គឺចាំច្បាស់ត្រង់ តែខ្ញុំរែកដីហ្នឹងឯង អាហ្នឹងគឺច្បាស់តែម្តង។

[១១:៣៧:០៦]

**ស៖** សំណួរខ្លីមួយទៀត តើលោកចាំទេលោកបានធ្វើការនៅការដ្ឋាននោះប៉ុន្មានខែដែរ អំឡុងពេលលោកចាប់ផ្តើម រហូតដល់លោកឈប់ធ្វើនៅទីនោះ? តើមានរយៈពេលប៉ុន្មានដែរ?

**ឆ៖** បាទ ពេលធ្វើហ្នឹងវាយូរ ប៉ុន្តែមិនដឹងថាប៉ុន្មានខែ ព្រោះខ្ញុំមិនដឹងចាំខែ ចាំថ្ងៃ ព្រោះខ្ញុំធ្វើ

ហ្នឹងវាយូរដែរ បាទ ព្រោះសម័យហ្នឹង មួយខែៗហ្នឹងយូរណាស់ មិនមែនមួយខែលឿនដូចសម័យនេះឯណា មួយខែៗដូច១០ឆ្នាំអ៊ីចឹងឯង។ មិនមែនមកមួយខែ បន្តិចដល់ខែៗដូចសម័យនេះឯណា បើសម័យមុនមួយខែ ដូច១០ឆ្នាំ ហើយក្នុងបីឆ្នាំហ្នឹង ខ្ញុំស្មើតែមួយជីវិត ដូច១០០ឆ្នាំខ្ញុំទៅហើយ ហើយខ្ញុំធ្វើម៉េចចាំបានអស់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះនៅរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅបន្ទប់សវនាការនេះនៅរសៀលនេះ នៅវេលាម៉ោងមួយកន្លះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣៨ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣៣:២៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយតទៅនេះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី ដើម្បីសួរដេញដោលសាក្សី ហើយទំនងជាមិនទាន់ចប់ទេ ហើយប្រគល់ឲ្យទៅសហមេធាវីការពារក្តីលោក នួន ជា។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ បាទ ខ្ញុំនៅមានសំណួរបន្តទៅទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរបន្ថែមខ្លះទៀត ដើម្បីសួរលោកនៅរសៀលនេះ។ ប៉ុន្តែទី១ ខ្ញុំសូមចូលទៅប្រធានបទដែលខ្ញុំបានសួរលោកមុនពេលឈប់សម្រាកពិសាបាយថ្ងៃត្រង់ គឺនិយាយអំពីកម្មករដែលដួលសន្លប់ ហើយត្រូវបានគេជួយធ្វើចលនា ប៉ុន្តែក៏ស្លាប់ទៅ។ តើលោកដឹងទេថាមានអ្នកណាម្នាក់ដែលរស់រានមានជីវិតដល់សព្វថ្ងៃនេះ ធ្លាប់ធ្វើការនៅទីនោះជាមួយលោកបានឃើញព្រឹត្តិការណ៍នេះជាមួយលោក តើលោកមាននៅចាំឈ្មោះអ្នកណាម្នាក់ទេ?

**លោក ស៊ុត សុផល៖**

**ឆ៖** ដល់វាបែកគ្នាពីឆ្នាំ៧៩មក ដូចថាខ្ញុំវាមិនបានចាំ មិនដឹងថាពីណានៅរស់ ពីណាស្លាប់ ព្រោះខ្ញុំក៏មិនដែលបានទៅស្រុក ទៅកន្លែងហ្នឹងទៀតដែរ ព្រោះខ្ញុំនៅតែអន្លង់វែង ខ្ញុំមិនដឹងអ្នកណាងាប់អ្នកណារស់។

[១៣:៣៥:៣១]

**ស៖** ហើយលោកបានឆ្លើយថា ព្រឹត្តិការណ៍បែបនេះបានកើតឡើងជាង១០ដង។ ព្រឹត្តិការណ៍មួយទៀតដែលលោកបានឃើញនោះ តើព្រឹត្តិការណ៍ដទៃៗទៀតដែលលោកបានឃើញ លោកដឹងទេថាពលករដែលដួលសន្លប់ហ្នឹងជាអ្នកណា?

**ឆ៖** បាទ ពលករដែលដួលហ្នឹង គឺខ្ញុំក៏មិនស្គាល់ដែល គ្រាន់តែឃើញគេដួល ប៉ុន្តែមិនស្គាល់ថាពីណា គឺអត់ស្គាល់ទេ។

**ស៖** ប្រហែលមានបញ្ហា ដោយសារការបកប្រែ។ ខ្ញុំមានថា នៅពេលដទៃទៀតនោះ ក៏លោកបានឃើញមនុស្សដួលសន្លប់ដែរ អាចដោយសារតែការងារហួសកម្លាំង នឿយហត់ខ្លាំងពេក។ ព្រឹត្តិការណ៍ទាំងអស់ហ្នឹង លោកថាលោកបានឃើញ។ តើពលករដែលដួលសន្លប់ដោយការអស់កម្លាំងនេះជាអ្នកណាដែរ?

**ឆ៖** បង សុំម្តងទៀត។

**ស៖** មុនពេលឈប់សម្រាកហូបបាយថ្ងៃត្រង់ យើងបាននិយាយគ្នាពីស្ថានភាពដែលពលករដួលសន្លប់ ហើយគេក៏ធ្វើចលនា ព្យាយាមធ្វើចលនា។ លោកថាព្រឹត្តិការណ៍នេះកើតឡើងជាង១០លើក តើព្រឹត្តិការណ៍ជាង១០លើកដែលលោកបានឃើញនេះ តើលោកដឹងថា ពលករដែលដួលសន្លប់ជាង១០លើកនេះជាអ្នកណាដែរ?

**ឆ៖** ខ្ញុំវាមិនបានស្គាល់ឈ្មោះ ហើយនិងក៏មិនស្គាល់មុខ ក៏ប៉ុន្តែគ្រាន់តែឃើញ ឃើញតែដឹងថាដួល ក៏ប៉ុន្តែមិនដឹងថាឈ្មោះអ្វី ឬនៅឯណា ក៏ខ្ញុំមិនដឹង ប៉ុនដឹងតែអ្នកដែលធ្វើការជាមួយគ្នាហ្នឹងឯង។ ឈ្មោះអ្វី ឬក៏មុខមាត់យ៉ាងម៉េច ព្រោះខ្ញុំម៉េចបានហ៊ានចូលទៅមើល បើខ្ញុំគ្រាន់តែឃើញគេដួលពីចម្ងាយអ៊ីចឹង ខ្ញុំអើតមើលទៅឃើញ ក៏ប៉ុន្តែខ្ញុំមានបានទៅមានសិទ្ធិទៅអើតឯណា ព្រោះគេអ្នកធ្វើការហ្នឹងកម្លាំងគ្នាគេតើ ជួយមើល ជួយថែ។ រែកឡើងទៅទៀតទៅ គេសួរថាម៉េច "បានធូរនៅ?" ថា "ធូរណាគាត់ស្លាប់បាត់ហើយ"។ អាហ្នឹងសួរអាគ្នាយើងដែលឡើងបន្តបន្ទាប់ៗនឹងខ្ញុំហ្នឹងណ៎ា។

[១៣:៣៨:៣៧]

**ស៖** តើលោកធ្លាប់បាននិយាយទៅកាន់អ្នកដែលព្យាយាមជួយសង្គ្រោះអ្នកដួលសន្លប់នេះទេ? តើលោកធ្លាប់បាននិយាយទៅកាន់អ្នកដែលគេជួយទៅដល់អ្នកដួលសន្លប់នោះទេ?

**ឆ៖** បាទ ដែលសួរហ្នឹង គឺគ្រាន់តែសួរតគ្នាទេ គ្រាន់តែសួរថា ឃើញអាអ្នកដែលធ្វើការហ្នឹងអាអ្នកព្យាបាលហ្នឹង យើងមិនបានទៅសួរគេទេ សួរអាអ្នកដែលនៅដើរទៅមកៗជុំគ្នាហ្នឹងណ៎ា សួរម៉េចហើយអ្ហ៎? អ្ហ៎!ស្លាប់បាត់ហើយ។ បានទៅសួរផ្ទាល់អាអ្នកដែលចលនាហ្នឹង គឺអត់បានសួរផ្ទាល់ ព្រោះអត់មានពេលទៅសួរគេទេ ព្រោះអាល័យតែរែកដី រែកអីឡើងទៅលើហ្នឹង អ្នកណាហ៊ានទៅសួរគេផ្ទាល់។

**ស៖** ឥឡូវខ្ញុំសូមចូលទៅដល់ការសម្លាប់ដែលលោកថា លោកបានឃើញដោយផ្ទាល់ភ្នែក បើខ្ញុំយល់មិនច្រឡំទេ លោកបានឃើញការសម្លាប់នេះពីរដង។ ម្តងនោះ លោកថាមានបុរសម្នាក់ ត្រូវបានគេសម្លាប់ចោល។ លោកដឹងទេ បុរសម្នាក់ដែលលោកឃើញលើកទី១ដែលគេសម្លាប់នៅទីនោះនុ៎ង ជាអ្នកណាដែរ?

**ឆ៖** ទោះខ្ញុំឃើញ ក៏ប៉ុន្តែខ្ញុំមិនបានស្គាល់ ថាអ្នកហ្នឹងគេយកពីណាមក ឬក៏អ្នកទោសយកពីណាមក អត់ដឹងទេ។ ដឹងថាដែលគេយកមក គឺវាយចោលនៅមុខ ក្បែរៗពួកខ្ញុំធ្វើការហ្នឹងឯង។ វាយរួចគេនឹងប្រាប់ពួកយើង និងអ្នកដែលនៅថា "ពួកឯងប្រឹងធ្វើការ បើមិនធ្វើការទេ ពួកមិត្តឯងសម្លាប់ចោលដូចអាមួយដែលវាយចោលហ្នឹង"។

[១៣:៤១:០០]

**ស៖** តើលោកឃើញបុរសដែលគេសម្លាប់ហ្នឹង សម្លាប់នៅត្រង់កន្លែងណានៃការដ្ឋានលើកទំនប់ហ្នឹង? ហើយលោកធ្វើការនៅត្រង់កន្លែងណានៃការដ្ឋានលើកទំនប់នេះ?

**ធ៖** បាទ ដែលខ្ញុំឃើញនេះ បើតាមដែលខ្ញុំស្មានមើលទៅ ប្រហែលជា២០០ម៉ែត្រពីកែងទិសខាងកើត អ៊ំ! ពីទិសខាងជើងបត់មកលិច។ ប្រហែល ចម្ងាយប្រហែលជា១០០ ឬក៏២០០ម៉ែត្រពីជ្រុង។

**សៈ** តើមានអ្នកណាម្នាក់នៅក្បែរលោក ឬក៏មានមនុស្សច្រើននាក់នៅក្បែរលោក ឃើញការសម្លាប់ដូចដែលលោកឃើញនេះដែរទេ?

[១៣:៤២:០៥]

**ធ៖** បាទ បើឃើញ គឺឃើញទាំងអស់តែគ្នាហ្នឹងហើយ អាអ្នកដែលធ្វើការហ្នឹង អ្នកណាក៏គេឃើញ។ បើឃើញចង់ទូទៅហើយ អ្នកដែលធ្វើការហ្នឹង អ្នកដែលនៅក្បែរៗហ្នឹង។

**សៈ** តើបើខ្ញុំថាមនុស្សរាប់រយនាក់បានឃើញនូវអ្វីដែលលោកបានឃើញ។ ត្រឹមត្រូវដែរឬក៏អត់ទេ?

**ធ៖** បាទ សូមម្តងទៀត បង។

**សៈ** តើវាត្រឹមត្រូវដែរឬក៏អត់ទេលោក បើខ្ញុំនិយាយថា មនុស្សរាប់រយនាក់ ឬក៏រហូតដល់រាប់ពាន់នាក់ បានឃើញការសម្លាប់ដូចលោកបានឃើញដែរនោះ តើអាចថាដូច្នេះបាន ឬក៏មិនបានទេ?

**ធ៖** ពេលដែលឃើញ គឺឃើញច្រើនមែន។ តែបើទាល់តែទៅសួរគេ បើសិនដឹងថា អ្នកនៅរស់ទៅសួរគេ ប៉ុនដល់មិនដឹងថាគេរស់ មិនដឹងថាគេស្លាប់ ដឹងខ្ញុំសួរពីណា។ ដែលសម្លាប់ ដែលស្លាប់ហ្នឹង គឺខ្ញុំឃើញ គឺដឹងតែស្លាប់មែននឹងភ្នែកខ្ញុំ។

**សៈ** ឥឡូវនេះ ខ្ញុំសុំសួរលោកអំពីការសម្លាប់លើកទី២ ដែលលោកបានឃើញលើកទី២។ តើលោកអាចជម្រាបជូនតុលាការបានទេថា ជម្រាបជូននូវអ្វីដែលលោកបានឃើញការសម្លាប់លើកទី២នេះ លោកបានឃើញគេធ្វើដោយរបៀបម៉េច ការសម្លាប់នេះប្រព្រឹត្តទៅដោយរបៀបណា?

[១៣:៤៤:០០]

**ធ៖** បាទ ទី១ និងទី២ហ្នឹង មិនប្លែកៗពីគ្នាទេ ធ្វើដូចតែគ្នា។ ដល់ពេលគេសម្លាប់រួច គេវាយរួចអ៊ីចឹងទៅ គេប្រាប់អ្នកដែលនៅរស់ថា “ពួកមិត្តឯងប្រឹងធ្វើការ” បើសិនតែធ្វើការឲ្យយើងធ្វើមិនបានទេ គេយកទៅវាយចោលទៅទៀត។ ទី១ និងទី២ហ្នឹង អត់ខុសគ្នាទេ ដូចតែគ្នា។

**សៈ** ដូច្នេះលើកទី២នេះ គឺគេសម្លាប់ពលករហ្នឹងតែម្នាក់ដែរទេ តើត្រឹមត្រូវដែរឬទេ?

**ធ៖** បាទ ត្រឹមត្រូវ។ សម្លាប់ម្តងតែម្នាក់ៗហ្នឹង មិនដែលមានយកប្អូនដប់ម្ភៃនាក់ មកវាយតែម្តង អត់មានទេ។ មានតែយកម្តងមួយអ៊ីចឹងទៅ គេធ្វើការសតិអារម្មណ៍យើង។

**ស៖** ហើយការសម្លាប់លើកទី២ ដែលលោកថាលោកបានឃើញផ្ទាល់ភ្នែកដែរនេះ តើលោកស្គាល់អ្នកដែលគេសម្លាប់នេះដែរទេ ជាអ្នកណា ឈ្មោះអីដែរទេ?

**ឆ៖** បាទ ខ្ញុំមិនបានស្គាល់ទេ ប៉ុន្តែគ្រាន់ថាឃើញគេបណ្តើរមកអ៊ីចឹងទៅ គេវ៉ៃអ៊ីចឹងទៅ ងាប់ទៅ។ ហើយបើខ្ញុំនិយាយទៅ ថាខ្ញុំនិយាយដដែល តើងាប់ទៅគេផ្តាំផ្ញើយើង អត់មានថា អញឲ្យមាសអ្វែងប៉ុណ្ណោះ ឲ្យប្រាក់ប៉ុណ្ណោះ អត់មានទេ។ មានតែអ្វែងខំប្រើ មិត្តឯងខំប្រឹងធ្វើការ មិត្តឯងបើមិនធ្វើការទេ វ៉ៃចោល។ ពីរោះៗបំផុតគឺ "វ៉ៃចោល" ហ្នឹងឯង ភាសាដែលពីរោះគេ។

**ស៖** ហើយការសម្លាប់លើកទី២ ដែលលោកបានឃើញនេះ តើមានកម្លាំងពលករផ្សេងទៀតបានឃើញច្រើនទេ បានឃើញច្រើននាក់ទេ?

**ឆ៖** ថាលើកទី១ លើកទី២នេះ វាដូចតែលើកទី១ហ្នឹងឯង ព្រោះអ្នកដែលឃើញ អ្នកដែលធ្វើការហ្នឹង គេឃើញគ្រប់តែគ្នាហ្នឹងឯង។

[១៣:៤៦:៤៣]

**ស៖** ខ្ញុំសូមអានសម្រង់នៃចម្លើយរបស់លោក គឺឯកសារ E3/7755។ លោកប្រធាន ERN គឺ--

**អ្នកបកប្រែ៖**

លោកប្រធានសូមអនុញ្ញាត ឲ្យលោកមេធាវីអានម្តងទៀត លោកប្រធាន។ ញាប់ពេក តាមអត់ទាន់ អម្បាញ់មិញ។

**ប្រធានអង្គជំនុំ៖**

លោក រ៉ិចទ័រ កូប៉េ អានលេខ ERN សាថ្មីម្តងទៀត អ្នកបកប្រែបកអត់បានទេ។ អ្នកបកប្រែបកភាសាអត់ទាន់ទេ លោកលឿនពេក។

**សួរដោយលោក រ៉ិចទ័រ កូប៉េ៖**

**ស៖** ENR ជាភាសាខ្មែរ 00279115 គឺឯកសារ E3/7755, បារាំង 00338221 និងអង់គ្លេស 00293004។ លោកសាក្សីនេះគឺជាចម្លើយរបស់លោកដែលលោកឆ្លើយជូនមន្ត្រីស៊ើបអង្កេត។ លោកឆ្លើយថា៖ "នៅពេលនោះ ខ្ញុំបានឃើញគេវាយមនុស្ស។ គេក៏បានសម្លាប់មនុស្សនៅការដ្ឋានការងារនោះដែរ។ គេចងយកទៅ ខ្ញុំបានឃើញគេវ៉ៃមនុស្សស្លាប់ចោលនៅនឹងកន្លែងរាប់រយនាក់ រួចកប់នៅបាតទំនប់តែម្តង។ ខ្ញុំបានឃើញគេចាប់ចងឡើងលើដោយដាក់ខ្សែរ៉ត ទម្លាក់ចុះឡើងៗពីរបីដង។ មនុស្សភាគច្រើនក្នុងការដ្ឋាន តែងតែបានឃើញឧបករណ៍ធ្វើទណ្ឌកម្មខាងលើ ស្ទើរតែគ្រប់គ្នា។" ឥឡូវខ្ញុំសូមផ្តោត

ទៅលើចំណុចមួយទេ នៅក្នុងចម្លើយរបស់លោកក្នុងកំណត់ហេតុស្តាប់ចម្លើយជូនមន្ត្រីស៊ើបសួរ លោកឆ្លើយថាមានអ្នកដទៃទៀតឃើញរាប់រយ -- គឺថាលោកបានឃើញគេសម្លាប់មនុស្សរាប់រយនាក់។ ឥឡូវលោកថា លោកបានឃើញគេសម្លាប់មនុស្សតែពីរនាក់ទេ។ តើវាត្រឹមត្រូវដែរឬក៏អត់ទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១៣:៤៩:៣០]

**លោក ពេជ អង្គ៖**

បាទ ខ្ញុំសូមបញ្ជាក់បន្តិច ត្រង់ចំណុចដែលបានអាននេះជាភាសាខ្មែរនិយាយថា "ខ្ញុំបានឃើញគេវ៉ៃមនុស្សសម្លាប់ចោលនឹងភ្នែករាប់រយនាក់" មិនមែននៅនឹងកន្លែងទេ គឺ "នឹងភ្នែករាប់រយនាក់ រួចកប់នៅបាតទំនប់តែម្តង"។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

វាខុសពីសំណួរយ៉ាងម៉េចទៅ?

**លោក ពេជ អង្គ៖**

បាទ លោកប្រធាន អម្បាញ់មិញការបកប្រែជាខ្មែរ គឺនិយាយថា "ខ្ញុំឃើញគេវ៉ៃមនុស្សសម្លាប់ចោលនៅនឹងកន្លែងរាប់រយនាក់" តែជាភាសាខ្មែរគេសរសេរថា "ខ្ញុំបានឃើញគេវ៉ៃមនុស្សសម្លាប់ចោលនៅនឹងភ្នែករាប់រយនាក់"។ ឃើញនឹងភ្នែករបស់គាត់ មិនមែននៅនឹងកន្លែងទេ អ្វីដែលជាភាសាខ្មែរ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

វាដូចជាមិនខុសគ្នាប៉ុន្មានទេ ណេះ។ ខ្លឹមសារវាអត់មានផ្ទុយ ឬអត់មានខុសអីសោះ។ សាក្សីឆ្លើយតបនឹងសំណួរចុងក្រោយអម្បាញ់មិញ ដែលសួរឡើងដោយមេធាវីការពារក្តី។

[១៣:៥០:៥១]

**លោក ស៊ុត សុផល៖**

**ឆ៖** បាទ ដែលខ្ញុំឃើញថា ផ្ទាល់ៗនឹងភ្នែកហ្នឹង គឺថា ចុះបើខ្ញុំឃើញហើយ បើខ្ញុំឆ្លើយហើយ វាមិនមែនថានឹងកន្លែងការដ្ឋានហ្នឹងណា៎។ ដូចខ្ញុំ កាលពីខ្ញុំនៅជាមួយឪពុកជាមួយម្តាយខ្ញុំឃើញ ខ្ញុំនៅធ្វើ

ចម្ការនៅក្បែរហ្នឹង ហើយគេយកទៅវ៉ៃ គេស្រែកអាយូអាយ៉ាៗ អាក្បែរៗតាងិល ក្បែរអីហ្នឹង អាហ្នឹងខ្ញុំឆ្លើយអ៊ីចឹង ឆ្លើយ ខ្ញុំឃើញនឹងភ្នែកមែន មិនមែនថានឹងការដ្ឋានត្រពាំងថ្មហ្នឹងឯណា។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំអានចម្លើយរបស់លោក លោកបាននិយាយថា ពេលលោកធ្វើការនៅការដ្ឋាននោះ លោកបានឃើញ ជាឃ្លាខ្មែរតែម្តង គឺថាលោកបានឃើញ គេវ៉ៃមនុស្សសម្លាប់ចោលនៅនឹងភ្នែករាប់រយនាក់ រួចកប់នៅបាតទំនប់តែម្តង។ ឥឡូវនេះលោកឆ្លើយថា ការសម្លាប់នេះគឺថាឃើញនៅកន្លែងផ្សេងទៀត។ តើចម្លើយមួយណាដែលពិតប្រាកដ? តើលោកឃើញការសម្លាប់នឹងភ្នែករាប់រយនាក់ រួចកប់នៅបាតទំនប់ ហើយឥឡូវនេះលោកថាឃើញនៅកន្លែងផ្សេងផង តើចម្លើយមួយណាដែលត្រឹមត្រូវ?

[១៣:៥២:៣៣]

**ឆ៖** ខ្ញុំដូចរកកន្លែងឆ្លើយមិនឃើញ មិនដឹងឆ្លើយថាម៉េច។ បើខ្ញុំប្រាប់ថាឃើញនៅនឹងទំនប់ហ្នឹង ឃើញពីរនាក់ ហើយបើអាក្រៅពីហ្នឹង អាក្បែរៗចម្ការ អង្កាល់ម៉ាក់ខ្ញុំធ្វើចម្ការហ្នឹង វាវ៉ៃ វាស្រែករឡូងរឡាង។

**ស៖** ដូច្នេះដើម្បីបញ្ជាក់ចំណុចនេះឲ្យច្បាស់ គឺថាលោកមិនធ្លាប់បានឃើញគេសម្លាប់មនុស្សដល់រាប់រយនាក់ រួចកប់នៅបាតទំនប់ត្រពាំងថ្មនោះទេ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ អាមនុស្សរាប់រយ ខ្ញុំមិនដែលឃើញទេ ក៏ប៉ុន្តែសម្លាប់តែម្នាក់ពីរនាក់ហ្នឹង ខ្ញុំឃើញច្បាស់នឹងភ្នែក។

**ស៖** ពីខាងដើម លោកក៏បាននិយាយអំពីកងឈ្លប ជាកងឈ្លបដែលនៅដើរចុះដើរឡើងការដ្ឋានការងារ វាយដំពលករ ចាប់ពលករ ភ្ជង់ពលករជាមួយនឹងដាវ។ ឈ្លបដែលលោកបានរៀបរាប់នេះ តើជាឈ្លបដែលសម្លាប់មនុស្សពីរនាក់ដែលលោកបានឃើញនឹងភ្នែកនោះដែរឬទេ?

**ឆ៖** បាទ អ្នកដែលភ្ជង់ហ្នឹង មិនមែនអ្នកសម្លាប់ទេ។ អាអ្នកភ្ជង់ហ្នឹង វាគ្រាន់តែបានដើរមក វាភ្ជង់ វាចាក់ វាអីលេងហ្នឹងណ៎ា។ ហើយអាអ្នកដែលសម្លាប់ហ្នឹង ពេលគេយកមកសម្លាប់ អត់មែនអាពួកហ្នឹងទេ មិនដឹងអាពួកណា មកពីណា ប៉ុន្តែក្មេងៗដូចគ្នា ហើយគ្នាគេមានតែបីនាក់ហ្នឹងឯង។ មានតែស្រីមួយ អ៊ំ! ស្រីមួយ ប្រុសពីរ។ ស្រីហ្នឹងរាងធំ បើប្រុសៗតូចៗ។ ស្រីហ្នឹងគេស្ពាយកាំភ្លើង ដល់អាប្រុសពីរនាក់ហ្នឹង គេកាន់ដាវគេវែង ប្រហែលប្រវែងណេះ។ គេបណ្តើរយកមក ក៏មិនដឹងគេយកពី

កន្លែងណាមក ខ្ញុំអត់ដឹងទេ តែស្រាប់មកដល់គេវ៉ៃទម្លាក់អាក្នុងបាតទំនប់ហ្នឹងឯង។

**ស៖** បើអ្នកសម្លាប់នោះមិនមែនជាសមាជិកនៃកងឈ្លបដែលលោករៀបរាប់នោះទេ តើលោកដឹងថា អ្នកសម្លាប់នេះមកពីណាដែរទេ? តើអ្នកសម្លាប់នេះអាចជាកងទ័ព ឬក៏កម្មាភិបាលមកពីថ្នាក់ឃុំ ស្រុក ឬក៏ថ្នាក់តំបន់ ឬក៏ថ្នាក់ភូមិអីទេ លោកដឹងទេ?

**ឆ៖** បាទ ខ្ញុំមិនបានដឹងទេ។ ត្រង់ដែលគេគណៈស្រុក ឬក៏គណៈឃុំ ឬក៏ភូមិមកពីណា ក៏ខ្ញុំអត់ដឹង ក៏ដឹងឃើញច្បាស់តែដែលគេសម្លាប់ហ្នឹងហើយ។

[១៣:៥៦:២៤]

**ស៖** ព្រឹត្តិការណ៍ពីរលើកដែលលោកបានឃើញ ព្រឹត្តិការណ៍សម្លាប់នេះ លោកបាននិយាយផងដែរថា មេកងរបស់លោកថា បានទទួលបញ្ជាពី តាវ៉ាល់ៗ គ្រប់គ្រងទូទៅនៅពេលដែលលោកបានឃើញការសម្លាប់ទាំងពីរលើកនេះ។ តើមេកងរបស់លោកបញ្ជាក់ថាអ៊ីចឹង ឬក៏យ៉ាងណា?

**ឆ៖** បាទ ត្រង់ដែលគេបញ្ជាក់ គេមិនបញ្ជាក់ទេ អាហ្នឹងអាអ្នកដែលមកសម្លាប់ហ្នឹង គេបញ្ជាក់ប្រាប់យើងថា "មិត្តឯងប្រឹងធ្វើការ បើមិនធ្វើការ បើមិនបានសម្រេចផែនការទេ ប្រយ័ត្ន! មិត្តឯងប្រយ័ត្នខ្ញុំសម្លាប់ចោលដូចអាមួយហ្នឹង"។ ហើយក៏មិនមែនប្រសាសន៍ហ្នឹង ក៏មិនមែនប្រសាសន៍ តាវ៉ាល់ ឬក៏ពីណា អត់មាន។ អាអ្នកដែលយកមកសម្លាប់ហ្នឹងថាតែប៉ុណ្ណឹងរួច និយាយរួចទៅបាត់ទៅ មិនដឹងទៅនៅឯណា។

**ស៖** ប្រហែលដោយសារជាសំណួរខ្ញុំវាមិនច្បាស់ហើយមើល៍ទៅ លោកបានឃើញការសម្លាប់ពីរលើក តើការសម្លាប់ទាំងពីរលើកនេះគេសម្លាប់នៅពេលដែល តាវ៉ាល់ ជាមេធំនៅការដ្ឋានលើកទំនប់ហ្នឹង ឬក៏អត់ទេ?

**ឆ៖** នៅលើកទំនប់ អង្កាល់ដែលខ្ញុំនៅហ្នឹងគឺតែ តាវ៉ាល់ ហ្នឹងហើយអ្នកនៅ ក៏ប៉ុន្តែមិនមែន តាវ៉ាល់ ហ្នឹងអ្នកមកសម្លាប់ទេ ខ្ញុំថាឈ្លប។ មិនមែន តាវ៉ាល់ បើ តាវ៉ាល់ ខ្ញុំមិនដែលឃើញមុខទេ មិនដឹងជាមុខមាត់យ៉ាងម៉េច ខ្ញុំឃើញតែឈ្លប ឃើញទៅមកៗ ប៉ុន្តែហៅថា ដល់ពេលគេយកមកសម្លាប់ហ្នឹង មិនដឹងជាមកពីណា មិនដឹងឈ្លបមកពីណា ឈ្លបដែលដើរធ្វើការរាល់ថ្ងៃ អត់មានសម្លាប់ទេ អាហ្នឹង វាគ្រាន់តែសម្លុតយើង យកដាវចាក់ ឆ្កឹះ។ អាអ្នកសម្លាប់ វាសម្លាប់រួចទៅវិញបាត់ គេគ្រាន់តែណែនាំយើងហ្នឹងហើយ ប៉ុន្តែមិនដឹងកន្លែងគេនៅឯណានៅឯណី ក៏ខ្ញុំអត់ដឹង។

[១៣:៥៨:៣៩]

**ស៖** សំណួរចុងក្រោយទៅលើប្រធានបទសម្លាប់នេះ។ ខ្ញុំក៏បានស្ដាប់ឮលោកឆ្លើយពីខាងដើមថា មានមនុស្សជាច្រើនបានរែកដី សែងដីយកទៅលុបសាកសព។ តើលោកចង់មានន័យដូចម្ដេច នៅពេលដែលលោកនិយាយថា មនុស្សជាច្រើនបានរែកដី សែងដី ដើម្បីយកទៅកប់ខ្មោចហ្នឹង?

**ឆ៖** បាទ មានន័យថាម៉េច ព្រោះខ្ញុំរែក គេក៏រែក អ្នកណាក៏រែក រែកទៅចាក់ ព្រោះដល់វេនដែលត្រូវចាក់ហើយ គេរៀវួច យើងដល់វេនយើងចាក់ហើយ។ ចេះតែចាក់ទៅ ចាក់រួចយើងមកវិញ បានអានោះគេឡើងទៅចាក់ អានេះក៏ចាក់ អានោះក៏ចាក់។ អាខ្លះចាក់ឡើងទាល់តែដល់លុបទៅមិនឃើញដឹងតែចាក់ទាល់តែពេញខ្នងទំនប់ហ្នឹងឯង។

**ស៖** អ៊ីចឹងលោកចង់និយាយថា ការរែកដីនេះគឺមិនពាក់ព័ន្ធទៅនឹងការកប់សាកសពនេះទេ គឺអ្នកកប់សាកសពផ្សេង អ្នករែកដីលើកទំនប់នេះផ្សេង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ព្រោះសាកសពហ្នឹងវាកប់ហ្នឹងដូចថា អ្នកណាដែលរែកទៅដល់ហ្នឹង ដូចឧទាហរណ៍ថាខ្ញុំរែកទៅមុនគេ ទៅដល់គេរៀវួច ខ្ញុំរែកទៅចាក់។ ដល់បងប្អូនទៅក្រោយចាក់ទៀត ក្រោយទៅចាក់ទៀត ចាក់ៗ ឡើងទាល់តែកើតជាខ្នងទំនប់ ទទឹងវា១០ម៉ែត្រ កម្ពស់វា២០ម៉ែត្រជាង សាមសែសិបម៉ែត្រហ្នឹង។ ចាក់ហ្នឹងទាល់តែពេញទាំងអស់ បានគេវាស់បន្ដមកទៀត។

**ស៖** បាទ ឥឡូវខ្ញុំសូមចូលទៅប្រធានបទថ្មី និយាយអំពីក្រុមរបស់លោក និងកងរបស់លោក។ ខ្ញុំអានកំណត់ហេតុស្ដាប់ចម្លើយរបស់លោក គឺថា រឿន គឺជាមេក្រុមរបស់លោក។ ហើយ សារឿន គឺជាមេកងតូចរបស់លោក។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ សមមិត្តរឿន កាលហ្នឹងជាមេ មិនដឹងជាមិត្ត រឿន មិនដឹងជាមិត្ត វ៉ាន់ ទេ មេក្រុមមេកងហ្នឹង ខ្ញុំក៏ភ្លេចដែរ ប៉ុន្តែមានពីរនាក់ហ្នឹងឯង បើមិន រឿន គឺ វ៉ាន់។

[១៤:០១:២៤]

**ស៖** តើ រឿន, សារឿន និង រុន មានពាក់ព័ន្ធក្នុងការដាក់បញ្ជា ក្នុងការបញ្ជាមកមេកងរបស់លោក ពាក់ព័ន្ធថាចំនួនផែនការដែលត្រូវឱ្យធ្វើ ហើយលោកត្រូវធ្វើការប៉ុន្មានម៉ោងក្នុងមួយថ្ងៃ? តើអ្នកទាំងបីនេះ មានពាក់ព័ន្ធក្នុងការដាក់បញ្ជាហ្នឹងដែរឬក៏អត់ទេ?

**ឆ៖** បាទ ពេលដែលខ្ញុំទទួលផែនការដែលខ្ញុំដែលតូចហ្នឹង វាទទួលផែនការៗពីបើមិនមិត្ត រឿន គឺមិត្ត វ៉ាន់ ព្រោះគេវានៅផ្ទាល់ជាមួយខ្ញុំ។ គេឱ្យ គេអ្នកខាងវាស់ខាងវែងដីឱ្យខ្ញុំជីក ឱ្យខ្ញុំកាប់។ តែត្រង់ថាអ្នកណាដែលបញ្ជាពីលើគេទៀតនោះ ខ្ញុំអត់ដឹងទេ ព្រោះដឹងថា ដែលមេខ្ញុំតែពីរនាក់ហ្នឹងឯង មួយមេ

ក្រុម មួយកងតូច។ គេអ្នកវាស់វែង ចាត់ចែងការងារ។

**ស៖** នៅពេលដែលអ្នកណាម្នាក់ក្នុងកងរបស់លោកធ្វើការមិនបានគ្រប់ផែនការនោះ តើអ្នកណាម្នាក់ដែលនិយាយជាមួយនឹងពលករដែលធ្វើការមិនគ្រប់ផែនការនេះ? តើ រឿន ឬក៏ សារឿន ឬក៏ រុន?

**ឆ៖** ហ្នឹងកងតូចរបស់ខ្ញុំ រឿន ដែលគេអ្នកមកថាមកយើង គេកាត់បន្ថយរបប។ គេបន្ថយពីយើងម្នាក់ហ្នឹង ក្នុងម្នាក់ហ្នឹងគេដកពីយើងម្នាក់ហ្នឹង គេយកទៅថែមឲ្យពីរនាក់ ម្នាក់បន្តិចៗទៅ យើងបានតែពីរ គេបានបីកន្លះ។

[១៤:០៣:៣៩]

**ស៖** មនុស្សទាំងបីនាក់នេះ គឺថាគ្រប់គ្រងក្រុមកងតូចរបស់លោក តើហេតុអ្វីបានជាពួកគេទាំងបីនាក់ត្រូវការជំនួយពីឈ្លប ដើម្បីឲ្យមកជួយបង្ខំពលករធ្វើការឲ្យបានខ្លាំងក្លា? ហេតុអីបានជាមេក្រុម និងមេកងទាំងបីនាក់របស់លោកនេះ ពឹងពាក់ឈ្លបឲ្យមកជួយត្រួតពិនិត្យពលករនៅការដ្ឋាននោះ?

**ឆ៖** បាទ កន្លែងហ្នឹងក៏ខ្ញុំ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាល់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន សំណួរនេះគឺធ្វើឲ្យសាក្សីសន្និដ្ឋានអ្វីដែលជាការគិតគូររបស់មេកងតូចរបស់គាត់។ ដូច្នេះ វាជាសំណួរដែលមិនត្រឹមត្រូវ។

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំមិនបានសួរសាក្សីឲ្យធ្វើសេចក្ដីសន្និដ្ឋានទេ។ ខ្ញុំសួរហេតុផល ថាតើមានហេតុផលណាដែលនាំឲ្យគាត់ដឹងថា រឿន, សារឿន និង រុន ត្រូវការជំនួយឈ្លបដែលកាន់ដាវឲ្យមកត្រួតត្រាពលករនៅការដ្ឋានការងារនោះ ពីព្រោះវាដូចជាមិនធម្មតាទេនូវអ្វីដែលគាត់រៀបរាប់អំមិញ។ អ៊ីចឹងឯងបានជាខ្ញុំចង់ដឹងថា ម៉េចបានជាអ្នកបីនាក់នេះទៅជាពឹងឈ្លបមកឲ្យជួយត្រួតពិនិត្យពលករ។

**ប្រធានអង្គជំនុំ៖**

បដិសេធសេចក្ដីជំទាស់ សាក្សីឆ្លើយតបនឹងសំណួរ!

[១៤:០៥:៤០]

**លោក ស៊ុត សុផល៖**

**ឆ៖** បាទ ពីព្រោះមេកងតូច ហើយនិងមេក្រុម អាហ្នឹងពួកហ្នឹងគេបញ្ជាគាត់ បញ្ជាគេឲ្យគេមកសួរយើង ឲ្យមកបង្ខំយើង ឲ្យយើងជួយ ពីព្រោះគេបានទទួលផែនការពីថ្នាក់ ពីអង្គការគេនោះ។ គេទៅទទួលហើយ គេមកពីទទួលវិញ គេរៀបផែនការដាក់ឲ្យយើងអាតូចៗ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើលោកធ្លាប់ឃើញ វឿន, សារឿន និង វុន ធ្លាប់បានបញ្ជាទៅឈ្លបទាំងនេះដោយផ្ទាល់ទេ?

**ឆ៖** បាទ មិនដែលឃើញទេ។

**ស៖** លោកក៏បានឆ្លើយថា លោកឆ្លើយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកជូនមន្ត្រីស៊ើបអង្កេត ថាយើងមិនត្រូវបានអនុញ្ញាតឲ្យសម្រាកនៅក្នុងពេលបាយថ្ងៃត្រង់នោះទេ។ សូមកែតម្រូវ គឺថាលោកបានឆ្លើយថា "គេមិនអនុញ្ញាតឲ្យយើងសម្រាកក្នុងពេលកំពុងធ្វើការនោះទេ"។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** សុំម្ដងទៀតបង ស្ដាប់មិនយល់។

[១៤:០៧:២៦]

**ស៖** នៅក្នុងចម្លើយរបស់លោកឆ្លើយប្រាប់អ្នកស៊ើបអង្កេត លោកថាគេមិនឲ្យលោកសម្រាកនៅក្នុងពេលធ្វើការទេ។ តើចម្លើយនៅក្នុងកំណត់ហេតុនេះត្រឹមត្រូវដែរទេ? ហើយបើសិនណាជាគេមិនឲ្យសម្រាកនេះ អ្នកណាជាអ្នកហាមឃាត់មិនឲ្យលោកសម្រាកពេលកំពុងធ្វើការ?

**ឆ៖** បាទ អ្នកដែលប្រាប់យើងមិនឲ្យសម្រាកហ្នឹង គឺមេក្រុម។

**ស៖** ចុះបើសិនជាមានពលករគាត់សម្រាក តើអ្នកណាជាអ្នកនិយាយទៅកាន់ពលករដែលសម្រាកហ្នឹង ឲ្យក្រោកឡើងបន្តធ្វើការតទៅទៀតនោះ?

**ឆ៖** បាទ ហ្នឹងមេក្រុមដូចតែគ្នា។

**ស៖** តើអ្នកដែលប្រាប់ពលករដែលសម្រាកឲ្យក្រោកឡើងបន្តធ្វើការទៀតហ្នឹង ជាឈ្លបដែលលោកបាននិយាយមុននេះ ឬក៏មិនមែនទេ?

**ឆ៖** បាទ មិនមែនឈ្លបទេ មេក្រុមៗក្នុងកងតូចកងអី។ គេមកប្រាប់មិនឲ្យយើងសម្រាកយើងអីហ្នឹង រឿងមេក្រុមគេទេ រឿងអាពួកឈ្លបហ្នឹង វាមិនដែលមកទេ អាពេលវាមក គឺដើរតែឆ្អឹះដើរផ្ទៀល

អាហ្នឹងអត់មានម៉ោងទេអាហ្នឹង ម៉ោងណាក៏វាដើរបាន។ បើមេក្រុម អាហ្នឹងគេអត់ធ្វើការទេ គេអង្គុយមើលយើងអ៊ីចឹងទៅ អាណាធ្វើមិនធ្វើ ដល់ពេលណាមិនធ្វើ គេក្រោកថា “អូនអ្នំ! ប្រឹងងើបទៅទៀត ឬក៏មិត្តអ្នំ តស៊ូទៅទៀត ធ្វើ”។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំលោកសាក្សី។ នៅក្នុងចម្លើយទៅនឹងសំណួរទី១ លោកបានឆ្លើយដូចតទៅ “ប្រាំខែក្រោយថ្ងៃរំដោះ១៩៧៥ គេជម្លៀសខ្ញុំឲ្យទៅនៅស្វាយទាំងគ្រួសារ។ កាលនោះយើងក្មេងៗគេឲ្យរៀន បន្ទាប់មកគេមិនអនុញ្ញាតឲ្យយើងរៀនទៀតទេ ដោយសារយើងធំហើយ។” លោកចាំថា លោកបានឆ្លើយឃ្លានេះជូនមន្ត្រីស៊ើបអង្កេតទេ?

[១៤:១០:១៨]

**ឆ៖** បាទ អាហ្នឹងខ្ញុំឆ្លើយមែន រៀន ក៏ប៉ុន្តែអត់ដែលមានសាលាទេ យើងរៀននៅក្នុងភូមិ ក្រោមម្លប់ឈើ គ្មានសាលាទេ។ ហើយរៀនមួយថ្ងៃអ៊ីចឹងទៅ ខានបួនប្រាំថ្ងៃ រៀនកន្លះម៉ោងអ៊ីចឹងទៅ ខានបួនដប់ថ្ងៃ។ គេឲ្យទៅកាប់ ឲ្យទៅរែកតែដី អារែកដីអាចម៍គោ រែកដំបូក កាប់ដំបូក កាប់ទន្ទ្រានខែត្រ។ ទៅរៀនតែអាហ្នឹងឯងរួចមក មិនដែលមានសាលារៀនឯណា រៀនតែក្នុងម្លប់ឈើហ្នឹង រៀនកាប់ រៀន មិនដែលមានសៀវភៅឯណាសរសេរ រៀនតែកាប់ រៀនតែពូតដី ដំដីដំបូកអីហ្នឹងឯង។

**ស៖** អ៊ីចឹងត្រឹមត្រូវដែលទេ ដែលថាក្នុងឆ្នាំ១៩៧៥ លោកទើបតែមានអាយុ១១ឆ្នាំទេ ត្រឹមត្រូវដែរឬក៏អត់ទេ?

**ឆ៖** អត់ទេ ខ្ញុំវាភ្លេចដែលបង ព្រោះអីវាបាត់ការចងចាំអស់ អង្កាល់ហ្នឹងមិនដឹងអាយុ១២ ឬក៏អាយុ១៤ ព្រោះខ្ញុំវាភ្លេច។

**ស៖** លោកចាំទេថា លោកធ្លាប់បានទៅចូលរៀនទេ នៅពេលលោកអាយុ៤ឆ្នាំ ៥ឆ្នាំ ឬ៦ឆ្នាំ តើលោកធ្លាប់បានទៅចូលរៀននៅសាលាទេ មុនឆ្នាំ១៩៧៥?

**ឆ៖** បាទ អត់មានទេ ព្រោះមុនសម័យ៧៥ហ្នឹង គឺខ្ញុំនៅក្នុងព្រៃ។ គេចតែគ្រាប់ទម្លាក់ គេចតែគ្រាប់ផ្លោងជាមួយម៉ែ ជាមួយឪ រត់ចូលតែត្រង់សេ មិនដែលបានរៀន បានសូត្រឯណា។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន ខ្ញុំចប់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អគុណ។ ជាបន្តនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក

ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក ស៊ុត ផល! ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។ ខ្ញុំមានសំណួរមួយចំនួនដើម្បីសុំការបញ្ជាក់ពីលោក សំណួរខ្ញុំមានតិចតួចទេ ហើយមេធាវី គង់ សំអុន ក៏គាត់មានសំណួរមួយចំនួនដែរ។ ខ្ញុំចង់ត្រឡប់មកនិយាយអំពីរយៈកាលដែលលោកធ្វើការនៅទំនប់ត្រពាំងថ្ម។ លោកបានឆ្លើយថា លោកមិនចាំថាលោកចាប់ផ្តើមធ្វើការហ្នឹងគឺអាយុប៉ុន្មានទេ អ៊ីចឹងលោកអត់ចាំថា លោកកើតនៅឆ្នាំណាទេ ក៏ប៉ុន្តែលោកបានឆ្លើយជូនសហព្រះរាជអាជ្ញាថាលោកកើតឆ្នាំ៦៤ ព្រោះថាឪពុកលោកជាអ្នកប្រាប់លោក។ អ៊ីចឹងតើចម្លើយរបស់លោកហ្នឹងត្រឹមត្រូវទេ គឺលោកកើតនៅឆ្នាំ១៩៦៤ មែនទេ?

[១៤:១៤:០៨]

**លោក ស៊ុត សុផល៖**

**ឆ៖** បាទអាហ្នឹងខ្ញុំចាំច្បាស់ណាស់ អារឿងកើតឆ្នាំ១៩៦៤ហ្នឹង ព្រោះអង្កាល់យើងឆ្នាំរំដោះនេះគេចុះធ្វើប្រវត្តិរូប។ ដល់ធ្វើប្រវត្តិរូប ពុកខ្ញុំ អង្កាល់ហ្នឹងគេសួរពុកខ្ញុំថា ពុកខ្ញុំកើតឆ្នាំអីៗអ៊ីចឹងទៅ? គាត់ៗប្រាប់ថា អ្អែងទន្ទេញឲ្យចាំ ថាអ្អែងកើតឆ្នាំ១៩៦៤។ ខ្ញុំក៏ចាំតែរហូតមក អាហ្នឹងខ្ញុំដូចថាវាពេញវ័យ ហើយអាដែលគេធ្វើប្រវត្តិរូប ឆ្នាំដែលគេរំដោះហ្នឹង ដែលវៀតណាមគេចូលរំដោះហ្នឹង អាហ្នឹងខ្ញុំចាំច្បាស់ហើយអាហ្នឹង ព្រោះឪពុកខ្ញុំគាត់ប្រាប់។ ក៏ខ្ញុំទន្ទេញចាំតែរហូត ប៉ុនរឿងមែនមិនមែន ម៉េចដឹង ខ្ញុំចេះតែថា ឪពុកគាត់ប្រាប់ថាអ៊ីចឹងហើយ ខ្ញុំចេះតែឆ្លើយអ៊ីចឹងទៅ ចាំអាហ្នឹងរហូតមក ធ្វើអី ប្រវត្តិរូបអី អត្តសញ្ញាណប័ណ្ណអី ក៏ខ្ញុំដាក់៦៤ – ១៩៦៤ៗ តែ៦៤តែរហូតទាំងអស់ហ្នឹងឯង។ ត្រង់អា៦៤ អាយុប៉ុន្មាន យកទៅគុណប៉ុន្មាន ដកប៉ុន្មាន ចែកប៉ុន្មាន ខ្ញុំម៉េចចេះ ខ្ញុំវាមិនដឹង ព្រោះឪពុកប្រាប់ថា ៦៤ គឺ៦៤ហ្នឹងហើយ។

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះ។ ដូច្នេះចាប់ពីពេលបញ្ជាក់នេះមក យើងអាចធ្វើការគណនាបាន កុំព្រួយបារម្ភអី។ ដូច្នេះខ្ញុំអាចសន្និដ្ឋានបានថា នៅឆ្នាំ៧៥ លោកមានអាយុ១១ឆ្នាំ ប្រសិនបើខ្ញុំច្រឡំសូមលោកកែខ្ញុំ។ ខ្ញុំយល់ថា លោកចាប់ផ្តើមធ្វើការនៅក្នុងកងកុមារដែលមានអាយុ១៤

ដល់១៨ឆ្នាំ គឺពេលដែលលោកចាប់ផ្ដើមធ្វើការហ្នឹង គឺលោកមានអាយុ១៤ឆ្នាំមែនទេ? គេឲ្យលោកចូលទៅក្នុងកងកុមារហ្នឹង នៅពេលដែលលោកមានអាយុ១៤ឆ្នាំ។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

[១៤:១៦:០២]

**ផ៖** អាហ្នឹងក៏ខ្ញុំមិនដឹង ព្រោះឪពុកខ្ញុំ ម្ដាយខ្ញុំប្រាប់ខ្ញុំថា អាយុ១៤ ឆ្នាំប្រាប់ថា១៤ទៅ។ ខ្ញុំធ្វើម៉េចចាំ ខ្ញុំម៉េចដឹង បើគាត់ប្រាប់ថា១៤ៗ ក៏១៤តែរហូតហ្នឹងឯង អាយុ។ ទោះបីជាខ្ញុំ១១ឆ្នាំ ក៏ខ្ញុំប្រាប់គេថា១៤។ ខ្ញុំ១២ឆ្នាំ ក៏ខ្ញុំប្រាប់គេថា១៤ បើពុកខ្ញុំប្រាប់ថា អ្អែង១៤ហើយ ឬក៏១២ហើយ ខ្ញុំធ្វើម៉េចដឹងថាអាយុខ្ញុំប៉ុន្មាន។

**ស៖** តើលោកចាំទេ ក្រោយពេលលោកចូលធ្វើការនៅកងកុមារបានប៉ុន្មានខែ ទើបលោកទៅធ្វើការនៅការដ្ឋានត្រពាំងថ្ម? ភ្លាមៗតែម្ដង ក្រោយពេលលោកចូលក្នុងកងកុមារ ឬក៏រយៈពេលប៉ុន្មានខែក្រោយមក លោកចាំទេ?

**ផ៖** បាទ រយៈពេលមិនដឹងជាប៉ុន្មានខែ ក៏ប៉ុន្ដែដែលខ្ញុំនៅកាប់ជីកាប់អី រៀងយូរដែរ មិនដឹងជាខែ មិនដឹងឆ្នាំហ្នឹង ក៏ខ្ញុំវាចាំមិនច្បាស់ដែរ ក៏ប៉ុន្ដែដល់តែពេលក្រុមអង្គការគេហ្នឹងទៅសួរយើង ទៅសួរឪពុកម្ដាយយើងថា អ៊ំ ឬក៏អ៊ី កូនអ៊ុំឯង អាយុប៉ុន្មានហើយ គាត់ក៏បានប្រាប់គេទៅថា កូនខ្ញុំអាយុប៉ុននេះ អាយុ១២ឆ្នាំ ឬក៏អាយុ១៣ឆ្នាំ។ រួចដល់អ៊ីចឹងទៅ អង្គការគេហ្នឹង គេមានក្រដាសមានអី គេដើរកត់ គេដើរជ្រើសរើសដកកម្លាំងយក។

**ស៖** ខ្ញុំយល់មិនសូវច្បាស់ទេ។ លោកឆ្លើយថា នៅពេលសម័យនុ៎ង លោកនិយាយថា លោកមានអាយុ១៤ឆ្នាំ ហើយឪពុកលោកក៏ប្រាប់ថា លោកអាយុ១៤ឆ្នាំ។ ឥឡូវនេះលោកចង់និយាយថា ម្ដាយរបស់លោកបាននិយាយថា លោកមានអាយុផ្សេង។ អ៊ីចឹងខ្ញុំចង់ដឹងថា នៅពេលដែលលោកធ្វើការនៅក្នុងកងកុមារនោះ លោកប្រាប់គេថាលោកមានអាយុ១៤ឆ្នាំ។ អ៊ីចឹងមែនទេ?

[១៤:១៨:៣៣]

**ផ៖** បាទ ដែលគេទៅសួរ មិនមែនសួរនៅឯកន្លែងកុមារទេ គេសួរនៅឯផ្ទះដែលខ្ញុំនៅជាមួយឪពុកម្ដាយរបស់ខ្ញុំហ្នឹងណា។ គេមិនមែនសួរខ្ញុំទេ គេសួរម៉ែខ្ញុំថា អ៊ី កូនអ៊ីឯងអាយុប៉ុន្មាន – កូនមិត្តឯងហ្នឹងអាយុប៉ុន្មានហើយ? ហើយម្ដាយខ្ញុំក៏ឆ្លើយទៅកាន់អង្គការហ្នឹងវិញថា កូនខ្ញុំហ្នឹងវាអាយុ១២ឆ្នាំ ឬក៏១៤ឆ្នាំអីអ៊ីចឹងទៅ។ ហើយក៏ខ្ញុំឮដែរសំឡេងដែលគាត់សួរ ដែលគាត់ប្រាប់គេអ៊ីចឹងទៅ ខ្ញុំក៏ចាំ។ ថាអ្អឹ ខ្ញុំអាយុ១៤ឆ្នាំ ឬក៏១២ឆ្នាំហើយអ៊ីចឹងទៅ។ បើត្រង់ឲ្យខ្ញុំចេះរាប់ ចេះចាំខ្លួនឯង ខ្ញុំម៉េចចេះ ចាំតែដែលម៉ែខ្ញុំ

និយាយពីរម៉ាត់ ឬបីម៉ាត់ហ្នឹងឯង។

**ស៖** មិនជាបញ្ហាអ្វីទេ លោកសាក្សី។ ខ្ញុំបន្តទៅសួរលោកអំពីការងារនៅត្រពាំងថ្ម។ នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់ចៅក្រម ហ្វេនស៍ ទោះបីជាលោកមិនចាំថា លោកនៅទំនប់នុំងប៉ុន្មានក៏ដោយ ក៏ប៉ុន្តែលោកបាននិយាយថា លោកធ្វើការនុំងក្នុងរដូវប្រាំង ព្រោះថានៅក្នុងរដូវវស្សា គេអត់ឲ្យលោកជីកប្រឡាយទេ។ ដូច្នេះខ្ញុំចង់សួរលោកថា តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា រដូវប្រាំងហ្នឹងគឺចាប់ពីខែណា ដល់ខែណា? ឧទាហរណ៍ថា នៅក្នុងឆ្នាំមួយអ៊ីចឹង យើងនិយាយរដូវប្រាំងហ្នឹង តើយើងចាប់រាប់ពីខែណា ដល់ខែណា?

**ឆ៖** អង្កាល់នោះរដូវប្រាំង ខ្ញុំមិនដឹង មិនដឹងជាខែណារដូវប្រាំង ព្រោះដឹងតែខែអត់ភ្លៀង។ តែវាមិនភ្លៀង គេហៅរដូវប្រាំង។ ចុះបើខ្ញុំធ្វើៗទៅ ឡើងដល់ខែភ្លៀង។ ដល់ខែភ្លៀងគេដកយកទៅឲ្យធ្វើអីកាប់ចិញ្ច្រាំៗដី គេសាបសំណាប សាបអីហ្នឹង ថ្នាល។ គេយកកងកុមារហ្នឹងយកទៅឲ្យសាប់ៗដី រួចអូស នាំគ្នាអូសរនាស់ហ្នឹងទៅ ហើយគេរើកម្ទេចៗដីហ្នឹងទៅ យកស្រូវហ្នឹងសាបៗ ដាំដុះ។

[១៤:២១:០២]

**ស៖** នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងកន្លែងដែលលោកធ្វើការនៅទំនប់ត្រពាំងថ្ម លោកបានឆ្លើយថា លោកនៅផ្នែកខាងកើតទៅខាងលិច នៃជ្រុងខាងកើតទៅជ្រុងខាងលិច។ អ៊ីចឹងខ្ញុំចង់ដឹងថា ឈ្មោះភូមិដែលនៅជិតកន្លែងដែលលោកធ្វើការបំផុតហ្នឹងឈ្មោះភូមិអី? លោកចាំទេ ភូមិដែលនៅជិតកន្លែងដែលលោកធ្វើការហ្នឹង ជាភូមិអីដែរ?

**ឆ៖** បាទ ភូមិហ្នឹង អង្កាល់ដែលពីសម័យដែលខ្ញុំធ្វើហ្នឹង គេហៅ វាមានភូមិត្រពាំងថ្ម ស្ថិតនៅក្នុងស្រុកភ្នំស្រុក ឬក៏ភូមិស្អីទេ អ៎! ភូមិស្នួល ភូមិស្អីម៉េចទេ ខ្ញុំវាមិនសូវចាំដែរ វាយូរដែរ ភូមិអស់ហ្នឹង។ ប៉ុនបើមិនភូមិត្រពាំងថ្ម ក៏ភូមិស្នួល ភូមិដែលនៅជាប់ ដែលជិត ជាប់នឹងជើងទំនប់ខ្នងអាងហ្នឹង។

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះ។ លោកបានឆ្លើយថា គេបានតាមដានលោកពេលលោកធ្វើការនៅទំនប់ត្រពាំងថ្ម ហើយលោកបានឆ្លើយថា អ្នកដែលតាមដានហ្នឹង គឺជាមេពួកមេកង។ ហើយលោកក៏បាននិយាយអំពីថា មានឈ្លបផងដែរ។ ជាពិសេសនោះ នៅពេលដែលលោកឆ្លើយនៅថ្ងៃនេះនោះ លោកបញ្ជាក់ថា មានកងមួយទៀត ដែលធ្វើការនៅជិតលោកដែរ ហើយពេលខ្លះទៅដើម្បីប្រាប់ថា មានក្រុមឈ្លបមកដល់ គឺថាលោកកប់ថ្មដាក់គ្នាទៅ ដើម្បីឲ្យដឹងថាពេលហ្នឹង គឺឈ្លបមកហើយ។ អ៊ីចឹងខ្ញុំចង់ដឹងថា ឈ្លបហ្នឹង គឺមិនយាមជាប្រចាំនៅកន្លែងធ្វើការហ្នឹងទេ គឺមកតែម្តងម្កាល

ទេ។ អ៊ីចឹងហើយបានជាពួកលោក នៅពេលដែលឃើញឈ្លបមកដល់ហ្នឹង តែងតែកប់ថ្មដាក់គ្នា ប្រាប់គ្នាឲ្យដឹងនោះ អ៊ីចឹងមែនទេ?

[១៤:២៣:៣៣]

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** ដូច្នេះមានន័យថា ឈ្លបមិនមកយាម មកមើលហ្នឹង គឺរៀងរាល់ថ្ងៃទេ មែនទេ?

**ឆ៖** បាទ នៅប្រចាំហ្នឹងគឺនៅរាល់ថ្ងៃ ក៏ប៉ុន្តែមិនមែនបានដើររាល់ម៉ោងទេ។ ជួនកាលនោះ ពីរម៉ោងអី ដើរមើលហួសទៅអ៊ីចឹងទៅ កន្លះម៉ោង ឬមួយម៉ោងក្រោយអ៊ីចឹងទៅ ដើរពីកើតទៅលិចអ៊ីចេះវិញទៅ។

**ស៖** តាមរយៈសក្ខីកម្មរបស់លោក ខ្ញុំយល់ថា ប្រធានឈ្លបនោះ គឺស្ត្រីមួយរូបដែលមានកាំភ្លើង -- ដែលមានដៃតូច ដែលមានកាំភ្លើងតូច (សូមទោស)។ អ៊ីចឹងខ្ញុំចង់ដឹងថា ឈ្លបហ្នឹង គឺជាទាហានដដែលៗទេ គឺជាមនុស្សដដែលៗទេ ដែលមកយាមនៅការដ្ឋានហ្នឹង មែនទេ?

**ឆ៖** បាទ អត់មានដដែលៗទេ គេដូរ។ ជួនកាលទៅឃើញមកផ្សេងទៅ បើសិនណាឈ្លបអាកូនតូចៗអស់ហ្នឹងគឺប្រចាំការ បើអាធំៗស្រីម្នាក់ៗហ្នឹងគេដូរគ្នា។ ប៉ុន្តែកាំភ្លើងឃើញស្ពាយតែកាំភ្លើងដដែលៗហ្នឹងឯង។ កាំភ្លើងខ្ញុំមិនស្គាល់ទេ ដឹងកាំភ្លើងអី ព្រោះសម័យនោះ បើសម័យនេះអត់ឃើញមានប្រើ ឃើញប្រើតែសម័យបីឆ្នាំ កាំភ្លើងហ្នឹង។

[១៤:២៥:៣៥]

**ស៖** នៅពេលដែលលោកនិយាយថា មានការប្តូរវេនយាមគ្នាអ៊ីចឹង គឺចង់និយាយថា គេដូរកន្លែងយាម ប៉ុន្តែអ្នកយាម អ្នកឈ្លបមកយាមមកមើលហ្នឹងគឺថា មនុស្សដដែលៗទេ មែនទេ?

**ឆ៖** បាទ គឺមនុស្សដដែលៗ ដូចថាឈ្លប អាដែលកាន់កាំបិត កាន់ដាវហ្នឹងដដែលៗ ប៉ុន្តែបើស្រីហ្នឹងគេដូរគ្នា។ ជួនកាលមួយថ្ងៃពីរថ្ងៃអ៊ីចឹងទៅ ឃើញមុខមកផ្សេង មួយថ្ងៃពីរថ្ងៃទៅឃើញមុនដដែលវាមិនទៀង។ ជួនកាលនៅពីរថ្ងៃឧប ជួនកាលឃើញតែមួយថ្ងៃអ៊ីចឹងទៅ បាត់ទៅ។

**ស៖** លោកបានឆ្លើយថា ក្មេងៗដែលឈ្លបហ្នឹងគឺមានគ្នាបីនាក់ អ៊ីចឹងអ្នកមករហូតហ្នឹងគឺបីនាក់ហ្នឹងរហូត មែនទេ?

**ឆ៖** បាទ ដែលមកហ្នឹងគឺមកបីនាក់រហូត ក៏ប៉ុន្តែដូរ គ្រាន់តែដូរមុខនារីហ្នឹងឯង។ នារីដែលគេមកហ្នឹង មកជាមួយគ្នា ប៉ុន្តែវាដូរមុខ បើប្រុសៗហ្នឹងអត់ដូរទេ កុមារប្រុសៗហ្នឹង ដូរតែប្រធាន ដូចថា

នារីៗហ្នឹងគេដូរគ្នា។ ជួនកាលឃើញឧបពីរថ្ងៃ បីថ្ងៃអ៊ីចឹងទៅ ឃើញបាត់នារីហ្នឹងបាត់ ប្រហែលគេយកថ្មីមកទៀត កន្លះខែទៅមួយខែបាត់ទៅណាទៀតទៅ ប្រធានគេមិនដែលឃើញ បើអាកូនក្មេងហ្នឹងគឺប្រចាំការប្រចាំថ្ងៃ ប្រចាំម៉ោង ទៅមកៗតែរហូតហ្នឹង។

**ស៖** លោកបានឆ្លើយថា លោកមានគ្នាច្រើននៅក្នុងកងរបស់លោក។ តើលោកសុទ្ធតែមកពីភូមិឃុំតែមួយជាមួយគ្នាមែនទេ?

**ឆ៖** បាទ ដែលមកហ្នឹង គឺកងកុមារហ្នឹងគឺមកពីភូមិឃុំជាមួយគ្នា ក៏មិនមែនអ្នកភូមិកំណើតហ្នឹងទាំងអស់គ្នាទេ។ ភូមិហ្នឹងអាខ្លះគេយកពីនេះ អាខ្លះគេយកពីនោះ យកពីណា យកពីណីទៅ យកទៅដាក់រៀបក្នុងព្រៃហ្នឹង គេរៀបមួយភូមិ។ ប៉ុន្តែមិនដឹងជាមកពីណា មិនដឹងពីណី អាខ្លះនិយាយអ៊ីចឹង អាខ្លះនិយាយតេវ អាខ្លះនិយាយទៅអ៊ីចុះទៅ។ យើងមិនបានស្គាល់គ្នាអស់ទេ។ ខ្លះទៅគេហៅប្រជាជនថ្មី ប្រជាជនចាស់អីណា។

[១៤:២៨:២០]

**ស៖** តើឈ្លបដែលលោកឃើញជារៀងរាល់ថ្ងៃហ្នឹង គឺពួកគេសុទ្ធតែមកពីភូមិតែមួយជាមួយគ្នាមែនទេ?

**ឆ៖** បាទ ដែលដកហ្នឹង ដកពីក្រុមកុមារជាមួយគ្នាហ្នឹងហើយ។ មកដល់គេដំឡើងឲ្យគេធ្វើឈ្លបអ៊ីចឹងទៅ គេបានធ្វើឈ្លប គេស្រួលគេ។

**ស៖** លោកបានឆ្លើយថា លោកមិនដឹងថាតើមានមន្ទីរពេទ្យ ឬក៏អត់ទេនៅជិតទំនប់ត្រពាំងថ្ម នោះ។ អ៊ីចឹងខ្ញុំចង់បានការបញ្ជាក់ពីលោកម្តងទៀតថា ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ដែលខ្ញុំឆ្លើយហ្នឹងថា មិនដែលមានមន្ទីរពេទ្យហ្នឹង គឺត្រឹមត្រូវ ព្រោះខ្ញុំវាមិនដែលឃើញមន្ទីរពេទ្យមែន គឺព្យាបាលអ្នកជំងឺ គឺព្យាបាលនៅកន្លែងដែលធ្វើការ។ ផ្សំថ្នាំ បើកថ្នាំអី យើងសុំមេក្រុម មិនមែនសុំពេទ្យទេ។ សមមិត្តមេក្រុម ខ្ញុំឈឺពោះ ហើយគេយកថ្នាំមកឲ្យយើងលេប។ ឈឺពោះក៏ថ្នាំតែមួយមុខហ្នឹងឯង។ ថ្ងៃក្រោយ មួយថ្ងៃពីរថ្ងៃអ៊ីចឹងទៅ ខ្ញុំដូចថារាងចង់ក្តៅខ្លួន ឬគ្រុន សុំគេតាមរយៈមេក្រុមទៅ បើកមកថ្នាំបាត់ឈឺពោះហ្នឹងឯងទៀត។ ថាដដែលៗហ្នឹងឯងថ្នាំ អត់មានអាណាគ្រុនផ្សេង ថ្នាំបាត់ឈឺពោះផ្សេង អត់មានទេ ឃើញថ្នាំដដែលៗ អាថ្នាំប៉ុនចង្កឹះហ្នឹងឯង។ បើកន្លែងមន្ទីរពេទ្យវាអត់មាន មិនដឹងជានៅឯណាផង មិនដែលឃើញពេទ្យ។

[១៤:៣០:១៩]

**ស៖** ខ្ញុំសួរសំណួរនេះពីព្រោះថា យើងបានស្ដាប់ចម្លើយសាក្សីជាច្រើនរួចមកហើយនៅក្នុងតុលាការនេះ ដែលពួកគាត់ធ្លាប់ធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្មដែរ ហើយគាត់ អ្នកខ្លះនោះក៏បាននិយាយថា មានមន្ទីរពេទ្យ។ អ៊ីចឹងហើយបានជាខ្ញុំសួរបញ្ជាក់លោក ខ្ញុំចង់រំឭកការចងចាំរបស់លោក គឺខ្ញុំសុំយោងទៅលើសក្ខីកម្មរបស់សាក្សីឈ្មោះ ឈុំ សេង នៅក្នុងសវនាការថ្ងៃទី១៧ សីហា ឆ្នាំ២០១៥ គឺមុនម៉ោងដប់បួន ម្ភៃបីនាទី។ គាត់បានពន្យល់ថា មានពេទ្យនៅក្នុងកងនីមួយៗ ហើយប្រសិនបើអ្នកណាឈឺធ្ងន់ គេបញ្ជូនទៅមន្ទីរពេទ្យនៅវត្តត្រពាំងថ្ម។ ដូច្នេះខ្ញុំចង់សួរលោកថា តើលោកធ្លាប់ស្ដាប់ឮគេនិយាយអំពីមន្ទីរពេទ្យវត្តត្រពាំងថ្មទេ?

**ឆ៖** បាទ បើខ្ញុំនេះដូចមិនដែលឮគេនិយាយរឿងមន្ទីរពេទ្យ ប៉ុន្តែដល់មន្ទីរពេទ្យ ថាពេទ្យ ខ្ញុំមិនដែលឮគេនិយាយ ព្រោះយើងឈឺយើងរងា គេសុំថ្នាំតាមរយៈតែមេក្រុម ឬក៏មេពួកហ្នឹងឯង។ អ្នកមិត្តអ្នកថាខ្ញុំថ្ងៃនេះឈឺពោះ ប្រាប់ទៅមេក្រុមខ្ញុំហ្នឹង ហើយត្រង់ដែលមេក្រុមខ្ញុំគេទៅរកពេទ្យ រកអីមន្ទីរពេទ្យឯណាហ្នឹង រឿងរបស់គេ ខ្ញុំក៏អត់ដឹង។ ស្រាប់តែបន្តិច ឃើញគេឲ្យថ្នាំពីរគ្រាប់អីមកលេប។ លេបទៅក៏ធ្វើការទៀតទៅ មានបានឡើងទៅដេក ទៅសម្រាកខ្លួនឲ្យត្រជាក់ឲ្យអី អត់ទេ។ ធ្វើការ គ្រាន់តែលេបតែថ្នាំរួចប្រហែល៥នាទីអី ចាប់ផ្ដើមធ្វើការទៀតហើយ។

[១៤:៣២:០៥]

**ស៖** លោកសាក្សី ដោយសារតែខ្ញុំមានពេលវេលាខ្លី ខ្ញុំព្យាយាមសួរខ្លីៗជាក់លាក់។ ខ្ញុំស្ដាប់ឮសក្ខីកម្មរបស់លោកនេះរួចមកហើយ។ លោកបានឆ្លើយចម្លើយនេះរួចមកហើយ ក៏ប៉ុន្តែខ្ញុំសុំឲ្យលោកផ្ដោតអារម្មណ៍ទៅលើសំណួររបស់ខ្ញុំ ដើម្បីឲ្យខ្ញុំអាចសួរឈានទៅមុខបានទៀត។ សាក្សីមួយរូបទៀត គឺ យី ឡៃសួរ គឺក្នុងសវនាការថ្ងៃ២០ ខែសីហា ឆ្នាំ២០១៥ បាននិយាយអំពីមន្ទីរពេទ្យមួយ គឺនៅមុនម៉ោងដប់មួយ ដប់ប្រាំពីរនាទី គាត់បានបញ្ជាក់ថា គេបញ្ជូនទៅមន្ទីរពេទ្យប៉ោយចារ។ អ៊ីចឹង តើលោកធ្លាប់ស្ដាប់ឮឈ្មោះមន្ទីរពេទ្យប៉ោយចារនេះទេ?

**ឆ៖** បាទ ខ្ញុំនៅឆ្លើយទៅថាដដែលៗ ព្រោះខ្ញុំប្រាប់ថារឿងមន្ទីរពេទ្យ ហើយនិងពេទ្យនេះ ខ្ញុំវាមិនដែលឃើញសោះ ហើយក៏មិនដែលដឹងសោះហ្នឹង ព្រោះខ្ញុំរយៈតាមតែមេក្រុម និងមេកងតូច។ តែខ្ញុំឈឺ ខ្ញុំប្រាប់គេ។ មិនដែលឃើញពេទ្យថា អូ៎! លោកគ្រូពេទ្យ ខ្ញុំគ្រុន សុំថ្នាំលេប អត់ដែលមាន។ មិនដែលឃើញពេទ្យ មិនដឹងជាពេទ្យហ្នឹងមុខយ៉ាងម៉េច? ស្លៀកខោអាវយ៉ាងម៉េច? បើមើលទៅខោអាវខ្មៅតែទាំងអស់គ្នា មិនដឹងអ្នកណាពេទ្យ មិនពេទ្យ។ បើខ្ញុំឈឺខ្ញុំរងាអី គឺខ្ញុំទៅតាមរយៈមេក្រុមរបស់ខ្ញុំ។ បើ

មេក្រុមរបស់ខ្ញុំហ្នឹងថាគេស្គាល់ពេទ្យ បើដូចខ្ញុំមិនដែលស្គាល់ពេទ្យទេ។ សម័យបីឆ្នាំហ្នឹងគឺសោះតែម្តង។

**ស៖** ខ្ញុំត្រឡប់មកនិយាយអំពីចម្លើយរបស់លោកមុននេះបន្តិច។ មុននេះលោកបានឆ្លើយបញ្ជាក់អំពីកន្លែងដែលលោកឈរជើងនៅពេលដែលលោកធ្វើការនៅការដ្ឋានសាងសង់ទំនប់ត្រពាំងថ្ម។ ដូច្នេះត្រឹមត្រូវដែរឬទេ បើខ្ញុំនិយាយថា លោកមិនដឹងអំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងកងរបស់លោកទេ គឺលោកដឹងតែរឿងអ្វីដែលមេកងលោកបញ្ជាឲ្យលោកធ្វើតែប៉ុណ្ណោះ ឯរឿងអីផ្សេងទៀតក្រៅពីនេះ គឺលោកអត់ដឹងទេ។ តើមែនទេ?

**ឆ៖** បាទ។

[១៤:៣៤:៥០]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកសាក្សីដែលបានឆ្លើយបញ្ជាក់នេះ ខ្ញុំមិនរំខានលោកតទៅទៀតទេ។

សូមប្រគល់វេទិកានេះជូនមេធាវី គង់ សំអុន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន សូមគោរពអង្គជំនុំជម្រះ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរខ្លីទេ។ ខ្ញុំចង់សួរបញ្ជាក់លោកទាក់ទងទៅនឹងការឆ្លើយបំភ្លឺរបស់លោក ថានៅក្នុងក្រុមការងាររបស់លោកហ្នឹងមានមេពួក មានមេក្រុម មានមេកង មានកងតូច កងធំ ហើយនិងមានកងវរៈ។ ហើយលោកក៏បានរៀបរាប់មួយចំនួនអំពីឈ្មោះមេពួក ប៉ុន្តែលោកអត់ស្គាល់ឈ្មោះមេក្រុម មេកងតូចជាដើម។ ខ្ញុំចង់សួរបញ្ជាក់ថាតើមេពួក ឬក៏មេក្រុម ឬក៏មេកងតូច មេកងធំហ្នឹង ជាកុមារក្នុងវ័យដូចលោកដែរ ឬក៏ជាមនុស្សពេញវ័យ?

**លោក ស៊ុត សុផល៖**

**ឆ៖** បាទ មេកងហ្នឹង គឺថាមនុស្សកុមារដែរ ក៏ប៉ុន្តែដូចថាគេមានវ័យរាង ដូចថាគេរាងធំ ខ្ពស់អីអីចឹងទៅ ក៏ប៉ុន្តែឈ្មោះគឺថាកុមារដែរ ប៉ុន្តែគេដូចថាវាខ្ពស់ វាធំអីចឹងទៅ គេឲ្យចាត់ធ្វើជាប្រធានអីចឹងទៅ។

[១៤:៣៦:២៤]

**ស៖** ខ្ពស់ធំ លោកសំដៅទៅលើមាឌ ឬសំដៅទៅលើអាយុ?

**ឆ៖** បាទ សំដៅទៅលើកម្ពស់ ហើយនិងមាឌ។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំចង់សួរពីថ្នាក់កងវរៈដែលលោកបានបញ្ជាក់ថាមាន៣០០នាក់។ លោកចាំថាក្នុងរចនាសម្ព័ន្ធហ្នឹងមានលេខ មានអីសម្គាល់វរៈរបស់គាត់លោកទេ?

**ឆ៖** បាទ ព្រោះខ្ញុំអង្គាល់នោះវាភ្លេចអស់ហើយ ព្រោះខ្ញុំមិនចាំលេខវរៈ លេខកង លេខក្រុមអី មិនចាំទេ វាច្រើនឆ្នាំណាស់ទៅហើយ ភ្លេចអស់។

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់ពីព្រឹកមិញ ទាក់ទងទៅនឹងមេក្រុម ដែលលោកថា មេក្រុមមិនធ្វើការទេ ហើយគេអង្គុយចាំមើល ហើយនិងដាស់តឿនលោកឲ្យធ្វើការ។ ខ្ញុំចង់សួរបញ្ជាក់ថា តើលោកដឹងការងាររបស់មេក្រុមធ្វើអីផ្សេងទៀតទេ?

**ឆ៖** បាទ ខ្ញុំដឹងការងារគេ គឺអង្គុយមើលយើងហ្នឹងឯង។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងមេពួក លោកនិយាយថាបើសិនជាលោកឈឺ លោកត្រូវសុំថ្នាំ ឬក៏ប្រាប់ទៅមេពួកដើម្បីឲ្យគេយកថ្នាំឲ្យ។ លោកដឹងថាមេពួកទៅយកថ្នាំពីកន្លែងណាដែរទេ?

[១៤:៣៩:១៥]

**ឆ៖** បាទ ព្រោះខ្ញុំគ្រាន់តែបានថាសមមិត្តមេពួក ខ្ញុំឈឺពោះ ហើយខ្ញុំប្រាប់គេអ៊ីចឹងទៅ ក៏ខ្ញុំរែកដីឡើងទៅ។ ស្រាប់តែគេហ្នឹង គេសុំបន្តទៅមេក្រុម ថាខ្ញុំមានកូនពួកខ្ញុំហ្នឹងវាឈឺ។ ស្រាប់តែមកវិញរែកពីរដងបីដង អាហ្នឹងបានឃើញគេឲ្យថ្នាំ ឃើញមេពួកហ្នឹង គេអ្នកឲ្យ មិនមែនមេក្រុមទេ។ មេពួកគេឲ្យ មេក្រុមគេហុចមកមេពួកអ៊ីចឹងទៅ មេពួកគេឲ្យមកខ្ញុំលេបទៅ។ ត្រង់ដែលគេទៅយកកន្លែងណា គេបើកកន្លែងណា ខ្ញុំអត់ដឹង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំមានចំណុចមួយចង់សួរលោកទាក់ទងទៅនឹង តាវ៉ាល់ ដែលលោកនិយាយថា លោកមិនដែលជួបមុខគាត់ទេ ប៉ុន្តែមានពេលខ្លះ លោកនិយាយពីថា លោកធ្វើការ សូម្បីតែជីកស្រះនៅក្នុងពេលចុងក្រោយ ក៏លោកជីកស្រះហ្នឹង ដែលមានឈ្មោះថា ជាស្រះរបស់ តាវ៉ាល់ ដែរ។ ហើយលោកបានបញ្ជាក់កន្លងមកថា តាវ៉ាល់ គឺជាអ្នកគ្រប់គ្រងនៅក្នុងការដ្ឋាននោះ រហូតដល់ចុងក្រោយនៃការបែករបបនោះ។ ខ្ញុំចង់សួរថា លោកដឹងពីឈ្មោះ តាវ៉ាល់ ហ្នឹងដោយរបៀបណា?

**ឆ៖** បាទ អាហ្នឹងឮតែតៗតាមគ្នាមក គេថាពួកយើងស្អែក ព្រោះ តាវ៉ាល់ ហ្នឹងគេមកធ្វើស្អីទេ

មកបើកឲ្យយើងជីកស្រះហ្នឹង ដឹងគេថាម៉េច អង្គមីទ្មិង បើកអង្គមីទ្មិង ដើម្បីនឹងបើកស្រះជីកឲ្យយើងជីកស្រះស្អែក ថាស្អែក តាវ៉ាល់ មកទៀតហើយ។ ហើយមុខមាត់ តាវ៉ាល់ ខ្ញុំមិនដែលឃើញ ព្រោះមនុស្សវាច្រើនដែលជីកស្រះហ្នឹង ប្រជាជន ប៉ុន្តែមានមិនដែលឃើញ តាវ៉ាល់ អីមកផង ឃើញតែមេក្រុម មេកង មេវរៈ តែប៉ុណ្ណឹង។ ប៉ុន្តែគ្រាន់តែថា ឮតែឈ្មោះ តាវ៉ាល់ៗ មិនដែលឃើញ តាវ៉ាល់ ទេ។ មិនដឹងថារូបរាងគាត់យ៉ាងម៉េច កម្ពស់គាត់យ៉ាងម៉េច អត់ដែលឃើញ។ បើនិយាយតែឃើញជាប់ តែមេកងធំ កងតូច ហើយនិងមេក្រុមអីហ្នឹង តែប៉ុណ្ណឹងឯង អាហ្នឹងឃើញនៅជាប់ជាមួយពួកខ្ញុំរាល់ថ្ងៃ។ បើ រ៉ុល, វ៉ាល់ ហ្នឹងមិនដែលឃើញទេ។

[១៤:៤១:៤៧]

**ស៖** បាទ សូមអរគុណ។ លោកនិយាយអំពីការជីកស្រះ ដែលលោកហៅថា ស្រះតាវ៉ាល់ ហ្នឹង លោកចាំពីកាលបរិច្ឆេទ ពេលវេលា អាចថាជាឆ្នាំ ឬក៏ជាខែជាក់លាក់បានទេ?

**ឆ៖** បាទ បើឆ្នាំ បើខែអាហ្នឹង ថ្ងៃអីអត់ចាំទេ បើចាំ ចាំកន្លែងស្រះតែម្តង។

**ស៖** លោកអាចបញ្ជាក់ទីតាំងស្រះហ្នឹងបានទេ?

**ឆ៖** បាទ ទីតាំងស្រះហ្នឹង បើខ្ញុំមិនច្រឡំទេ ខ្ញុំថានៅពីខាងលិចសាលាក្រហម។

**ស៖** លោកអាចបញ្ជាក់ទីតាំងសាលាក្រហមហ្នឹង នៅកន្លែងណាទេ?

**ឆ៖** បាទ សាលាក្រហមហ្នឹង គឺនៅស្ថិតនៅក្នុងស្រុកសិរីសោភ័ណ បច្ចុប្បន្ននៅខេត្តបន្ទាយមានជ័យ។

**ស៖** សាលាក្រហមនៅជិតទីរួមស្រុក តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ មិនមែនជិតទេ ឆ្ងាយដែរ។

**ស៖** លោកអាចបញ្ជាក់ពីចម្ងាយបានទេ ថាពីសាលាក្រហមមកខេត្តបន្ទាយមានជ័យ ទីរួមខេត្តបន្ទាយមានជ័យហ្នឹងប៉ុន្មានគីឡូម៉ែត្រ?

**ឆ៖** បាទ មិនដឹងជាប៉ុន្មានគីឡូម៉ែត្រទេ ប៉ុន្តែខ្ញុំថាឆ្ងាយហើយ។

**ស៖** រំលងឃុំ រំលងស្រុកទេ?

[១៤:៤៤:១៩]

**ឆ៖** ទេ មិនដឹងជាម្តុំហ្នឹងដូចមិនមានស្រុក មិនមានភូមិអីទេ ព្រោះបើនៅចម្ងាយពីផ្លូវជាតិយើង ពីរូបដំរីសហ្នឹង វាមកឆ្ងាយមក មកដល់នេះសាលាក្រហមហ្នឹង ក៏ប៉ុន្តែស្រះហ្នឹង វានៅស្ថិតនៅ

ខាងត្បូងផ្លូវ។ យើងទៅពីនេះ នៅខាងឆ្វេងដៃ ប៉ុន្តែអារឿងឆ្ងាយ វាកាត់ស្មានវាមិនត្រូវបង។

**សៈ** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីចម្ងាយ ពីទំនប់ត្រពាំងថ្មមកស្រះហ្នឹងបានទេ កន្លែងសាលាក្របាមលោកមានប្រសាសន៍ហ្នឹង មានចម្ងាយប៉ុន្មានដែរ?

**ឆៈ** អ៊ូ! ឆ្ងាយ មិនដឹងប៉ុន្មានគីឡូទេ ចុះវានៅឯកើត ត្រពាំងថ្មវាស្ថិតនៅក្នុងស្រុកព្រះនេត្រព្រះ ដល់ស្រះតាវ៉ាល់ ក្រោយហ្នឹង វាស្ថិតនៅក្នុងស្រុកសិរីសោភ័ណ ហើយវានៅខាងលិចមន្ទីរស្រុកទៀត។ បើវាឆ្លងអាប្រឡោះកណ្តាលហ្នឹង មិនដឹងប៉ុន្មានគីឡូ ខ្ញុំម៉េចមិនដឹង។

**សៈ** លោកអាចឆ្លើយបានថា វាឆ្ងាយជាង៥០គីឡូម៉ែត្រ ឬក៏ជិតជាង៥០គីឡូម៉ែត្រ?

**ឆៈ** បាទ មិនដឹងប៉ុន្មានទេបង ដឹងឆ្លើយថាម៉េច បើវា ដឹងថាវាឆ្ងាយ ប៉ុនមិនដឹងជាប៉ុន្មានគីឡូម៉ែត្រ ដឹងម៉េចដឹង ប៉ុន្តែអារឿងឆ្ងាយ ដឹងតែឆ្ងាយហើយ។

[១៤:៤៦:០៤]

**សៈ** បាទ សូមអរគុណ។ ខ្ញុំចង់បញ្ជាក់ចំណុចមួយ ទាក់ទងទៅនឹងពេលវេលាដែលលោកធ្វើការនៅក្នុងទំនប់ត្រពាំងថ្ម។ នៅពេលដែលលោកស្រីចៅក្រម ហ្វេនស៍ សួរលោក លោកហាក់ដូចជាមិនមានភាពច្បាស់លាស់អំពីរយៈពេល ថាតើលោកធ្វើការនៅទីនោះរយៈពេលប៉ុន្មានទេ។ ប៉ុន្តែក្រោយមកមានការឆ្លើយបញ្ជាក់ថា លោកធ្វើការមួយរដូវ ហើយលោកបានបញ្ជាក់ថា រដូវដែលលោកធ្វើការនោះជារដូវប្រាំង ហើយកាលណារដូវវស្សា គេឲ្យលោកទៅធ្វើស្រែវិញ ទៅកន្លែងផ្សេង។ ហើយសំណួរបានសួរបញ្ជាក់ពីរឿងខែជាក់លាក់ លោកមិនអាចចាំបានទេ ប៉ុន្តែខ្ញុំចង់សួរបញ្ជាក់ទៅលើកាលៈទេសៈណាមួយដែលលោកអាចចាំ ពីពេលចាប់ផ្តើម និងពេលបញ្ចប់ ក្នុងរយៈពេលរដូវប្រាំងមួយដែលលោកធ្វើការនៅទំនប់ត្រពាំងថ្មនោះ។ លោកមានចាំកាលៈទេសៈណាមួយជាក់លាក់ទេ?

**ឆៈ** ខ្ញុំដែលចាំថារដូវប្រាំង ខ្ញុំចាំច្បាស់ថាត្រង់រដូវប្រាំង រដូវអត់ភ្លៀងហ្នឹងឯង ដែលច្បាស់ជាងគេ។ ដល់រឿងខែ រឿងថ្ងៃ អាហ្នឹងមិនដឹងច្បាស់។

**សៈ** បាទ ខ្ញុំយល់ថា លោកអត់ចាំថ្ងៃខែទេ ប៉ុន្តែខ្ញុំចង់ដឹងថា ក្រែងលោកចាំនូវកាលៈទេសៈនូវព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈសម្គាល់ជាក់លាក់អំពីកាលបរិច្ឆេទ ពីពេលវេលានោះបាន។ បើលោកចាំ លោកបញ្ជាក់មក បើលោកមិនចាំទេ លោកថាអត់មាន អត់ចាំបានទេ។ អាហ្នឹងខ្ញុំក៏ឈប់សួរដែរបាទ។

**ឆៈ** បាទ ខ្ញុំអត់ចាំទេ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

[១៤:៤៨:២២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយសវនាការស្ដាប់សក្ខីកម្មសាក្សី ស៊ុត សុផល បានដល់ទីបញ្ចប់ហើយ ហើយអង្គជំនុំជម្រះអរគុណលោក ស៊ុត សុផល ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ ក្នុងឋានៈជាសាក្សីក្នុងរយៈពេលពីរថ្ងៃកន្លងមកនេះ។ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនូវរឿងក្ដីនេះ។ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ ហើយសូមលោក ស៊ុត សុផល ជួបតែសំណាងល្អ បានសេចក្ដីសុខ សេចក្ដីចម្រើន។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនលោក ស៊ុត សុផល វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយជាបន្តនេះ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយសវនាការក្រោយនេះ អង្គជំនុំជម្រះនឹងពិភាក្សាស្ដាប់សេចក្ដីសន្និដ្ឋានរបស់ភាគីពាក់ព័ន្ធនឹងបញ្ហាមួយចំនួន និងស្ដាប់បង្ហាញអំពីសំណើសុំរបស់សហមេធាវីការពារក្ដី ខៀវ សំផន។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៥០ នាទី ដល់ម៉ោង ១៥:០៥ នាទី)*

[១៥:០៦:០៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធី។ ហើយដូចដែលអង្គជំនុំជម្រះបានជូនដំណឹង

តាមរយៈអ៊ីម៉ែលដោយមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី២៥ និង ២៨ និង ៣០ ខែកញ្ញា ឆ្នាំ២០១៥នេះរួចហើយ គឺនៅរសៀលនេះអង្គជំនុំជម្រះសាលាដំបូងនឹងធ្វើសវនាការស្តាប់សេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ភាគីទៅលើបញ្ហាចំនួនបី។ ទី១ សេចក្តីសន្និដ្ឋានរបស់ភាគីទៅលើសំណើសុំរបស់លោកមេធាវីក្រុមមេធាវី នួន ជា ដែលបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាស្តាប់សក្ខីកម្មបន្ថែមចំនួនបុគ្គលមួយរូប ពាក់ព័ន្ធនឹងអង្គហេតុការដ្ឋានការងារទំនប់ត្រពាំងថ្ម អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ឯកសារ E368។ ទី២ សេចក្តីសន្និដ្ឋានរបស់ភាគីទៅលើលិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៃ អ.វ.ត.ក ជុំវិញនីតិវិធីនៃការប្រព្រឹត្តទៅក្នុងការស្តាប់សក្ខីកម្មអ្នកជំនាញដែលមានរហស្សនាម 2-TCE-95 នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E367/1។ និងទី៣ ការដាក់បង្ហាញឯកសារចំនួន១១ ពីសំណុំរឿង០០៤ មកក្នុងសំណុំរឿង០០២/០២ ដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងអង្គហេតុនៃការប្រព្រឹត្តលើក្រុមមនុស្សគោលដៅជាក់លាក់ចំពោះជនជាតិចាម ឯកសារ E319/33។ ហើយនិងបញ្ហាចុងក្រោយគឺមានស្តាប់នូវសំណើសុំរបស់សហមេធាវីការពារក្តីលោក ខៀវ សំផន ពាកព័ន្ធនឹងបញ្ហាមួយចំនួន។

បាទ ជាដំបូងនេះ អង្គជំនុំជម្រះយកបញ្ហាទី១មកពិភាក្សា ហើយដំបូងនេះអង្គជំនុំជម្រះសូមសួរទៅភាគីថា តើភាគីមានបំណងឆ្លើយតបទៅនឹងសំណើសុំរបស់មេធាវីការពារក្តី នួន ជា ដែរឬទេលើបញ្ហានេះ? ហើយដំបូងនេះ ដើម្បីឱ្យមានការច្បាស់លាស់បន្ថែមទៀត អង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅសហមេធាវីការពារក្តី នួន ជា ដើម្បីបង្ហាញដោយសង្ខេបនូវសំណើសុំនិងមូលហេតុនៃការស្នើសុំឱ្យអង្គជំនុំជម្រះស្តាប់សក្ខីកម្មសាក្សីមួយរូបបន្ថែមទៀត ពាក់ព័ន្ធនឹងអង្គហេតុការដ្ឋានការងារទំនប់ត្រពាំងថ្ម។

[១៥:០៨:៥៦]

**លោក វ៉ិចទ័រ កូប៉េះ**

បាទ សូមអរគុណលោកប្រធាន ខ្ញុំគិតថាខ្ញុំមិនមានអ្វីដែលត្រូវបន្ថែមច្រើនបន្ថែមទៅលើសំណើសុំរបស់យើងខ្ញុំទេ ដោយសារថាសំណើសុំនេះត្រូវបានជជែកតវ៉ារួចហើយៗ។ សាក្សីនេះគាត់អាចមានសក្ខីកម្មពាក់ព័ន្ធទៅនឹងការដ្ឋានទំនប់ត្រពាំងថ្ម គាត់នឹងអាចផ្តល់ភស្តុតាងគួរឱ្យចាប់អារម្មណ៍ពាក់ព័ន្ធដូចជារចនាសម្ព័ន្ធការងារនៅការដ្ឋាននោះ ហើយនិងអាចផ្តល់សក្ខីកម្មពាក់ព័ន្ធទៅនឹងស្ថានភាពទូទៅនៅភូមិភាគពាយ័ព្យ។ ដូច្នេះ ខ្ញុំយល់ឃើញថា សាក្សីមួយរូបនេះគឺជាសាក្សីដែលសំខាន់ ហើយគួរតែមក

បង្ហាញមុខនៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីផ្តល់សក្ខីកម្ម។ ដូច្នេះឯងខ្ញុំបាទមិនមានអ្វីបន្ថែមច្រើនពីលើទៀតទេលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីមានឱកាសចង់ធ្វើការកត់សម្គាល់ ឬឆ្លើយតបទៅនឹងសំណើសុំរបស់មេធាវីការពារក្តីលោក នួន ជា អំពីបញ្ហាដែលលើកឡើងអម្បាញ់មិញនេះដែរឬទេ? សូមអញ្ជើញ បាទ!

[១៥:១០:២៦]

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់ឃើញថា ខ្ញុំក៏លើកឡើងជាសង្ខេបដែរ។ សហព្រះរាជអាជ្ញាមិនជំទាស់ទៅសំណើសុំរបស់សហមេធាវីការពារក្តី ដើម្បីស្តាប់សក្ខីកម្មសាក្សីមួយរូបនេះបន្ថែមទៀតនោះទេ ដោយហេតុថានៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ និងចម្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គឺថាមានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ ហើយឯកសារទាំងអស់នេះ ត្រូវបានប្រើប្រាស់រួមជាមួយនឹងសាក្សីមួយចំនួនទៀត។ យើងយល់ឃើញថាសំណើសុំនេះជាសំណើសុំសមហេតុសមផល។ ប្រហែលជាចំណុចចម្បងរបស់សាក្សីនេះ គឺថាសាក្សីនេះអាចនិយាយពាក់ព័ន្ធទៅនឹងផែនការនៃការឆើបបះបោរ។ ដូច្នេះទាក់ទងដោយសារហេតុផលនេះ យើងខ្ញុំសូមលើកឡើងថា សំណើសុំនេះជាសំណុំសមហេតុផល យល់ស្របថាឲ្យអង្គជំនុំជម្រះកោះហៅសាក្សីរូបនេះ។ ថាតើយើងបើសិនណាជាមេធាវីការពារក្តីយកសក្ខីកម្ម ពាក់ព័ន្ធទៅនឹងការដ្ឋានទំនប់ត្រពាំងថ្មជាភស្តុតាងដោះបន្ទុកនៅនេះគឺថា ក៏ត្រូវតែស្វែងរកឲ្យឃើញនូវភស្តុតាងដាក់បន្ទុកក្នុងពេលជាមួយគ្នានោះផងដែរ។ សរុបសេចក្តីមកវិញ យើងខ្ញុំមិនជំទាស់ទៅនឹងសំណើសុំរបស់មេធាវីការពារក្តីទេ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ចុះក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ខាងមេធាវីនាំមុខមិនមានអ្វីជាការកត់សម្គាល់ ឬក៏ជាការជំទាស់ចំពោះសំណើសុំនេះទេ។ បាទ សូមអរគុណ។

[១៥:១២:១២]

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្ដីលោក ខៀវ សំផន ដូចទំនងមិនមានបញ្ហាអីទេ ព្រោះភាគីម្ចាស់សំណើ និងភាគីដទៃទៀតមិនមានបញ្ហា។ មានអីទេ? បើមានសូមអញ្ជើញបាទ!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន យើងអាស្រ័យលើតែអង្គជំនុំជម្រះទេលោកប្រធាន អត់មានយោបល់អីទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយឥឡូវនេះឈានចូលដល់បញ្ហាទី២ យកមកពិភាក្សា គឺពាក់ព័ន្ធទៅនឹងខ្លឹមសារនៃលិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មុននឹងសម្រេចថាតើការដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់អ្នកជំនាញដែលមានរហស្សនាម 2-TCE-95 ត្រូវប្រព្រឹត្តិទៅដូចម្ដេចនោះ។ អង្គជំនុំជម្រះមានបំណងស្ដាប់នូវមតិយោបល់របស់ភាគីជាមុនសិន ហើយដំបូងនេះស្ដាប់នូវមតិយោបល់របស់ភាគីសហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងបញ្ហានេះ។

[១៥:១៣:១៩]

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីទាំងអស់គ្នា។ សហព្រះរាជអាជ្ញាបានអានលិខិតនេះហើយ គឺលិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ យើងខ្ញុំជឿជាក់ថាសូមស្នើឲ្យមានវត្តមានរបស់មន្ត្រីច្បាប់ជាការសមហេតុផល។ យើងយល់ឃើញថាការស៊ើបអង្កេតគឺជាកិច្ចការសម្ងាត់ មិនមែនជាសេចក្ដីសម្រេចដោយឆន្ទានុសិទ្ធិរបស់គាត់នោះទេ ប៉ុន្តែជាសេចក្ដីសម្រេចដែលអនុលោមតាមច្បាប់របស់ អ.វ.ត.ក។ ខ្ញុំយល់ឃើញថា មិនមានបញ្ហាអ្វីធំដុំនោះទេ ពាក់ព័ន្ធទៅនឹងការបង្ហាញនូវព័ត៌មានសម្ងាត់។ សហព្រះរាជអាជ្ញាមិនមានផែនការអ្វីទៅសួរដល់អ្នកជំនាញអំពីអ្វីដែលអ្នកប្រជាជនបានឆ្លើយមក សាក្សីឆ្លើយមកឲ្យសហចៅក្រមស៊ើបអង្កេតនោះទេ។ ដោយសារថា ពួកគាត់ថាឆ្លើយសម្រាប់តែពួកគាត់។ ដូច្នេះ យើងខ្ញុំនឹងសួរសំណួរមួយចំនួនទៅកាន់អ្នកជំនាញពាក់ព័ន្ធទៅនឹងជនជាតិចាម ដោយអាស្រ័យទៅលើការងាររបស់គាត់ គាត់បានសរសេរសៀវភៅពីរក្បាល ហើយគាត់បានធ្វើកិច្ចសម្ភាសន៍នៅខាងក្រៅការិយាល័យសហចៅក្រមស៊ើបអង្កេតនេះជាច្រើនដង។ ប៉ុន្តែការព្រួយបារម្ភរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនេះ គឺដោយសារថា ខ្ញុំយល់ឃើញថាអាស្រ័យទៅលើអង្គជំនុំជម្រះទេ គឺថាត្រូវតែមានវត្តមានរបស់មន្ត្រីច្បាប់ពាក់ព័ន្ធទៅនឹងការស្នើសុំឲ្យបង្ហាញនូវ

ព័ត៌មានសម្ងាត់ទាំងនេះ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយចុះក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានមតិយោបល់អ្វីដែរទេ លើខ្លឹមសារនៃលិខិតរបស់ចៅក្រម សហចៅក្រមស៊ើបអង្កេតអន្តរជាតិនេះ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនមានការកត់សម្គាល់ជាក់លាក់អីទេទៅនឹងលិខិតនេះ។ យើងអាស្រ័យទៅលើវិចារណញ្ញាណនៃអង្គជំនុំជម្រះតែប៉ុណ្ណឹងទេ លោកប្រធាន អត់មានគំនិតយោបល់អ្វីទេ។

[១៥:១៥:៤៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះក្រុមសហមេធាវីការពារក្តីលោក នួន ជា មានមតិយោបល់អ្វីដែរទេទៅលើខ្លឹមសារនៃលិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលពាក់ព័ន្ធនឹងការស្តាប់សក្ខីកម្មអ្នកជំនាញ 2-TCE-95 នាពេលខាងមុខ ពាក់ព័ន្ធជាមួយនឹងសំណុំរឿង០០៣, ០០៤?

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំមិនទាន់ជឿជាក់នៅឡើយថា វាងាយដូចអ្វីដែលលោកសហព្រះរាជអាជ្ញាទើបតែរៀបរាប់នោះទេ ប៉ុន្តែដំបូង សូមឱ្យខ្ញុំអនុញ្ញាតឱ្យខ្ញុំលើកឡើងថាវាមានបញ្ហាសម្ងាត់នៅក្នុងសំណុំរឿង០០៤ វាមានការជជែកតវ៉ាគ្នារួចមកហើយ ក៏ប៉ុន្តែលោក ឧស្មាន នេះត្រូវមកផ្តល់សក្ខីកម្មក្នុងឋានៈជាអ្នកជំនាញ។ ដូច្នេះកាតព្វកិច្ច គាត់មានកាតព្វកិច្ចផ្ទាល់ខ្លួនដើម្បីបង្ហាញជូនតុលាការ។ ដូច្នេះវាអាស្រ័យទៅលើគាត់ ថាតើចម្លើយរបស់គាត់ វាអាចនឹងបំពានទៅដល់វិធានស្តីអំពីភាពសម្ងាត់នៃកិច្ចស៊ើបសួរដែរឬក៏យ៉ាងណា។ ដូច្នេះ ខ្ញុំយល់ឃើញថាភាគីទាំងអស់គួរត្រូវបានអនុញ្ញាតឱ្យសួរសំណួរទាំងឡាយណាដែលខ្លួនចង់សួរ។ ហើយបន្ទាប់មក វាអាស្រ័យទៅលើលោក ឧស្មាន ខ្លួនឯង ថាតើគាត់ត្រូវឆ្លើយសំណួរទាំងនោះឬក៏អត់។ តើបើការឆ្លើយទៅនាំឱ្យគាត់មានបញ្ហា ឬក៏យ៉ាងណាហើយវាក៏អាស្រ័យទៅលើអង្គជំនុំជម្រះថា ត្រូវសំណួរណាមួយដែលមិនត្រូវអនុញ្ញាតឱ្យគាត់ឆ្លើយ ឬក៏យ៉ាងណា។ បញ្ហាអាចនឹងកើតមានឡើងហើយ ហើយជាពិសេសបញ្ហាវាកើតមានឡើងនៅពេលដែលសួរសំណួរផ្ទាល់តែម្តង។ អនុញ្ញាតឱ្យខ្ញុំផ្តល់ឧទាហរណ៍មួយ កាលពីមុននោះ ក្នុងសំណុំរឿងរបស់យើង

នៅចំពោះមុខអង្គជំនុំជម្រះ យើងនិយាយអំពីព្រឹត្តិការណ៍នៅវត្តអូរត្រកួន ហើយយើងទាំងអស់គ្នាក៏ដឹងដែរ ថាវត្តមួយនេះវាជាផ្នែកមួយនៃកិច្ចស៊ើបសួរនៃសំណុំរឿង០០៤។ បើសិនណាជាខ្ញុំសួរគាត់នូវពាក្យពេចន៍ទូទៅ ថាតើគាត់ដឹងអ្វីពីរចនាសម្ព័ន្ធនៃការបញ្ជានៅវត្តអូរត្រកួន គាត់អាចនឹងប្រឈមនឹងបញ្ហាហើយ ដោយសារថាប្រធានបទដដែលនេះកំពុងតែស្ថិតនៅក្នុងកិច្ចស៊ើបសួរដែរនាពេលបច្ចុប្បន្ននេះ។

[១៥:១៨:៥២]

ដូច្នេះយោងទៅតាមទ្រឹស្តី វាអាចនឹងមិនមានបញ្ហាទេ ក៏ប៉ុន្តែនៅពេលសួរសំណួរអនុវត្តជាក់ស្តែង អាចនឹងមានបញ្ហាកើតឡើងនៅពេលពិភាក្សាដេញដោលនោះ។ ដូច្នេះថាតើចម្លើយរបស់គាត់អាចនឹងត្រូវហាមឃាត់មិនឲ្យគាត់ឆ្លើយ ដោយអនុលោមទៅតាមវិធានស្តីអំពីវិធានសម្ងាត់ដែរឬក៏អត់នោះ។ ដូច្នេះបញ្ហា គឺថាយើងទាំងពីរនាក់កំពុង យើងពីរក្រុមមានបញ្ហាពាក់ព័ន្ធទៅនឹងផ្នែកណាមួយនៃសំណុំរឿងដែលកំពុងស៊ើបសួរ០០៤ នេះឯង។ ប៉ុន្តែខ្ញុំវាមិនប្រាកដថា ឧទាហរណ៍ដែលខ្ញុំលើកឡើងជាក់ស្តែងនេះ វានឹងកើតឡើងដោយរបៀបណាទេ ពីព្រោះនៅពេលដែលគាត់ឆ្លើយនោះ វាអាចនឹងមានបញ្ហាកើតឡើង នេះជាបច្ចេកទេស ប៉ុន្តែខ្ញុំមិនអាចទស្សន៍ទាយបានមុននោះទេ។ ប៉ុន្តែនឹងមានការទម្រង់នៃការតាំងសំណួរជាទូទៅហើយ។ គ្រាន់តែខ្ញុំចង់ដឹងថាតើវាមិន -- ថាតើមិនអនុញ្ញាតឲ្យគាត់ឆ្លើយផ្នែកណាមួយដែរឬក៏អត់ ពាក់ព័ន្ធទៅនឹងវត្តអូរត្រកួន ហើយនិងតំបន់៤១នេះ។

ទាក់ទងទៅនឹងសំណួរសួរថាតើគួរតែមានអ្នកណាម្នាក់ដែលលើកឡើងថាមន្ត្រីច្បាប់គួរតែអង្គុយអមជាមួយគាត់ ខាងយើងខ្ញុំយល់ថាមិនមានបញ្ហាអ្វីទេ។ មានករណីច្បាប់ពីតុលាការ អាយ.ស៊ី.ធី.វ៉ាយ ក្នុងលក្ខណៈប្រៀបធៀបមួយនោះ គឺថានីតិវិធីក្នុងការប្តឹងសាទុក្ខនៅក្នុងរឿងក្តីរបស់ មីឡូសីវិច តែម្តងដែលមន្ត្រីរដ្ឋាភិបាលពីរនាក់មានវត្តមាននៅក្នុងបន្ទប់សវនាការ នៅពេលដែលសាក្សីកំពុងតែឆ្លើយទៅនឹងសំណួរ។ អង្គជំនុំជម្រះសាលាកំពូល ថាទោះបីជាមិនមានបទប្បញ្ញត្តិចែងអំពីបញ្ហានេះក៏ដោយ អង្គជំនុំជម្រះសាលាដំបូងនៅទីនោះ ពេលនោះគឺអនុញ្ញាតឲ្យមានមន្ត្រីរដ្ឋាភិបាលពីរនាក់មានវត្តមាននៅក្នុងបន្ទប់សវនាការ។ ខ្ញុំយល់ឃើញថា មន្ត្រីរដ្ឋាភិបាលនេះមិនត្រូវធ្វើអន្តរាគមន៍ណាមួយ ត្រូវឆ្លើយសំណួរនេះមិនត្រូវឆ្លើយសំណួរនោះៗទេ។ ការដែលខ្ញុំលើកឡើងដូច្នេះ គឺថាបញ្ហាវានឹងអាចកើតមានឡើង។ ខ្ញុំដឹងថាមន្ត្រីច្បាប់ គឺត្រូវតែជាមនុស្សម្នាក់ដែលត្រូវមានវត្តមាន ហើយជួយដល់អ្នកជំនាញរូបនេះ។

[១៥:២២:០៩]

នៅក្នុងយុត្តាធិការរបស់ខ្ញុំគឺ មេធាវីតំណាងឲ្យសាក្សីដែលអាចផ្តល់ប្រឹក្សាទៅដល់សាក្សីគួរឆ្លើយ

សំណួរណា និងមិនគួរឆ្លើយសំណួរណា។ ខ្ញុំចង់ដឹងថាតើកញ្ញា ជូអ៊ីង (តាមសូរស័ព្ទ) នេះត្រូវបានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងអនុញ្ញាតឲ្យផ្ដល់ប្រឹក្សាទៅដល់អ្នកជំនាញហើយឬនៅ។ ចំណុចនេះត្រូវតែស្វែងយល់ទាំងអស់គ្នា ហើយត្រូវតែរកឲ្យឃើញថាតើបានទទួលស្គាល់នៅ។ ហើយអ្នកជំនាញអង្គុយនៅចំពោះមុខអង្គជំនុំជម្រះក្នុងតួនាទី និងឋានៈរបស់គាត់ជាអ្នកជំនាញ។ តែបើសិនណាជាមានអ្នកណាម្នាក់មកអមគាត់ ជួយដល់គាត់ត្រូវតែជាមេធាវីដែលត្រូវបានគណៈមេធាវីទទួលស្គាល់ អនុវត្តច្បាប់ឲ្យប្រកបវិជ្ជាជីវៈរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជាទ្រឹស្ដីសរុបមកវិញ ជាទ្រឹស្ដីអាចនឹងមានបញ្ហា តែជាការអនុវត្តជាក់ស្ដែងអាចនឹងជួបប្រទះបញ្ហា។ អ៊ីចឹងឯងថា តើយើងគួរតែចាត់ចែងកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធទៅនឹងការសួរអ្នកជំនាញរូបនេះដោយរបៀបណា ពាក់ព័ន្ធទៅនឹងវត្តអូរត្រកួន ឬក៏តំបន់៤១នោះ។

[១៥:២៣:៤៩]

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន មេធាវីលោក ខៀវ សំផន មានបញ្ហាពីរដែលចោទឡើង។ យើងយល់ច្បាស់ណាស់ថា អំពីលក្ខណៈសម្ងាត់នៃការស៊ើបអង្កេតដែលកំពុងធ្វើ ហើយទន្ទឹមនឹងនោះគឺថាបើសិនជាអ្នកជំនាញរូបហ្នឹងត្រូវបានកោះហៅមកក្នុងឋានៈជាអ្នកជំនាញនោះ ដោយសារគិត -- យើងយល់ថាគាត់មានព័ត៌មានសំខាន់ ទាក់ទងទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះកំពុងតែជំនុំជម្រះចំពោះលោក ខៀវ សំផន ដែលជាជនជាប់ចោទនោះ គឺថាអង្គហេតុ គឺថាពេលដែលកោះហៅសាក្សីនេះមកត្រូវឲ្យបើកសវនាការជាសាធារណៈ ហើយមិនជាសវនាការសម្ងាត់នោះទេ។ ទាក់ទងទៅនឹងកិច្ចសម្ភាសន៍នៃអ្នកជំនាញហ្នឹង ដែលថាគាត់បានសម្ភាសសាក្សីមួយចំនួនដែលបានមកផ្ដល់សក្ខីកម្មនៅទីនេះហើយ អ៊ីចឹងវាមិនមែនជាការលំបាកអ្វីទេ ពីព្រោះថាសាក្សីទាំងអស់នោះនៅក្នុងសំណុំរឿងអស់ហើយ។ ទាក់ទងទៅនឹងចម្លើយមួយចំនួន ទៅនឹងបញ្ហាដូចដែលលោក កូប៉េ បានលើកឡើងជាទូទៅនោះថា បើសិនជាគាត់ជាអ្នកជំនាញ ហើយបើយើងចាត់ទុកគាត់ថាជាអ្នកជំនាញនោះ គាត់គួរតែអាចមកផ្ដល់សក្ខីកម្ម មិនបាច់មានជំនួយការពីអ្នកណាទេ។ គាត់ត្រូវដឹងថាគាត់អាចនិយាយអ្វីបាន អ្វីដែលគាត់និយាយមិនបាននោះ។ អ៊ីចឹងយើងយោងទៅ តែបើយើងមិនគិតដូចជាសាក្សីធម្មតាទេ ចង់និយាយថា បើយើងចាត់ទុកជា គាត់ជាអ្នកជំនាញទៅហើយនោះ។ មេធាវី ខៀវ សំផន ថាមិនចង់ឲ្យគាត់ហ្នឹងចង់មកផ្ដល់សក្ខីកម្មជាអ្នកសាក្សីនោះទេ -- ជាអ្នកជំនាញនោះទេ ត្រឹមសាក្សីបានហើយ ក៏ប៉ុន្តែបើ

អង្គជំនុំជម្រះហ្នឹងចាត់ទុកថាគាត់ជាអ្នកជំនាញហើយនោះ គួរតែឲ្យគាត់មកផ្តល់សក្ខីកម្មដោយឯករាជ្យ មិនបាច់មានអ្នកណាដឹកដៃគាត់មកទេ។ ហើយដោយឲ្យគាត់គោរពលើគោលការណ៍សម្ងាត់របស់គាត់ បើសិនជាគាត់មាននោះ ព្រោះថា យើងជាអ្នកជំនាញទៅហើយ មិនចាំបាច់មាននរណាមកជួយយើងទេ។

[១៥:២៦:០៩]

បើសិនមានមនុស្សម្នាក់ពីការិយាល័យចៅក្រមស៊ើបអង្កេត មកតាមដានកិច្ចដំណើរការនីតិវិធីនៅទីនេះ មិនបញ្ហាអ្វីទេ តែបើសិនមកឲ្យគាត់មកខ្សឹបប្រាប់អ្នកជំនាញថាឲ្យឆ្លើយថារបៀបនេះ របៀបនោះនោះ មើលទៅដូចជាមិនសមស្របនោះទេ ចំពោះការពិភាក្សាផ្លូវច្បាប់នោះ។ នេះគឺជាគោលជំហររបស់ ខៀវ សំផន។ បើសិនជាគាត់មកជាអ្នកជំនាញ គាត់ត្រូវឆ្លើយទៅតាមលទ្ធភាពដែលគាត់ធ្វើអាចទៅបាន ដោយគោរពទៅលើកាតព្វកិច្ចការពារព័ត៌មានសម្ងាត់របស់គាត់។

នេះជាវិធីសាស្ត្រដែលយើងស្នើជូនតុលាការដើម្បីបើកសវនាការនេះ។ អ៊ីចឹងអ្វីដែលមាននៅសំណុំរឿង០២ វគ្គពីរយើងនេះហ្នឹង អ្វីដែលទាក់ទងទៅនឹងអង្គហេតុដែកគេជំនុំជម្រះទៅលើលោក ខៀវ សំផន យើងសង្ឃឹមថាមានភស្តុតាងមួយចំនួន ដែលនៅក្រោមការស៊ើបអង្កេត ហើយវា ហើយអង្គហេតុទាំងអស់នេះ គាត់អត់មានពាក់ព័ន្ធនឹងសំណុំរឿង០៤នោះទេ។ អង្គហេតុដែលគេកំពុងតែស៊ើបអង្កេតនៅក្នុងសំណុំរឿង០៤នោះ ដូចមិនពាក់ព័ន្ធនឹងលោក ខៀវ សំផន នោះទេ។ យើងមានការកត់សម្គាល់ផ្សេងទៀត ទាក់ទងទៅនឹងអ្នកជំនាញនេះ ខ្ញុំដឹងថាលោកប្រធានចង់ឲ្យខ្ញុំធ្វើការកត់សម្គាល់ឥឡូវនេះ ដើម្បីឲ្យភាគីមានលទ្ធភាពឆ្លើយមកខ្ញុំវិញ ឬក៏លោកប្រធានចង់ឲ្យដោះស្រាយបញ្ហានេះមួយសិន មុននឹងធ្វើការកត់សម្គាល់។

**ប្រធានអង្គជំនុំ៖**

ដោះស្រាយបញ្ហានេះមួយសិន។ សូមអញ្ជើញលោកចៅក្រមៗ ហ្វេនស៍!

[១៥:២៨:១៤]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមចូលរួមយោបល់មួយ សម្រាប់ខ្ញុំនិយាយដោយត្រង់ គឺថាមិនទាន់ច្បាស់ទាំងស្រុងនៅឡើយទេ។ បើសិនណាជាអ្នកណាអានសំណើសុំចំណុច(ក) ដែលថា សហចៅក្រមស៊ើបអង្កេតគឺថា យើងមិនអាចសួរសំណួរទាំងឡាយណា ពាក់ព័ន្ធទៅនឹងអ្វីដែលកំពុងតែស៊ើបសួរក្នុងសំណុំរឿង០០៤

បានទេ ទោះបីជាព័ត៌មាននោះបើកចំហ ឬក៏មិនទាន់បើកចំហក្តី។ ហាក់បីដូចជាមានការបញ្ជាក់ផងថា មានការស្នើសុំឲ្យសួរគាត់នៅក្នុងសវនាការជាសម្ងាត់។ ដូច្នេះខ្ញុំគិតថាយើងត្រូវតែបញ្ជាក់ឲ្យបានច្បាស់ តើគាត់ចង់ច្រានចោលព័ត៌មានណាមួយ ឬបញ្ហាណាមួយដែលគាត់យល់ថា ជាព័ត៌មានសម្ងាត់ ឬក៏គាត់យល់ឃើញថាព័ត៌មាននេះ អាចនឹងផ្តល់នៅក្នុងសវនាការជាអសាធារណៈ។

**លោក នីកូឡាស គូមជែន៖**

តាមដែលខ្ញុំយល់លិខិតនេះ គឺថាមេធាវីការពារក្តីហាក់ដូចជាយល់ខុស នូវអ្វីដែលចៅក្រមស្នើសុំឲ្យមន្ត្រីច្បាប់ធ្វើនេះ។ មិនមែនតំណាងឲ្យលោក អ៊ីសា ឧស្មាន ក្នុងឋានៈជាសាក្សីអីទេ គ្រាន់តែតំណាងឲ្យការិយាល័យរបស់គាត់ផ្ទាល់តែម្តងថា ព័ត៌មានសម្ងាត់មកពីការិយាល័យសហចៅក្រមស៊ើបអង្កេតមិនត្រូវបង្ហាញឲ្យគេដឹងនោះទេ។ ហើយនេះ ដោយសារតែបញ្ហាស្មុគស្មាញអាចនឹងកើតចេញនៅពេលសួរសំណួរទៅដល់គាត់នោះ។ ខ្ញុំមិនយល់ឃើញថាសាក្សីជាមេធាវី ហើយចៅក្រម ដែលចង់ឲ្យមេធាវីមន្ត្រីច្បាប់មកពីការិយាល័យរបស់គាត់ផ្ទាល់ ដើម្បី ដូចអ៊ីចឹងឯងមិនអាចត្រូវមានតំណាងណាមួយថាជាមេធាវីតំណាងឲ្យសហចៅក្រមស៊ើបអង្កេតមកជួយដល់អ្នកជំនាញនោះទេ។ ប៉ុន្តែមន្ត្រីច្បាប់នេះ គ្រាន់តែជួយផ្តល់យោបល់ទៅតុលាការថា តើសំណួរណាខ្លះវាអាចនឹងបំពានទៅដល់ភាពសម្ងាត់នៃកិច្ចស៊ើបសួរ ឬក៏អាចថាចម្លើយគាត់ណាមួយវាអាចពាក់ព័ន្ធទៅនឹងភាពសម្ងាត់នេះ ពេលនោះមន្ត្រីច្បាប់នេះអាចនឹងប្រាប់ថាតើគាត់គួរត្រូវអនុញ្ញាតឲ្យឆ្លើយទៅនឹងសំណួរនេះ ឬក៏អត់។ មន្ត្រីច្បាប់មិនមែនតំណាងឲ្យសាក្សីទេ មន្ត្រីច្បាប់ដែលស្នើសុំនេះ គឺតំណាងឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតទាំងមូលតែម្តង។

[១៥:៣១:១៣]

**លោក វ៉ិចទ័រ កូប៉េះ**

គឺអនុញ្ញាតឲ្យខ្ញុំឆ្លើយតបខ្លីទេ។ នៅក្នុងបន្ទប់សវនាការក្នុងសំណុំរឿង០០២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានឋានៈអ្វីនៅក្នុងបន្ទប់សវនាការនេះទេ គាត់មិនមែនជាភាគីមួយនៅចំពោះមុខអង្គជំនុំជម្រះទេ។ វាពាក់ព័ន្ធទៅនឹងព័ត៌មានដែលត្រូវមកបង្ហាញ ក៏ប៉ុន្តែការិយាល័យរបស់គាត់មិនមានតួនាទីអ្វីនៅចំពោះមុខអង្គជំនុំជម្រះនោះទេ។ ប៉ុន្តែមន្ត្រីច្បាប់ណាមួយដែលមកពីការិយាល័យរបស់គាត់ក៏មិនមានឋានៈអីដែលត្រូវមានវត្តមានចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែរ។ មានតែមេធាវីប្រឹក្សាសាក្សីដូចដែលបានផ្តល់ជូនដូចសព្វដងនេះ ដើម្បីធ្វើម៉េចកុំគាត់ឆ្លើយទៅ ឆ្លើយដាក់បន្ទុកលើខ្លួនឯង វានាំ

ឲ្យគាត់ទៅវាមានពិរុទ្ធភាពអីនោះ។

ដូច្នេះសរុបទៅ ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនមានឋានៈអ្វីត្រូវមានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះនេះទេ។ ខ្ញុំថា ការដែលខ្ញុំលើកឡើងនេះ វាជា នីតិវិធីមួយដ៏ត្រឹមត្រូវនៅចំពោះមុខអង្គជំនុំជម្រះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបាននិយាយថា បើសិនណាមានសំណួរណាពាក់ព័ន្ធទៅនឹងវិសាលភាពនៃសក្ខីកម្មរបស់គាត់ នោះត្រូវតែឲ្យអ្នកជំនាញនឹងពិគ្រោះជាមួយនឹងមន្ត្រីច្បាប់ គឺលោកស្រីជាមន្ត្រីច្បាប់ ជាមុនសិន។ បើសិនជាឲ្យមន្ត្រីច្បាប់មកផ្តល់ប្រឹក្សាជំនួយឲ្យមេធាវី នោះមិនមែនជានីតិវិធីមួយដែលត្រឹមត្រូវនោះទេ។ យើងត្រូវតែធ្វើឲ្យដូចអ្វីដែលយើងបានធ្វើនៅក្នុងសំណុំរឿង ០០២ យ៉ាងដូច្នេះ។ ប្រសិនណាអង្គជំនុំជម្រះសម្រេចថា មន្ត្រីច្បាប់មានមុខងារ ឬក៏អាចបំពេញតួនាទីនៅចំពោះមុខអង្គជំនុំជម្រះ អ៊ីចឹងត្រូវបញ្ជាក់ឲ្យបានច្បាស់ថាតើគាត់មានតួនាទីធ្វើអ្វី? អ៊ីចឹងឯងបានជាខ្ញុំនៅតែសរុបសេចក្តីទៅវិញថា នៅតែមានបញ្ហាដដែល។

[១៥:៣៣:៥០]

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំសូមធ្វើការបំភ្លឺលើសពីការកត់សម្គាល់ដែលខ្ញុំបានលើកឡើងអម្បាញ់មិញ។ ខ្ញុំសូមរំឭកថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ គឺឯកសារ E319/7 ទាក់ទងទៅនឹងរបៀបប្រើប្រាស់ឯកសារដែលចេញមកពីសំណុំរឿង ដែលកំពុងតែស៊ើបសួរ ត្រូវបានអនុវត្តដោយភាគី។ ខ្ញុំមិនចូលនិយាយលម្អិតអំពីសេចក្តីសម្រេចនោះទេ។ គឺថានិយាយអំពីរបៀបដែលយើងត្រូវធ្វើយ៉ាងណានោះទេ ក៏ប៉ុន្តែអង្គជំនុំជម្រះបានចេញនីតិវិធីហើយស្រេចហើយ ទាក់ទងទៅនឹងឯកសារដែលស្ថិតនៅក្រោមការស៊ើបអង្កេតនេះ។ អ៊ីចឹងខ្ញុំគិតថា គួរតែចាត់វិន័យដូចគ្នាអ៊ីចឹងទៅ ចំពោះសំណួរដែលយើងនឹងសួរទៅអ្នកជំនាញរូបនេះ លោកប្រធាន។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៏៖**

អរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការកត់សម្គាល់ខ្លីទេ--

**ប្រធានអង្គជំនុំ៖**

ឈប់កុំអាលសិន! សូមអញ្ជើញមួយចំហៀងៗម្តង។ ឥឡូវនៅច្របូកច្របល់គ្នាអ៊ីចឹង គ្រប់គ្រងពិភាក្សាគ្នាម៉េចនឹងកើត។ សូមអញ្ជើញលោក គង់ សំអុន!

[១៥:៣៥:០៥]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមទាញការចាប់អារម្មណ៍របស់អង្គជំនុំជម្រះ និងភាគីទាក់ទងទៅនឹងសំណើរបស់សហចៅក្រមអន្តរជាតិ ខ្ញុំយល់ពីការប្រឹងប្រែងដើម្បីទប់ស្កាត់នូវការសម្ងាត់នៅក្នុងសំណុំរឿងផ្សេងក្រៅពីសំណុំរឿង០០២ ដែលយើងកំពុងធ្វើសវនាការនេះ។ ក៏ប៉ុន្តែចំណុចមួយដែលខ្ញុំសុំលោកប្រធាន និងក្រុមប្រឹក្សាពិនិត្យទៅលើនោះ គឺសាធារណភាពនៃដំណើរការសវនាការរបស់យើង។ ហើយនិងទី២ គឺទាក់ទងទៅនឹងផលប្រយោជន៍ជាសិទ្ធិរបស់កូនក្តីរបស់ខ្ញុំបាទ ក៏ដូចជាជនជាប់ចោទនៅក្នុងទីនេះ ក្នុងសំណុំរឿង០០២នេះ ពីព្រោះថាយើងមាននីតិវិធីសម្រាប់ការពារទៅលើឯកសារមួយចំនួនដែលទាក់ទងទៅនឹងសំណុំរឿង០០៣, ០០៤រួចហើយ ថាត្រូវធ្វើយ៉ាងដូចម្តេច។ អ៊ីចឹងបើសិនជាមានការកម្រិតណាមួយ នៅពេលដែលការកម្រិតទាំងនោះ ឬក៏ជាសម្ភារៈទាំងនោះ ប៉ះពាល់ទៅដល់ផលប្រយោជន៍របស់កូនក្តីខ្ញុំបាទនៅទីនេះ អ៊ីចឹងវាមិនអាចឲ្យយើងត្រូវគោរពនូវកាតព្វកិច្ចណាមួយ ទាក់ទងទៅនឹងការសម្ងាត់ដែលមាននៅក្នុងសំណុំរឿងផ្សេងដែលធ្វើឲ្យប៉ះពាល់ ឬក៏ដែលមានប្រយោជន៍ផ្ទុយពីសិទ្ធិរបស់កូនក្តីរបស់យើងខ្ញុំនៅទីនេះបានទេ ពីព្រោះយើងត្រូវការពារផលប្រយោជន៍កូនក្តីនៅទីនេះ។ អ៊ីចឹងបើសិនជាមានវិវាទដែលសហចៅក្រមស៊ើបអង្កេតលើកឡើងហាមឃាត់មិនឲ្យតាំងសំណួរណាមួយដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់កូនក្តីនោះ វាធ្វើឲ្យការការពាររបស់យើងនៅទីនេះគឺគ្មានប្រសិទ្ធភាព។ ដូច្នេះវាមិនមានច្បាប់ណាមួយដែលហាមឃាត់ថា ជនជាប់ចោទត្រូវតែលះបង់កាតព្វកិច្ចការពារសិទ្ធិរបស់ខ្លួន ដើម្បីផលប្រយោជន៍នៃការរក្សាការសម្ងាត់ណាមួយនោះទេ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១៥:៣៧:៣៩]

**លោកស្រី ម៉ារី ហ្គ័ររ៉ូវ៉ង់៖**

សូមអរគុណលោកប្រធាន។ វិធានដែលសំខាន់ចំពោះខ្ញុំ គឺវិធាន៥៦នៃវិធានផ្ទៃក្នុងរបស់យើងដែលចែងថា ការស៊ើបអង្កេតជាការសម្ងាត់ ក៏ប៉ុន្តែអ្នកដែលចូលរួមក្នុងការស៊ើបអង្កេតនោះ ត្រូវតែគោរពការសម្ងាត់។ អ៊ីចឹងគឺជាកាតព្វកិច្ចបុគ្គលដែលអ្នកដែលធ្វើការស៊ើបអង្កេតនោះ ត្រូវតែគោរព មិនត្រូវបង្ហាញ ឬក៏លាតត្រដាងព័ត៌មានសម្ងាត់នោះទេ។ អ៊ីចឹងខ្ញុំយល់ស្របនឹងមេធាវីការពារក្តី គឺថា គឺ

លោក អ៊ីសា ឧស្មាន ទេដែលត្រូវដឹងខ្លួនឯង ថាតើព័ត៌មានណាជាព័ត៌មានដែលគាត់ត្រូវតែគោរពការសម្ងាត់ ហើយនិងព័ត៌មានណាដែលគាត់មិនត្រូវលាតត្រដាង។ អ៊ីចឹងមានដំណោះស្រាយពីរជូនលោក ឧស្មាន ហ្នឹងគាត់មានទីប្រឹក្សាណាមួយដែលជួយប្រាប់គាត់ពីវិសាលភាពដែលគាត់អាចឆ្លើយបាននឹងសំណួរភាគី ជួនគាត់ត្រូវៗអង្គជំនុំជម្រះក៏អាចថាទទួលទីប្រឹក្សាច្បាប់ ដែលរបស់ការិយាល័យសហព្រះរាជអាជ្ញា -- របស់ចៅក្រមស៊ើប តែលោក ឧស្មាន នោះគាត់ខ្លួនគាត់នេះហើយដែលត្រូវថាកំណត់នៃវិសាលភាពរបស់ខ្លួន តើដែនកំណត់របស់ខ្លួនហ្នឹងត្រឹមប៉ុនណា ឆ្លើយបានប៉ុនណា មិនឆ្លើយប៉ុនណា។

[១៥:៣៩:០៩]

**លោក នីកូឡាស គូមជែន៖**

លោកប្រធានខ្ញុំគ្រាន់ចង់លើកឡើងអ្វីដែលមេធាវីលើកឡើងនោះ គឺថាជាការត្រឹមត្រូវហើយ គឺមានយុត្តិសាស្ត្រដែលបញ្ជាក់ថា មេធាវីដែលមកពីខាងក្រៅ គឺតំណាង គឺឲ្យរដ្ឋាភិបាល ក្នុងហ្នឹងរឿងក្ដីរបស់លោក មីឡូសីវិច យុត្តាធិការដែលគាត់លើកឡើងនោះ។ នៅក្នុងយុត្តាធិការផ្សេងៗទៀត ដោយសារពាក់ព័ន្ធទៅនឹងផលប្រយោជន៍ជាតិ ព័ត៌មានដែលពាក់ព័ន្ធទៅនឹងផលប្រយោជន៍ជាតិអាចផ្ដល់មកឲ្យតុលាការក្នុងកាលៈទេសៈណាមួយដែលត្រឹមត្រូវ។ ដូច្នេះនៅក្នុងរឿងក្ដីរបស់លោក មីឡូសីវិច គឺមានឧត្តមសេនីយ៍មួយ គឺឯកអគ្គរដ្ឋទូតរបស់សហរដ្ឋអាមេរិក គឺថាមកផ្ដល់សក្ខីកម្ម ហើយត្រូវបានតំណាងរដ្ឋាភិបាលមកអមគាត់ ពាក់ព័ន្ធទៅនឹងការអនុវត្តន៍វិធាន៧១ ដែលក្នុងការផ្ដល់សក្ខីកម្មចំពោះមុខតុលាការ។ ហើយក្នុងរឿងក្ដីថ្មីៗនេះ ស្មេណ្ឌស៊ិក ឯកអគ្គរាជទូតអង់គ្លេស រ៉ូបឺត គឺថាគឺផ្ដល់សក្ខីកម្មក្នុងតំណាងឲ្យរដ្ឋាភិបាលអង់គ្លេស មិនមែនខ្លួនគាត់ផ្ទាល់ទេ។ អ៊ីចឹងហើយថាតើព័ត៌មានណាជាព័ត៌មានសម្ងាត់ដែលមិនត្រូវអនុញ្ញាតឲ្យគេសួរគាត់ ឬក៏មិនត្រូវអនុញ្ញាតឲ្យគាត់ឆ្លើយនោះ។ ការដែលសួរទៅសាក្សីដែលមិនមែនជាមេធាវី គឺវាអាស្រ័យទៅលើការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយសារតែយើងលើកឡើងរបស់មេធាវីការពារក្ដីនេះ អាចថានឹងសួរព័ត៌មានសម្ងាត់។ សូមឲ្យបង្ហាញនូវព័ត៌មានសម្ងាត់ ដោយសារតែផលប្រយោជន៍នៃកូនក្ដីរបស់ខ្លួន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៥:៤១:០៦]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសូមឆ្លើយតបទៅមេធាវីនាំមុខ ដែលគាត់និយាយថា មានជម្រើសពីរ គឺថាឲ្យមេធាវីម្នាក់ជួយគាត់ ហើយជូនឲ្យមានអ្នកតំណាងមកពីការិយាល័យចៅក្រមស៊ើបអង្កេតម្នាក់។ ខ្ញុំមិនយល់ថា ឲ្យមានវត្តមានមេធាវីនៅទីនេះហ្នឹង ដើម្បីជួយផ្តល់ប្រឹក្សាដល់ ឧស្មាន ហ្នឹងមានប្រយោជន៍អីទេ ព្រោះថាគាត់ហ្នឹងមិនមែនមេធាវីនៅក្នុងសំណុំរឿងដែលកំពុងស៊ើបសួរនោះទេ។ អ៊ីចឹងខ្ញុំមិនដឹងថា ពួកគាត់អាចពិភាក្សាអំពីការសម្ងាត់ហ្នឹងយ៉ាងម៉េចទៅ។ ប្រហែលជាខ្ញុំមិនយល់លោកស្រីមេធាវីច្បាស់ ឬក៏យ៉ាងណាទេ។ លោកស្រីអាចបំភ្លឺចំណុចនេះបានដែរឬទេ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំស្តាប់លោកចៅក្រម ខ្ញុំយល់ហើយ ប្រហែលដំណោះស្រាយមិនល្អទេ។ ក៏ប៉ុន្តែខ្ញុំសូមរំឭកដល់អង្គជំនុំជម្រះថា នេះការរក្សាការសម្ងាត់ហ្នឹងជាកាតព្វកិច្ចជាបុគ្គល ហើយជាដំបូងបំផុតនោះ គឺថាអ្នកជំនាញខ្លួនហ្នឹងហើយ ខ្លួនឯងហ្នឹងហើយជាអ្នកកំណត់ ថាតើសំណួរណាខ្លួនអាចឆ្លើយបាន សំណួរណាខ្លួនឆ្លើយមិនបាន ហើយមានតែគាត់ហ្នឹងហើយ ដែលជាអ្នកដឹងថាព័ត៌មានណា ជាព័ត៌មានសម្ងាត់ដែលគាត់មិនអាចចែករំលែកមកយើងបាននោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ចំណុចសង្ខេបមួយទេ បើអនុញ្ញាតឲ្យខ្ញុំលើកឡើង លោកប្រធាន គឺទាំងមេធាវី សហមេធាវីនាំមុខ ក៏ដូចជាការិយាល័យសហចៅក្រមស៊ើបអង្កេត។ សំណើសុំនេះ គឺជាសំណើសុំតែមកតែពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិតែម្នាក់ប៉ុណ្ណោះ។ ហើយជាពិសេសពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចថ្មីៗ គឺសេចក្តីសម្រេចដែលបានចេញនៅថ្ងៃសុក្រ សប្តាហ៍មុន ពាក់ព័ន្ធទៅនឹងករណីរបស់ មាស មុត ដែលស្នើសុំឲ្យផ្អាកដីកាសម្រេចនាំខ្លួន។ មានកថាខណ្ឌមួយគួរឲ្យចាប់អារម្មណ៍ នៅក្នុងយោបល់របស់ចៅក្រមជាតិទាំងបី។ មាស មុត បានស្នើសុំឲ្យបង្អង់ការអនុវត្តដីកានាំខ្លួននេះសិន។ ស្នើសុំឲ្យអង្គបុរេជំនុំជម្រះសម្រេចយ៉ាងដូច្នេះ ហើយចៅក្រមជាតិនៅអង្គបុរេជំនុំជម្រះបានលើកឡើងដូចតទៅ “ដីកាចាប់ខ្លួននេះគឺជាវិធានការចាប់បង្ខំដែលត្រូវអនុវត្តដោយនគរបាលយុត្តិធម៌ ដើម្បីនាំខ្លួន មាស មុត មកចំពោះមុខសហចៅក្រមស៊ើបអង្កេតតែម្នាក់ឯង។ មិនមែនមកចំពោះមុខសហចៅក្រមស៊ើបអង្កេតទាំងពីររូបនោះទេ”។ វិធានការនេះ នៅក្នុងសង្គមកម្ពុជាត្រូវបានចាត់ទុកថា ជាការគំរាមកំហែងទៅដល់សុចរិតភាពសេចក្តីថ្លៃថ្នូរ និងសិទ្ធិចម្បងៗរបស់ មាស មុត--

[១៥:៤៤:៤៧]

**ប្រធានអង្គជំនុំ៖**

លោក១អាចវែកញែកបានទេ លើកចំណុចនេះមកពេលនេះ ពិភាក្សារឿងត្រូវនីតិវិធីនៃការស្ដាប់ចម្លើយសក្ខីកម្មរបស់អ្នកជំនាញ ហើយនិងដែលមានវត្តមានមន្ត្រីច្បាប់មកពីការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ វាមានទាក់ទិនអីជាមួយនឹងឯកសារដែលលោកលើកបង្ហាញចុងក្រោយនេះទេ។ លោកអាចពន្យល់យើងបានទេ?

នេះជាចំណុចសម្ងាត់កន្លែងណាទៅ ហើយបានជាលោកលើកចំណុចនេះ ហើយវាពាក់ព័ន្ធយ៉ាងម៉េចទៅនឹងវិធីសាស្ត្រនៃការដែលយើងនឹងស្ដាប់សក្ខីកម្មអ្នកជំនាញ TCE-95 ដែលចំណុចហ្នឹង គឺអាចមានតែពីរចំណុចទេ គឺក្របខ័ណ្ឌឥឡូវនេះ ឲ្យមានវត្តមានមន្ត្រីច្បាប់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតមួយរូប អន្តរជាតិមួយរូបមកជួយដើម្បីរំឭក ឬក៏បញ្ជាក់ថា ត្រូវឆ្លើយតប ឬមិនឆ្លើយតប ព្រោះវាពាក់ព័ន្ធការងារសម្ងាត់ ឬអត់។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំកំពុងតែចង់លើកចំណុចនេះឡើងលោកប្រធាន។ វាហាក់បីដូចជាថា ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះធ្វើការញែកចេញពីគ្នានូវវិធានការចាប់បង្ខំ ដែលវាចេញឡើងទៅតាមសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិតែម្នាក់ឯង មិនមែនទាំងពីររូបនោះទេ។ ហេតុផលដែលខ្ញុំលើកឡើងនេះដោយសារថា លិខិតនេះគឺជាលិខិតមួយដែលបានស្នើសុំតែពីសំណាក់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ បើករណីនេះវាយ៉ាងដូច្នេះមែន ហាក់បីដូចថា សហចៅក្រមស៊ើបអង្កេតជាតិថាមានជំហរផ្សេងគ្នាពាក់ព័ន្ធទៅនឹងសំណើសុំនេះ។ ដូច្នេះជាការកត់សម្គាល់របស់យើងខ្ញុំទេថា ការិយាល័យសហចៅ -- កាលណាយើងលើកឡើងពាក្យថា ការិយាល័យសហចៅក្រមស៊ើបអង្កេតគឺមិនត្រឹមត្រូវទេ ជាសំណើពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិតែម្នាក់ឯងប៉ុណ្ណោះ។ ហើយវាពាក់ព័ន្ធទៅនឹងសិទ្ធិរបស់ជនជាប់ចោទ វាប៉ះពាល់ទៅដល់សិទ្ធិជនជាប់ចោទផងដែរ។ ដូច្នេះយើងខ្ញុំចង់ដឹងជំហររបស់ខាងសហព្រះរាជអាជ្ញាយល់ឃើញយ៉ាងដូចម្ដេច? សហព្រះរាជអាជ្ញាជាតិនោះយល់យ៉ាងម៉េចដែរពាក់ព័ន្ធទៅនឹងលិខិតស្នើសុំមួយនេះ។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅមានមតិយោបល់អីទេ សហព្រះរាជអាជ្ញារងជាតិ?

**លោក ស្រ៊ា រតនៈ៖**

សូមជម្រាបលោកប្រធាននៅត្រង់ចំណុចនេះ ខាងសហព្រះរាជអាជ្ញារងជាតិអត់មានយោបល់អ្វីទេបាទ។

**ប្រធានអង្គជំនុំ៖**

យើងចង់ដឹងអ៊ីចេះលោក វ៉ិចទ័រ កូប៉េ តើលោកចង់និយាយថាម៉េច? ឥឡូវចង់មានន័យថាសំណើសុំនេះគឺមិនមានសុពលភាព មិនអាចយកមកពិភាក្សាគ្នាបាន ព្រោះយើងពិភាក្សានេះ យើងគិតថា វាទទួលៗហើយ បានន័យថា វាទៅលើខ្លឹមសារ មិនមែនទៅលើទម្រង់ទេ។ ហើយបើសិនជាយើងមិនទទួល លោកចង់លើកឡើងបញ្ហាអ៊ីចឹងថា បើទទួលទៅវាខុសនឹងនីតិវិធី វាគ្មានសុពលភាព ឬក៏បដិសេធតែម្តងដោយទម្រង់មិនបាច់ពិនិត្យលើខ្លឹមសារទេ ឬយ៉ាងម៉េច?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ នេះគឺជាជំហររបស់ក្រុមយើងខ្ញុំទាក់ទងទៅនឹងសំណើសុំឲ្យហៅសាក្សីបីនាក់បន្ថែម។ កាលពីសប្តាហ៍មុន យើងខ្ញុំបានដាក់ចម្លើយតបរួចហើយ យើងខ្ញុំបានជំទាស់តវ៉ាថា សំណើសុំពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវចាត់ទុកជាមោឃៈ។ អង្គជំនុំជម្រះសាលាដំបូងមិនត្រូវទទួលយកសំណើសុំនោះទេ និងយើងខ្ញុំ ពាក់ព័ន្ធថាឲ្យបង្គង់នូវសំណើសុំបង្ហាញព័ត៌មានពីខាងសហចៅក្រមស៊ើបអង្កេតតែម្នាក់នេះ។ ខ្ញុំមិនទាន់ច្បាស់លាស់នៅឡើយដែរ ដោយសារសេចក្តីសម្រេចក៏មិនច្បាស់លាស់ដែរ។ ប៉ុន្តែខ្ញុំយល់ឃើញថា យើងទាំងអស់គ្នាអាចយល់ស្របថា វានឹងមានបញ្ហាផ្លូវច្បាប់ដោយសារតែសហចៅក្រមស៊ើបអង្កេតអន្តរជាតិស្នើសុំតែម្នាក់ឯង ឯសហចៅក្រមស៊ើបអង្កេតជាតិគឺថាមិនបានស្នើសុំទេ នៅស្ងៀមស្ងាត់ ដោយមិនមានមតិសំណើសុំអីនោះឡើយ។

[១៥:៥០:២៧]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមបញ្ជាក់ថាសហចៅក្រមស៊ើបអង្កេតជាតិ ក៏បានលើកឡើងអំពីភាពសម្ងាត់នៃកិច្ចស៊ើបសួរផងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ ហើយតទៅបញ្ហាមួយទៀត គឺបញ្ហាទី៣ ហើយដើម្បីឲ្យអង្គជំនុំជម្រះហ្នឹងមានមូលដ្ឋានសមស្របក្នុងការរៀបចំកាលវិភាគសវនាការ ហើយជាពិសេសសវនាការនៃការស្តាប់សក្ខីកម្មអ្នកជំនាញ

2-TCE-95 នាពេលខាងមុខ។ អង្គជំនុំជម្រះសូមសួរទៅសហព្រះរាជអាជ្ញាអន្តរជាតិ ថាតើសហព្រះរាជអាជ្ញាមានបំណងដាក់បង្ហាញឯកសារបន្ថែមទៀត ក្រៅពីឯកសារចំនួន១១ថ្មីៗដែលសហចៅក្រមអន្តរជាតិទើបតែបានដាក់ដូចបញ្ជីឯកសារ E319/33 ដែរឬទេ? ហើយបើសិនបើមាន តើសហព្រះរាជអាជ្ញាអន្តរហ្នឹងអាចបញ្ជាក់ដែរទេថា ឯកសារចំនួនប៉ុន្មានទៀតដែលនឹងដាក់បង្ហាញពាក់ព័ន្ធនឹងអង្គហេតុការប្រព្រឹត្តិលើក្រុមមនុស្សគោលដៅជាក់លាក់ចំពោះជនជាតិចាម?

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ តាមដែលយើងបានពិនិត្យនៅថ្ងៃនេះ យើងបានពិនិត្យមើលនូវកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរទាំងអស់នៅក្នុងសំណុំរឿង០០៤។ កំណត់ហេតុទាំងអស់ពាក់ព័ន្ធទៅនឹងជនជាតិចាមត្រូវបានបង្ហាញរួចហើយ នូវកំណត់ហេតុ២៧ទៀតដែលមានតែជាភាសាខ្មែរនៅឡើយ។ យើងខ្ញុំកំពុងតែពិនិត្យទៅលើកំណត់ហេតុជាភាសាខ្មែរទាំងអស់ ដោយសារថាការិយាល័យយើងខ្ញុំក៏មានបុគ្គលិកមានកម្រិតនៅឡើយដែរ។ ហើយមានសំណើសុំបីទៀតដែលបង្អង់នៅឡើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត គឺការបង្ហាញនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន។ ខ្ញុំសង្ឃឹមថាសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនឹងចេញនៅពេលឆាប់ៗ។

[១៥:៥៣:០៤]

ហើយខ្ញុំសូមលើកឡើងផងដែរថា នូវអ្វីដែលអង្គជំនុំជម្រះបានលើកឡើងអំពីការចោទប្រកាន់ថាមានការកម្រិត ហើយមានតែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលសំខាន់ៗបំផុតនៅក្នុងសំណុំរឿង០០៤ទេ ដែលនឹងត្រូវយកមកបង្ហាញក្នុងករណីដែលវាមានភស្តុតាងដោះបន្ទុក។ តាមដែលខ្ញុំយល់គឺថាមានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៤០០ឯណោះ ដែលមិនទាន់បានពិនិត្យឡើងវិញនៅឡើយ ហើយយើងក៏ត្រូវពិនិត្យទៅលើលក្ខណៈ ដោយយោងទៅលើលក្ខណៈវិនិច្ឆ័យតែមួយ ដូចមេធាវីការពារក្តីលើកឡើងថា បើសិនជាមានភាគីណាមួយមិនចង់ឲ្យយើងខ្ញុំពិនិត្យមើលនូវពាក្យសុំតាំងខ្លួនទាំងអស់នេះទេ យើងខ្ញុំក៏សប្បាយចិត្តដែរ ពីព្រោះថាវាជាបន្ទុកការងារមួយធ្ងន់ធ្ងរណាស់សម្រាប់ការិយា-ល័យ របស់ខ្ញុំដែលត្រូវពិនិត្យមើលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៤០០ ដែលយើងបានពិនិត្យបាន៣០០ហើយនោះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមសួរព័ត៌មានបន្ថែមបន្តិច លោកលើកឡើងថា កំណត់ហេតុ២៧ កំណត់ហេតុស្តាប់ចម្លើយ

២៧ មានតែជាភាសាខ្មែរទេ។

**លោក នីកូឡាស គូមជែន៖**

យើងខ្ញុំកំពុងតែពិនិត្យទៅជាភាសាខ្មែរ អ៊ីចឹងហើយវាយឺតយ៉ាវ។

[១៥:៥៤:៤២]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើលោកអាចបញ្ជាក់បានទេថា បើសិនណាស្នើសុំឲ្យដាក់បង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយទាំងអស់នេះរួចរាល់នៅពេលណាដែរ? ហើយតើទាំងអស់នេះអាចត្រូវបកប្រែ ឬក៏យ៉ាងណា ពីព្រោះមានតែជាភាសាខ្មែរ។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំមិនអាចឆ្លើយនឹងទៅនឹងសំណួររបស់លោកស្រីបានទេ ខ្ញុំគ្រាន់តែប៉ាន់ប្រមាណនៅឡើយទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ការកត់សម្គាល់មួយពីខាងយើងខ្ញុំ គឺឯកសារត្រូវបានបង្ហាញកាលពីម្សិលមិញ។ ឯកសារដែលបានបង្ហាញពីម្សិលមិញ គឺពាក់ព័ន្ធទៅនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលចាត់ទុកថាសាក្សីដ៏សំខាន់បំផុតម្នាក់។ សាក្សីរូបនេះត្រូវបានសម្ភាសប៉ុន្មានសប្តាហ៍មុននេះ ឬក៏ប៉ុន្មានខែមុននេះរួចហើយ។ មានន័យថាការស៊ើបអង្កេតនៅបន្តនៅឡើយ។ មានន័យថា អ៊ីចឹងមានន័យថាការស៊ើបអង្កេតមិនមែនបញ្ឈប់ត្រឹមតែកំណត់ហេតុស្តាប់ចម្លើយត្រឹម២៧នេះទេ នឹងបន្តទៅទៀតនឹងមានកំណត់ហេតុស្តាប់ចម្លើយតទៅទៀត។ សូម្បីតែក្នុងពេលដែលយើងកំពុងនិយាយនេះក៏ដោយការស៊ើបក៏នឹង--។

**លោក នីកូឡាស គូមជែន៖**

បាទ ដើម្បីប្រតិចារឹកដែរ ជាការគិតត្រឹមត្រូវហើយ ការស៊ើបអង្កេតកំពុងបន្តទៅទៀត យើងខ្ញុំកំពុងឯរង់ចាំនូវកំណត់ហេតុស្តាប់ចម្លើយណាដែលបានតែធ្វើរួចហើយនោះ។ យើងកំពុងតែពិនិត្យមើលតែកំណត់ហេតុស្តាប់ចម្លើយណាដែលបានសាកសួរចប់សព្វគ្រប់ហើយនោះ ពីព្រោះថាវាបន្ទុកធ្ងន់ធ្ងរសម្រាប់យើងខ្ញុំដែរ។

[១៥:៥៦:៣២]

**កញ្ញា អង់តា ហ្គីសសេះ**

ក្នុងដំណាក់កាលនេះលោកប្រធាន ខ្ញុំសូមអន្តរាគមន៍ដើម្បីបញ្ជាក់ថាយើងកំពុងតែរង់ចាំដោយភាពអត់ធ្មត់នូវចម្លើយទៅនឹងសំណើរបស់យើងខ្ញុំ ជាមេធាវីការពារក្តីលោក ខៀវ សំផន ប្រហែលជាមានការកម្រិត រឹតត្បិតដែលមានសារៈសំខាន់ដល់ការពន្លឿននីតិវិធី។ ខ្ញុំឃើញនៅក្នុងសារព័ត៌មានការសរសេរថាមានការផ្តល់ពេលវេលាទៅដល់មេធាវីការពារក្តីក្នុងការពិនិត្យឯកសារថ្មី។ នេះជាចំណុចសំខាន់ក្នុងការបញ្ជាក់ថា នេះមិនមែនជាពេលវេលាអត់ប្រយោជន៍ទេ គឺជាពេលវេលាដែលត្រូវបានស្នើសុំដោយសារតែមានការដាក់បង្ហាញឯកសារថ្មី ដូច្នេះជាចំណុចសំខាន់ដែលខ្ញុំត្រូវលើកឡើងនូវចំណុចនេះ។ ពាក់ព័ន្ធទៅនឹងការដាក់បង្ហាញថ្មីៗពីរ ដោយសហព្រះរាជអាជ្ញានោះ គឺម្សិលមិញ ឬថ្ងៃនេះក៏មិនដឹង ខ្ញុំភ្លេចហើយ យើងមិនទាន់បានពិនិត្យមើលឯកសារថ្មីទាំងអស់ហ្នឹងទេ ក៏ប៉ុន្តែមានសំណើថ្មីដែលសុំឲ្យការដាក់បង្ហាញរួចហើយ ក៏ប៉ុន្តែយើងមិនទាន់ពិនិត្យមើលឯកសារហ្នឹងទេ។ នេះជាបញ្ហាពាក់ព័ន្ធនឹងពេលវេលាទៀតហើយ ដែលយើងត្រូវការពេលដើម្បីពិនិត្យមើល។ ដូច្នេះយើងកំពុងរង់ចាំនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដើម្បីពិចារណាទៅលើបញ្ហាទាំងអស់នេះ។ ការស៊ើបអង្កេតសំណុំរឿង០០៣, ០០៤ វាមិនពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន អីនោះទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាចុងក្រោយផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី ខៀវ សំផន ដើម្បីបង្ហាញនូវសំណើសុំរបស់ខ្លួនដែលបានអង្គជំនុំជម្រះបានទទួលតាមអ៊ីម៉ែលកាលពីថ្ងៃមិញ ហើយសូមបង្ហាញនាពេលនេះតែម្តងទៅ តើមានបំណងធ្វើយ៉ាងដូចម្តេចខ្លះលើសំណើសុំនោះ?

[១៥:៥៨:៣៣]

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមចាប់ផ្តើមតាមរយៈចំណុចពាក់ព័ន្ធទៅនឹងអ្នកជំនាញដែលយើងកំពុងនិយាយមុននេះនោះ។ សំណើទី១របស់ខ្ញុំ គឺមានភាពសមហេតុផលណាស់ក្នុងក្របខ័ណ្ឌនៃកាលវិភាគអង្គជំនុំជម្រះដែលគ្រោងថានឹងស្តាប់អ្នកជំនាញនោះនៅចុងក្រោយវគ្គ គឺក្រោយពីស្តាប់សាក្សីពាក់ព័ន្ធនឹងជនជាតិចាមនេះអស់សិន ដោយសារតែមូលហេតុផ្សេងៗ គឺមានសាក្សីជាច្រើនហ្នឹងដែលត្រូវគ្រោងហ្នឹងមិនអាចមកផ្តល់សក្ខីកម្មតាមការគ្រោងទុកបាន។ ដូច្នេះខ្ញុំគិតថា សាក្សីខ្លះអាចនឹងកោះ

ហៅនៅពេលក្រោយបន្ថែមមកទៀត។ ដូច្នេះសំណើទី១របស់ខ្ញុំ គឺសុំធ្វើយ៉ាងណាឲ្យអ្នកជំនាញអាចផ្តល់សក្ខីកម្មក្រោយពីសាក្សីផ្តល់សក្ខីកម្មអស់សិន ពីព្រោះថាមានសាក្សីមួយនោះត្រូវបានអ្នកជំនាញជាអ្នកសម្ភាស។ អ៊ីចឹងយើងចង់ត្រឡប់មកនិយាយអំពីកិច្ចសម្ភាសន៍ហ្នឹង ហើយនិងអ្វីដែលគាត់ឆ្លើយជូននៅពេលសម្ភាសនោះ។ អ៊ីចឹងហើយជាភាពសមហេតុផលនោះ គឺថាត្រូវតែអ្នកជំនាញផ្តល់សក្ខីកម្មក្រោយគេបង្អស់។

ចំណុចទី២ ដែលពាក់ព័ន្ធនឹងចំណុចទី១ដែរ គឺថាតាមរយៈសវនាការកន្លងមកនេះ យើងសង្កេតឃើញថា មានឯកសារជាច្រើនដែលយើងចង់ដាក់ជូនអ្នកជំនាញឲ្យគាត់ពិនិត្យមើល ហើយនិងភាគីដើម្បីឲ្យអ្នកជំនាញគាត់ផ្តល់យោបល់ ហើយយោងតាមអ្វីកើតឡើងកន្លងមក គឺថាយើងត្រូវផ្តល់លេខ ERN គ្រប់ភាសា អ៊ីចឹងវាចំណាយពេលច្រើនណាស់។ អ៊ីចឹងយើងសូមស្នើថា២ថ្ងៃដែលគ្រោងទុកដោយអង្គជំនុំជម្រះស្តាប់សក្ខីកម្មអ្នកជំនាញ ហើយដែលមានឲ្យកន្លះថ្ងៃទៅឲ្យក្រុមមេធាវី ខៀវ សំផន គឺប្រហែលជា ២ម៉ោង១០នាទីហ្នឹង គឺខ្ញុំគិតថាវាខ្លីណាស់ យើងមិនអាចពិនិត្យមើល ទៅលើឯកសារផ្សេងៗដែលយើងចង់ដាក់ឲ្យអ្នកជំនាញផ្តល់យោបល់អស់ទេ។ អ៊ីចឹងយើងសូមស្នើថា ធ្វើយ៉ាងម៉េច គឺថាយើងមិនចង់សុំពេលចុងក្រោយថា សុំពេលម៉ោងបន្ថែមអ៊ីចឹងនោះទេ។ អ៊ីចឹងយើងធ្វើយ៉ាងម៉េចឲ្យអង្គជំនុំជម្រះគ្រោងមួយវគ្គបន្ថែមសម្រាប់ភាគីនីមួយៗ។ យើងមានន័យថាគ្រោងមួយវគ្គសម្រាប់ភាគីផ្សេងៗ ដើម្បីឲ្យភាគីអាចមានពេលសួរបានគ្រប់គ្រាន់។ ធ្វើបែបនេះដើម្បីឲ្យមានការងាយស្រួលដល់ក្នុងការសួរសំណួរគាត់។ ដូច្នេះខ្ញុំគិតថាកន្លះថ្ងៃសម្រាប់មេធាវីការពារក្តីលោក ខៀវ សំផន នោះគឺវាខ្លីណាស់ មិនគ្រប់គ្រាន់ឲ្យយើងសួរឲ្យបានពេញលេញគ្រប់ជ្រុងជ្រោយនោះទេ។ ដូច្នេះអ្វីដែលមេធាវីការពារក្តីចង់ស្នើនោះគឺបែបនេះហើយ។ តើអង្គជំនុំជម្រះមានសំណួរជាក់លាក់អ្វីមកខ្ញុំទៀត ខ្ញុំនឹងអាចឆ្លើយ ឬហើយបើមិនអ៊ីចឹងទេ ខ្ញុំនឹងអាចលើកសំណើខ្ញុំផ្សេងទៀត?

**ប្រធានអង្គជំនុំ៖**

អញ្ជើញចូលសំណើទី២!

[១៦:០២:២១]

**កញ្ញា អង់តា ហ្គីសសេ៖**

សំណើទី២របស់ខ្ញុំ ប្រហែលជាលឿនបន្តិច។ ក៏ប៉ុន្តែវាជាការឆ្លើយតបទៅនឹងសំណួររបស់ចៅក្រម ហ្វេនស៍ ដែលខ្ញុំមិនយល់ទេសំណួររបស់គាត់។ គាត់សួរកាលប៉ុន្មានថ្ងៃមុននៅក្នុងសវនាការនេះ

ថាតើមេធាវីការពារក្ដីត្រូវការពេលប៉ុន្មានសម្រាប់ត្រៀមសវនាការលើបណ្ដឹងសាទុក្ខនោះ។ ខ្ញុំដឹងថានេះជាកង្វល់របស់អង្គជំនុំជម្រះក្នុងការកំណត់កាលវិភាគរបស់ខ្លួន។ យើងៗមិនទាន់មានដីកាកំណត់កាលវិភាគរបស់អង្គជំនុំជម្រះតុលាការកំពូលនៅឡើយទេ។ យើងគិតទុកជាមុនទៅតាមការផ្លាស់ប្ដូរយោបល់គ្នាក្រៅផ្លូវការ ថាសវនាការហ្នឹងប្រហែលជាធ្វើនៅមុនចុងឆ្នាំនេះ។ ប្រហែលជាអាចខែវិច្ឆិកា ពាក់កណ្ដាលខែវិច្ឆិកា ទៅដល់ចុងខែធ្នូ -- ពាក់កណ្ដាលខែធ្នូ ឬក៏ដើមខែធ្នូ យើងមិនទាន់ដឹងច្បាស់ទេ។ អ៊ីចឹងយើងមិនដឹងថាតើសវនាការលើបណ្ដឹងសាទុក្ខហ្នឹងប្រព្រឹត្តឡើងនៅពេលណាទេ។ ក៏ប៉ុន្តែយើងគិតថាប្រហែលជាជាង១០ថ្ងៃ។ ហើយយើងគិតមើលទៅតាមទំហំការងាររបស់យើងនោះ យើងមេធាវីការពារក្ដីហ្នឹង យើងប្រហែលជាត្រូវការប្រាំសប្ដាហ៍ អត់មានសវនាការអីទេ។ សុំឲ្យផ្អាកប្រាំសប្ដាហ៍ដើម្បីឲ្យយើងរៀបចំខ្លួនសម្រាប់សវនាការលើបណ្ដឹងសាទុក្ខ គឺដើម្បីឲ្យយើងអាចត្រៀមខ្លួនឆ្លើយតបទៅនឹងចម្លើយតបរបស់ភាគីផ្សេងទៀតផងដែរ ពីព្រោះថាអត់មានការឆ្លើយតបជាលាយលក្ខណ៍អក្សរទេ។ ខាងអង្គជំនុំជម្រះតុលាការកំពូល អត់មានគ្រោងឲ្យយើងធ្វើជាលាយលក្ខណ៍អក្សរទេ ចំពោះការឆ្លើយតបនោះ។ អ៊ីចឹងបានយើងត្រូវការត្រៀមខ្លួន។ ហើយវាមានសាក្សីថ្មីដែលនឹងត្រូវកោះហៅដោយតុលាការកំពូល ហើយយើងនឹងត្រូវការពេល ដើម្បីវិភាគទៅលើចម្លើយមុនៗរបស់សាក្សីទាំងអស់នេះ។ ដូច្នេះប្រហែលជាមានការកោះហៅសាក្សីបន្ថែមៗមកទៀត។ អ៊ីចឹងយើងត្រូវតែគិតលើចំណុចនេះ ដើម្បីត្រៀមខ្លួនឲ្យបានច្បាស់លាស់។ យើងខ្ញុំបានធ្វើការគណនារួចរាល់ហើយ។ យើងមិនអាចមកចូលសវនាការនៃតុលាការដំបូងផង ហើយត្រៀមខ្លួនសម្រាប់ការចូលទៅសវនាការតុលាការកំពូលផងទេ។ ហើយសវនាការលើបណ្ដឹងសាទុក្ខនេះជាដំណាក់កាលចុងក្រោយសំខាន់បំផុតសម្រាប់លោក ខៀវ សំផន។ នេះជាព័ត៌មានដែលខ្ញុំចង់ជម្រាបជូនអង្គជំនុំជម្រះ។ ហើយខ្ញុំសូមបញ្ជាក់ម្ដងទៀតថា ខ្ញុំមិនទាន់ដឹងថាតើអង្គជំនុំជម្រះតុលាការកំពូលកំណត់យកកាលវិភាគណានៅឡើយទេ។ ក៏ប៉ុន្តែពាក់ព័ន្ធទៅនឹងរយៈពេលការងារនោះ គឺយើងត្រូវការពេលវេលាពេញប្រាំសប្ដាហ៍តែម្ដងគឺ ដើម្បីឲ្យយើងអាចត្រៀមខ្លួននៅពេលធ្វើសវនាការលើបណ្ដឹងសាទុក្ខនោះ។

**ប្រធានអង្គជំនុំ៖**

ហើយសូមសួរមួយ លោកស្រីមេធាវីការពារក្ដី ខៀវ សំផន ត្រឡប់ទៅសំណើសុំទី១វិញ។ អំមិញថា រយៈពេលតាំងសំណួរដេញដោលដែលគ្រោងផ្ដល់ទៅឲ្យហ្នឹង លើអ្នកជំនាញ 2-TCE-95 នុ៎ងគឺវាទំនងខ្លីពេក ហើយបើការដែលលោកស្រីប្រមើលមើលថាសមរម្យហ្នឹង លោកស្រីស្នើសុំប្រហែល

ប៉ុន្មានទៅ? ព្រោះបញ្ហានេះកាលយើងផ្តល់ឲ្យភាគីមួយ គឺបានន័យថា ភាគីទាំងអស់ត្រូវបានទទួលពីអត្ថប្រយោជន៍នៃការពន្យារពេលនេះ វាប្រហែលៗគ្នា។

[១៦:០៦:៣៩]

**កញ្ញា អង់តា ហ្គិសសេះ**

លោកប្រធាន ខ្ញុំបានធ្វើសំណើនេះជាមុនហើយ ដើម្បីឲ្យភាគីទាំងអស់ទទួលបានពេលវេលាបន្ថែមទាំងអស់គ្នា។ ចំពោះខ្ញុំ គឺខ្ញុំគិតថា បីវគ្គ ទើបគ្រប់គ្រាន់សម្រាប់ការសួរអ្នកជំនាញរូបនេះ។ ដូច្នេះកន្លះថ្ងៃ ខ្ញុំសូមថែមមួយវគ្គ មួយពេលទៀត គឺត្រូវជាបីពេល បីវគ្គ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយចុះមេធាវី ខៀវ សំផន -- មេធាវី នួន ជា តើមានពាក់ព័ន្ធជាមួយនឹងបញ្ហាចុងក្រោយ លើកឡើងដោយមេធាវីការពារក្តី ខៀវ សំផន អម្បាញ់មិញនេះ លើការសុំរយៈពេលប្រាំសប្តាហ៍ ដើម្បីត្រៀមរៀបចំនូវសារណាផ្ទាល់មាត់សម្រាប់ធ្វើការលើបញ្ចប់ទៅលើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១នុ៎ង យ៉ាងម៉េចដែរ លោកមានមតិយោបល់អីទេ?

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ យើងខ្ញុំយល់ឃើញថា ខ្ញុំនឹងដាក់សំណើសុំរបស់យើងខ្ញុំ នៅពេលណាមានការកំណត់កាលបរិច្ឆេទសវនាការលើបណ្តឹងសាទុក្ខហើយនោះ ដើម្បីឲ្យយើងខ្ញុំអាចសម្រេចថាតើត្រូវពេលវេលាប៉ុន្មាន ដើម្បីធ្វើការរៀបចំ។ យើងខ្ញុំកំពុងពិភាក្សានៅឡើយ មិនដឹងថាពីថ្ងៃទី១០ទៅដល់ថ្ងៃទី២០ ខែធ្នូ ឬក៏យ៉ាងណាទេ ស្នើសុំរយៈពេលប៉ុណ្ណោះ។ ប៉ុន្តែយើងខ្ញុំយល់ -- ខ្ញុំយល់ឃើញថាការស្នើសុំរបស់ក្រុម ខៀវ សំផន ប្រាំសប្តាហ៍ មិនសមហេតុផលទេ វាមានការត្រូវការរៀបចំច្រើនជាងនេះ។ បើថាមានការរៀបចំពេលវេលាច្រើន ហើយយើងក៏ត្រូវពិនិត្យមើលឯកសារពីសំណុំរឿង០០៤នេះច្រើនផងទៀតដែរ។ ដូច្នេះយើងខ្ញុំសូមការស្នើសុំពេលវេលានេះ គឺថាមិនមានអ្វីដែលថាមិនសមហេតុផលនោះទេ។ យើងខ្ញុំនឹងដាក់សំណើជូនអង្គជំនុំជម្រះភ្លាមៗ នៅពេលដែលយើងខ្ញុំទទួលបានការកំណត់កាលបរិច្ឆេទលើបណ្តឹង សវនាការលើបណ្តឹងសាទុក្ខ។

[១៦:០៩:២០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណៗ ភាគីដែលបានផ្តល់កិច្ចពិភាក្សារាល់មតិយោបល់ទៅលើបញ្ហាដែលអង្គជំនុំជម្រះ

បានកំណត់ថាជាបញ្ហាប្រឈមចំពោះមុខ។ អញ្ជើញលោកសហព្រះរាជអាជ្ញា!

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំសូមផ្តល់មតិយោបល់ខ្លីទេ ពាក់ព័ន្ធទៅនឹងសំណើសុំរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន។ ទី១ យើងខ្ញុំយល់ស្របជាមួយក្រុមមេធាវីការពារក្តី នួន ជា ថា លឿនពេក ការស្នើសុំពេលវេលាដើម្បីធ្វើការរៀបចំនេះ ពីព្រោះថា យើងមិនទាន់មានការកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើបណ្តឹងសាទុក្ខ ឬក៏មិនទាន់មានថាតើ តើតុលាការកំពូលនឹងកំណត់ពេលវេលាដែលត្រូវឲ្យតាំងសំណួរដោយរបៀបណានៅឡើយទេ។ ដោយសារតែយើងមានមូលដ្ឋាននៃបណ្តឹងសាទុក្ខរហូតពី៣០០ទៅ៤០០មូលដ្ឋាននៃបណ្តឹងសាទុក្ខឯណោះ។ ពាក់ព័ន្ធទៅនឹងការកំណត់ពេលវេលាសួរ ពេលវេលាទៅលើអ្នកជំនាញខាងជនជាតិចាម កាលកំណត់ឲ្យ២ថ្ងៃ គឺថាជាការសមស្របហើយ។ ហើយយើងខ្ញុំយល់ស្របផងដែរ ចំពោះសំណើសុំថាឲ្យសួរសក្ខីកម្មរបស់អ្នកជំនាញក្រោយការសួរសាក្សីដទៃៗទៀត ចប់សព្វគ្រប់សិន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះនឹងយកបញ្ហានេះ យកទៅពិភាក្សា ចេញសេចក្តីសម្រេចដោះស្រាយលើបញ្ហានេះ បញ្ហាដែលអាចចេញដោះស្រាយបានតាមដែលអាចធ្វើទៅបាន ហើយបញ្ហាណាដែលត្រូវទុកសិន បង្អង់ទុកសិននោះ គឺនឹងធ្វើតាមស្ថានភាពជាក់ស្តែងនៃបញ្ហាចំពោះមុខ។

បាទ សវនាការនៅថ្ងៃនេះ ដល់ពេលត្រូវឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី០៥ ខែតុលា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃចន្ទ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-950 និងអាចមានសាក្សីបម្រុង 2-TCW-904 ដែលអង្គជំនុំជម្រះមានគម្រោងបន្តពីសក្ខីកម្មសាក្សី 2-TCW-950។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

[១៦:១១:៥២]

**លោក វ៉ិចទ័រ កូប៉េះ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

បាទ អរគុណមិនមានអីទេ មិនមានសវនាការទេ នៅក្នុងចុងសប្ដាហ៍នេះ ព្រោះយើងអត់មានបុគ្គលដែលយើងត្រូវស្ដាប់។ លទ្ធភាពដែលអាចអញ្ជើញបុគ្គលដែលត្រូវស្ដាប់នោះគឺមិនអាចធ្វើបានទេ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់ឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការវិញ នៅថ្ងៃចន្ទ ទី០៥ ខែតុលា ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ!

*(សវនាការផ្អាកនៅម៉ោង ១៦:១២ នាទី)*